ប្រស្នាពុទ្ធប្រវត្តិ
ពិស្ដារ

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

ប្រស្នាពុទ្ធប្រវត្តិ

គឺ

ឃុនបណ្ឌានុរក្ស ម៊ួ - ម៉ួ
នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

ឃុនសុវត្ថិទេធី យូ - ទ៊្វិន

ពិនិត្យកែ

ផ្សាយចេញលើកទីបី

សាន-ភារ៉េត

ភ្នំពេញ
ព.ស. ២៤៩៥
គ.ស. ១៩៥២

ប្រស្នាពុទ្ធប្បវត្តិ

គឺ

ឃុនបណ្ឌានុរក្ស ម៉ូ - ម៉ូ

នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

ឃុនសុវត្ថិទេធី យូ - អ៊ុន

ពិនិត្យកែ

ផ្សាយចេញលើកទីបី

សាន-តារ៉េត

ភ្នំពេញ

ព. ស. ២៤៩៥

គ. ស. ១៩៥២

អារម្ភកថា

·····○·····

សៀវភៅ "ប្រស្នាពុទ្ធប្រវត្តិ" នេះ ជាពាក្យសួរ-ឆ្លើយក្នុងពុទ្ធប្រវត្តិ, ខ្ញុំបានរៀបរៀងឡើងដោយបានមើលគម្ពីរផ្សេង ៗ ជាច្រើន ដើម្បីទុកជាបែបសិក្សា របស់សិក្ខាកាមកុលបុត្រអ្នកសិក្សាពុទ្ធប្រវត្តិផង ដើម្បីជាសម្បត្តិប្រាជ្ញារបស់ពុទ្ធបរិស័ទ្យផង ។ ខ្ញុំសន្និដ្ឋានថា សៀវភៅនេះបើពុទ្ធបរិស័ទ្យបានមានហើយ អាចនឹងបំបាត់សេចក្ដីឆ្ងើងឆ្ងល់ក្នុងពុទ្ធប្រវត្តិបានខ្លះ ហើយនឹងតម្រង់ខ្លួនក្នុងផ្លូវប្រតិបត្តិព្រះពុទ្ធសាសនាឲ្យបានត្រឹមត្រូវដោយសមសួន ។

ឯបុព្វហេតុដែលនាំឲ្យកើតជាសៀវភៅនេះ ដោយសារឃុនសុវត្ថិទេធី យូរ-អ៊ុន. នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ជាកល្យាណមិត្ររបស់ខ្ញុំ លោកបានណែនាំឲ្យខ្ញុំរៀបរៀងឡើង ។ កាលខ្ញុំរៀបរៀងចប់ហើយ លោកនេះបានជួយពិនិត្យកែតម្រង់ ព្រមទាំងចាត់ការបោះពុម្ពនេះឡើង ។ ហើយមុននឹងឡើងកាន់ពុម្ព ខ្ញុំបានយកទៅប្រគេនព្រះតេជព្រះគុណព្រះគ្រូមុនីសោភ័ណ សេខ-នាង សាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ នឹងព្រះមហាប៉ាង-ខាត់ ក្រុមជំនុំព្រះត្រៃបិដក សូមឲ្យជួយពិនិត្យ ១លើកទៀត ។ តែប្រសិនបើសេចក្ដីក្នុងសៀវភៅនេះ នៅមានខុសឃ្លៀងឃ្លាតខ្លះ ខ្ញុំសូមអភ័យទោសអំពីអ្នកប្រាជ្ញទាំងឡាយ សូមជួយកែតម្រង់ឲ្យបានផង ដើម្បីទុកជាសម្បត្តិព្រះពុទ្ធសាសនាតរៀងទៅ ។

ក្នុងទីបំផុតនេះ ខ្ញុំសូមឧទ្ទិសកុសលដែលកើតអំពីកម្លាំងព្យាយាម រៀបរៀងប្រស្នាពុទ្ធប្រវត្តិនេះ ជូនដល់បុព្វការីទាំងឡាយមានមាតាបិតាជាដើម សូមឲ្យបុព្វការីទាំងឡាយនោះបានសម្រេចឥដ្ឋមនុញ្ញផលកុំបីឃ្លៀងឃ្លាត ៗ ដោយតេជានុភាពនៃកុសលនេះ សូមព្រះពុទ្ធសាសនាក្នុងកម្ពុជរដ្ឋចំរើនរុងរឿងជាកិរិយាភាព រហូត ៥.០០០ ព្រះវស្សា ៗ

ថ្ងៃទី ១០ ខែធ្នូ ព.ស. ២៤៩៤ គ.ស. ១៩៥១

ឃុនបណ្ណានុរ័ក្សប៊ូ-ប៉ូ

បណ្ឌិតពិតមិនលះព្យាយាម

ជាតិខ្លឹមបន្ទន់ ទោះស្ងួត ក្រៀមក្រញ៉ង់
មិនលះបង់ក្លិនខ្លឹមដ៏បវរ
អំពៅទោះនៅក្នុងយន្តស្ករ
មិនបរបង់រសផ្អែមឆ្ងាញ់បាន ។
ជាតិខ្លាទោះតូចដូចម្ដេចម្ដា
មិនបង់ក្រឡាអុបតាមប្រាណ
ជាតិឆ្មាទោះណាខ្សោយប៉ុន្មាន
មិនបានលះបង់ការរហ័ស ។
ជាតិប្រាជ្ញទោះបានទុក្ខលំបាក
មិនបាកបោលការឧស្សាហ៍ណាស់
សាងសុខសួស្ដីដល់ក្មេងចាស់
ប្រកាសកេរ្តិ៍ឈ្មោះពីរោះឆ្ងាយ

អ្នកឧកញ៉ាសុត្តន្តប្រីជា ឥន្ទ

បញ្ជីរឿង

ទំព័រ

ពាក្យប្រារព្ធ ១
ជម្ពូទ្វីបនិងប្រជាជន ៦
សក្កជនបទ ១១
សាក្យវង្សនិងកោលិយវង្ស ១៣
ព្រះសាស្តាចុះចាប់បដិសន្ធិ ១៧
ព្រះសាស្តាប្រសូត ២៥
ទំនាយព្រះលក្ខណៈនៃព្រះសាស្តា ៣០
រាជាភិសេក ៤២
ព្រះសាស្តាចេញទ្រង់ព្រះផ្នួស ៤៧
ព្រះសាស្តាធ្វើទុក្ករកិរិយា ៦០
ពុទ្ធបូជា ៧១
មារវិជ័យ ៧៣
អភិសម្ពោធិ ៧៥
ពោធិសព្វញ្ញូ ៧៩
ព្រហ្មជ្ឈេសនៈ ៨២
ធម្មចក្កប្បវត្តនទេសនា ៨៥

យសបព្វជ្ជា ៩៧
ឧរុវេលាគមនៈ ៩៩
អគ្គសាវកបព្វជ្ជា ១០១
កបិលវត្ថុគមនៈ ១០៥
ពិម្ពាពិលាប ១០៧
សាក្យបព្វជ្ជា ១០៧
មេត្តេយ្យព្យាករណ៍ ១០៩
ពុទ្ធបិតុនិព្វាន ១១១
យមកប្បាដិហារ្យ ១១២
ទេសនាបរិវត្តន៍ ១១៣
ទេវោរោហនបរិវត្តន៍ ១១៣
អគ្គសាវកនិព្វាន ១១៤
ពុទ្ធបរិនិព្វាន ១១៥
ធាតុភាជនៈ ១១៨
សង្គាយនា ៥ .. .. ១២៤
ប្រស្នាកាយវេរក្នុងពុទ្ធប្រវត្តិ ១៣៤
ពុទ្ធប្បវត្តិតាមថាសន្តរោហា ១៦៨

ប្រស្នាពុទ្ធប្រវត្តិ

ពាក្យប្រារព្ធ

១- សំនួរ = ពុទ្ធប្រវត្តិ គឺអ្វី ?

ចម្លើយ = គឺជារឿងរ៉ាវដែលពណ៌នាអំពីការប្រព្រឹត្តិរបស់ព្រះសម្មាសម្ពុទ្ធ ។

២-ស. ការរៀនពុទ្ធប្រវត្តិមានប្រយោជន៍ដូចម្ដេច ?

ច. មានប្រយោជន៍ជាសំខាន់ក្នុងការប្រតិបត្តិព្រះពុទ្ធសាសនា ព្រោះពុទ្ធប្រវត្តិចង្អុលបង្ហាញពុទ្ធចរិយាឲ្យឃើញជាក់ស្ដែង ដូចគ្នានឹងប្រវត្តិរបស់ជាតិនិមួយៗ អាចចង្អុលឲ្យឃើញថាមានដើមកំណើតមកដូចម្ដេចៗខ្លះ ។ ព្រះសម្ពុទ្ធជាគំរូល្អយ៉ាងវិសេស ទ្រង់មានឧបាយនិងមានរបៀបចាត់ការក្នុងករណីយកិច្ចដែលជាប្រយោជន៍ដល់ព្រះអង្គឯង ទាំងជាប្រយោជន៍ដល់សត្វដទៃ ;ជនណាបានរៀនពុទ្ធប្រវត្តិចប់ហើយ ជននោះតែងបានដឹងនូវពុទ្ធចរិយាថា ព្រះអង្គមានអាការល្អយ៉ាងណាៗខ្លះ, នេះទុកដូចជាបានឃើញគំរូយ៉ាងល្អ ដែលជាហេតុធ្វើដំរិករបស់ខ្លួនឲ្យមានប្រយោជន៍ទាំងប្រព្រឹត្តិឲ្យត្រឹមត្រូវតាមគន្លងធម៌បាន; ឯប្រយោជន៍នោះបើយ៉ាង

ហោចណាស់ ក៏គង់យកបែបយ៉ាងរបស់ព្រះអង្គមកប្រើក្នុងកិច្ចការខាងផ្លូវលោកនេះបានខ្លះៗ ដូចយើងដែលខំព្យាយាមទំអត់ធន់យកគម្រាប់តាមព្រះអង្គជាដើម ។ មួយទៀត អ្នករៀនពុទ្ធប្រវត្តិ កាលបានចេះដឹងរឿងរ៉ាវរបស់ព្រះអង្គច្បាស់លាស់ហើយ រមែងស្គាល់គុណភាពរបស់ព្រះអង្គរឹតតែខ្លាំងឡើង ជាហេតុបណ្ដុះបសាទសទ្ធាក្នុងព្រះអង្គឲ្យខ្លាំងក្លា ឧបមាដូចយើងនឹករឭកដល់បុព្វបុរស ដែលបានធ្វើផលប្រយោជន៍ទុកក្នុងត្រកូលរបស់យើងៗ នឹករឭកឃើញគុណនៃលោកនោះ ជាហេតុឲ្យយើងយកគម្រាប់តាមលំអានរបស់លោក ។

ស. ក្នុងពុទ្ធប្រវត្តិ លោកចែកកាលជាប៉ុន្មាន ? គឺអ្វីខ្លះ ? រាប់ពីត្រឹមណា ទៅដល់ត្រឹមណា ហៅថាកាលអ្វី ?

ច. លោកចែកជា ៣ គឺ: បឋមពោធិកាល ១, មជ្ឈិមពោធិកាល ១, បច្ឆិមពោធិកាល ១ ។ រាប់ពីត្រឹមឆ្នាំដែលព្រះអង្គបានត្រាស់មកដល់ឆ្នាំទី ១៥ ហៅថា បឋមពោធិកាល; រាប់ពីត្រឹមឆ្នាំទី ១៦ ដល់ឆ្នាំទី ៣០ ហៅមជ្ឈិមពោធិកាល, រាប់ពីត្រឹមឆ្នាំទី ៣១ ដល់ឆ្នាំទី ៤៥ ហៅថា បច្ឆិមពោធិកាល ។

៤ ស. ពុទ្ធប្រវត្តិជាប់ទាក់ទងនឹងការប្រតិបត្តិក្នុងព្រះធម្មវិន័យដូចម្ដេចទៅ បានជាលោកយកមករួបរួមទុកក្នុងចំណែកមួយនៃការសិក្សា ?

ឆ. ពុទ្ធប្រវត្តិជាឫសគល់នៃការប្រតិបត្តិ, ជាក្បួនយ៉ាងនៃសេចក្ដីប្រព្រឹត្តិក្នុងផ្លូវព្រះពុទ្ធសាសនា, ជាឧបាយនាំឲ្យកើតសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ ឲ្យដុះចិត្តដុះគំនិត ចង់ប្រតិបត្តិព្រះធម្មវិន័យដោយខ្លួនឯង មិនចាំបាច់មានអ្នកណាបង្ខិតបង្ខំ ។

៥-ស. សេចក្ដីក្នុងពុទ្ធប្រវត្តិបើរួបរួមឲ្យខ្លីមកមានប៉ុន្មានផ្លូវ? គឺផ្លូវអ្វីខ្លះ?

ឆ. មាន ៣ ផ្លូវគឺផ្លូវ ១ ជាប់ទាក់ទងដោយរឿងរ៉ាវ, ផ្លូវ ១ ជាប់ទាក់ទងដោយអភិនីហារ, ផ្លូវ ១ ទៀតជាប់ទាក់ទងដោយការប្រតិបត្តិធម៌ ។

៦-ស. បណ្ដាផ្លូវទាំង ៣ នេះ តើផ្លូវណាអាចឲ្យសម្រេចផលដល់អ្នកសិក្សាដូចម្ដេច?

ឆ. ផ្លូវដែលទាក់ទងដោយរឿងរ៉ាវ អាចសម្រេចផលដល់អ្នករៀនឲ្យដឹងរឿងរបស់ព្រះពុទ្ធ; ផ្លូវដែលទាក់ទងដោយអភិនីហារ អាចសម្រេចផលដល់អ្នករៀន ឲ្យកើតសេចក្ដីស្ងើចអស្ចារ្យក្នុងពុទ្ធានុភាព ទាំងឲ្យកើតសទ្ធាជ្រះថ្លាចូលចិត្តក្នុងការប្រតិបត្តិធម៌; ផ្លូវដែលជាប់ទាក់ទងដោយការប្រតិបត្តិធម៌ អាចឲ្យសម្រេចផលដល់អ្នករៀនឲ្យដឹងសេចក្ដីប្រព្រឹត្តិ និងហេតុផលតាមពិតដ៏ល្អិតសុខុម ។

៧-ស. ពុទ្ធភូមិមានប៉ុន្មាន? គឺអ្វីខ្លះ?

ឆ. មាន ៣ គឺ បញ្ញាធិក ១, សទ្ធាធិក ១, វីរិយាធិក ១ ។

៨-ស. ព្រះបរមសាស្ដានៃយើងទ្រង់កសាងជាពុទ្ធភូមិអ្វី? កំណត់កាលប៉ុន្មានអសង្ខេយ្យ ទើបបានត្រាស់ជាព្រះពុទ្ធ?

ឆ. ព្រះអង្គកសាងជាបញ្ញាធិក ។ កំណត់កាល ៤ អសង្ខេយ្យ និង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។

៩-ស. ក្នុង ៤ អសង្ខេយ្យនិង ១ សែនកប្បនោះ តើព្រះសាស្ដានៃយើងបានព្យាករណ៍ (បានទំនាយ) ក្នុងសំណាក់នៃព្រះពុទ្ធប៉ុន្មានព្រះអង្គ? ចូររាប់ព្រះនាមព្រះពុទ្ធទាំងនោះមកមើល!

ឆ. ក្នុងសំណាក់នៃព្រះពុទ្ធ ២៤ ព្រះអង្គគឺព្រះពុទ្ធទីបង្ករ ១, កោណ្ឌញ្ញ ១, សុមង្គលៈ ១, សុមនៈ ១, រេវតៈ ១, សោភិតៈ ១, អនោមទស្សី ១, បទុមៈ ១, នារទៈ ១, បទុមុត្តរៈ ១, សុមេធៈ ១, សុជាតៈ ១, បិយទស្សី ១, អត្ថទស្សី ១, ធម្មទស្សី ១, សិទ្ធត្ថៈ ១, តិស្សៈ ១, ផុស្សៈ ១, វិបស្សី ១, សិខី ១, វេស្សភូ ១, កកុសន្ធៈ ១, កោនាគមនៈ ១, កស្សបៈ ១ ។

១០-ស. ក្នុងសម័យព្រះពុទ្ធទីបង្ករទី ១ នោះ តើព្រះសាស្ដានៃយើងសោយព្រះជាតិជាអ្វី? កសាងបារមីដូចម្ដេច?

ឆ. ព្រះអង្គសោយព្រះជាតិជាព្រាហ្មណ៍ មាននាមថា សុមេធ ។ ព្រះសុមេធព្រាហ្មណ៍នេះលះសម្បត្តិចេញបួសជាឫសីបាន

សម្រេចឈាន និងអភិញ្ញា ; ថ្ងៃមួយ ព្រះតាបសបានធ្វើផ្លូវថ្វាយព្រះពុទ្ធទីបង្ករ ប៉ុន្តែធ្វើពុំទាន់រួចស្រេច ស្រាប់តែព្រះពុទ្ធស្តេចមកដល់ ព្រះតាបសក៏ប្រះខ្លួនក្រាលទៅលើភក់ រួចនិមន្តព្រះសាស្តានិងភិក្ខុសង្ឃឲ្យយាងស្មរលើខ្លួនឆ្លងភក់នោះទៅ ។ ព្រះពុទ្ធទីបង្ករទ្រង់ត្រាស់ព្យាករថា តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធនាមថា គោតម ក្នុងអនាគត ។

១១- ស. ក្នុងសម័យនៃព្រះពុទ្ធកស្សបៈជាគំរប់ ២៤ នោះ តើព្រះសាស្តានៃយើងសោយព្រះជាតិជាអ្វី? បានកសាងបារមីដូចម្តេច?

ឆ. ព្រះអង្គសោយព្រះជាតិជាជោតិបាលមាណព ។ ជោតិ-បាលមាណពនេះចេញបួសក្នុងព្រះពុទ្ធសាសនា បានស្តាប់ពុទ្ធព្យាករណ៍ហើយ. ក៏មានចិត្តជ្រះថ្លា ឧស្សាហ៍បំពេញបារមីធម៌ទាំង ៣០ ប្រការ និងមហាបរិច្ចាគ៥ឲ្យបរិបូណ៌គ្រប់ជាតិដែលព្រះអង្គកើតតាមលំដាប់មកទៀត ។

១២-ស. បារមីទាំង ៣០ ប្រការនោះគឺអ្វីខ្លះ? ក្នុងបារមីមួយ ៗ លោកចែកជាប៉ុន្មាន? ឲ្យឈ្មោះដូចម្តេច? បើមិនហៅថាបារមីទេ និងហៅថាជាអ្វីបានទៀត?

ឆ. គឺទាន១, សីល១, នេក្ខម្ម១, បញ្ញា១, វីរិយ១, ខន្តី១, សច្ចៈ១, អធិដ្ឋាន១, មេត្តា១, ឧបេក្ខា ១ ។ ក្នុងបារមីមួយៗលោកចែកចេញជាបីៗ

ដូចគ្នា ។ ឲ្យឈ្មោះថាទានបារមី ១ ទានឧបបារមី ១ ទានបរមត្ថបារមី១ (តាំងពីសីលដល់ឧបេក្ខាក៏ចែកជាបីៗ ដូចទានដែរ រួមគ្នាជាបារមី ៣០ ប្រការ) ។ បារមី ៣០ ប្រការនេះនឹងហៅថា ពុទ្ធការកធម៌វិញក៏បាន ។

១៣-ស. មហាបរិច្ចាគ ៥ ប្រការគឺអ្វីខ្លះ ?

ឆ. គឺអង្គបរិច្ចាគ (លះបង់អវយវៈណាមួយឲ្យជាទាន) ១. ធនបរិច្ចាគ (លះបង់ទ្រព្យសម្បត្តិឲ្យជាទាន) ១, បុត្តបរិច្ចាគ (លះបង់កូនឲ្យជាទាន)១, ទារបរិច្ចាគ (លះបង់ប្រពន្ធឲ្យជាទាន) ១. ជីវិតបរិច្ចាគ (លះបង់ជីវិតឲ្យជាទាន) ១ ។

១៤-ស. ព្រះសាស្តានៃយើងកាលព្រះអង្គច្យុតពីអត្តភាពជាព្រះបាទវេស្សន្តរហើយ តើព្រះអង្គបានទៅកើតនៅទីណា? មានព្រះនាមថាអ្វី? កំណត់ព្រះជន្មប៉ុន្មានឆ្នាំ ?

ឆ. ព្រះអង្គទៅកើតនៅស្ថានតុសិតសួគ៌ ។ មានព្រះនាមថា សន្តុសិតទេវបុត្រ ។ កំណត់ព្រះជន្ម ៤ ពាន់ឆ្នាំទិព្វ ត្រូវជា ៥៧ កោដិ និង ៦០ សែនឆ្នាំមនុស្ស ។

ជម្ពូទ្វីបនិងប្រជាជន

១៥-ស. ជម្ពូទ្វីបនៅឯណា ? នៅខាងណាប្រទេសយើង ? មនុស្សជាតិអ្វីបានចាប់ផ្តើមតាំងមក ?

ឆ. ជម្ពូទ្វីបគឺដែនដីដែលយើងហៅសព្វថ្ងៃនេះថា ឥណ្ឌា ។ ប្រទេសឥណ្ឌានោះនៅខាងទិសពាយ័ព្យនៃប្រទេសកម្ពុជាយើង ។ មនុស្សជាតិអរិយកៈចាប់ផ្ដើមតាំងជាទីលំនៅមកក្នុងប្រទេសនោះ ឯមនុស្សពួកអរិយកៈនេះមិនមែនជាម្ចាស់នៃប្រទេសឥណ្ឌានោះទេ បាននាំគ្នាលើកចុះមកអំពីដែនដីខាងជើង ឆ្លងភ្នំហិមាល័យដោយពិធីរុករានទន្ទ្រានដេញពួកមិលក្ខៈជាម្ចាស់ស្រុកឲ្យថយចុះមកទិសខាងត្បូងបន្តិចម្ដងៗ, ហើយជនជាតិអរិយកៈឯង បានចូលទៅតាំងលំនៅក្នុងជម្ពូទ្វីបគឺប្រទេសឥណ្ឌានោះ ។ ពួកមនុស្សអរិយកៈនោះ ជាអ្នកចំរើនដោយសេចក្ដីចេះដឹងនឹងទំនៀមទំលាប់ ហើយមានឫទ្ធិអំណាចជាងពួកមិលក្ខៈដែលជាម្ចាស់ស្រុកដើម ទើបអាចចាត់ការតាំងស្រុកទេសនឹងការគ្រប់គ្រងបានល្អជាង ។

១៦–ស. ជម្ពូទ្វីបនោះចែកជាប៉ុន្មានភាគ ? ហៅថាអ្វី ?

ឆ. ចែកជា ២ ភាគ ។ រួមខេត្រខាងក្នុងហៅថា មជ្ឈិមជនបទ ប្រែថា "ប្រទេសកណ្ដាល", រួមខេត្រខាងក្រៅ ហៅថាបច្ចន្តជនបទ ប្រែថា "ប្រទេសចុងដែន" ។

១៧-ស. ក្នុងសម័យពុទ្ធកាល គេចែកព្រំដែននៃមជ្ឈិមជនបទ និងបច្ចន្តជនបទផ្សេងគ្នាដូចម្ដេច ? មានគោលកំណត់ទុកក្នុងរឿងអ្វី ?

ឆ. លោកចែកផ្សេងគ្នា ដូចមានគោលកំណត់ទុកត្រង់បាលីចម្មក្ខន្ធក ក្នុងគម្ពីរមហាវគ្គនៃវិនយបិដក ដូច្នេះ ៖

ក) ទិសបូព៌ា ខាងក្នុង រាប់អំពីមហាសាលនគរចូលមក ។

ខ) ទិសអគ្នេយ៍ ខាងក្នុង រាប់អំពីស្ទឹងសល្លវតីចូលមក ។

គ) ទិសទក្សិណ ខាងក្នុង រាប់អំពីស្ទឹងសេតកណ្ណិកនិគមចូលមក ។

ឃ) ទិសបស្ចិម ខាងក្នុង រាប់អំពីថូនគ្រាមចូលមក ។

ង) ទិសឧត្តរ ខាងក្នុង រាប់អំពីភ្នំឧសីរទ្ធជៈចូលមក ។

ទីក្នុងខាងក្នុងនៃគោលកំណត់នេះ ហៅថា មជ្ឈិមជនបទ, ទីខាងក្រៅអំពីគោលកំណត់នេះចេញទៅ ហៅថា បច្ចន្តជនបទ ។

១៨–ស. អាណាចក្រក្នុងជម្ពូទ្វីប សម័យពុទ្ធកាលដែលមានឈ្មោះប្រាកដ តើអ្វីខ្លះ ? មានវិធីគ្រប់គ្រងដូចម្ដេច ?

ឆ. ជម្ពូទ្វីបនោះចែកចេញជាច្រើនអាណាចក្រ ដែលមានឈ្មោះក្នុងសម័យពុទ្ធកាល, តាមដែលលោកបានសំដែងទុកក្នុងឧបោសថសូត្រក្នុងតិកនិបាតអង្គុត្តរនិកាយថា នាក់ជាមហាជនបទ ១៦ គឺអង្គៈ, មគធៈ, កាសី, កោសល, វជ្ជី, មល្លៈ, ចេតី, វំសៈ, កុរុ, បញ្ចាល, មច្ឆៈ, សុរសេនៈ, អស្សកៈ, អវន្តិ, គន្ធារៈ, កម្ពោជៈ ។ តែមានសំដែងទុកក្នុងព្រះសូត្រដទៃ ដែលមិនស្ទួននឹងឈ្មោះខាងដើមនេះ គឺសក្កៈ, កោលិយៈ,ភគ្គៈ, វិទេហៈ, អង្គុត្តរាបថ, រួម ៥ ជនបទនេះទៀត ត្រូវជា ២១ ជនបទ ។ អាណាចក្រអម្បាលនេះ មានស្ដេចម្ចាស់ដែនដីទ្រង់

យសជាព្រះមហាពជខ្លះ, ជាព្រះរាជាខ្លះ, ជាអធិបតីខ្លះ, ជាអ្នកគ្រប់គ្រងដោយការប្រើសិទ្ធានុភាពផ្តាច់ខាតចំពោះខ្លួនខ្លះ, ដោយសាមគ្គីធម៌ខ្លះ, មានកាលតាំងជាឥស្សរភាពតាមកម្លាំងខ្លួន, មានកាលធ្លាក់ទៅជាអាណានិគមនៃប្រទេសដទៃ តាមសម័យដែលមានអានុភាពឬថយអានុភាព ។

១៩-ស. ពីបុរាណកាល គេចែកមនុស្សក្នុងជម្ពូទ្វីបជាប៉ុន្មានប្រភេទ? គឺអ្វីខ្លះ? ហើយប្រភេទណា មានមុខការយ៉ាងណា?

ច. គេចែកជា ៤ ប្រភេទដែលហៅថាវណ្ណៈ ៤ គឺៈ ខត្តិយៈ ១, ព្រាហ្មណៈ ១, វេស្ស ១, សុទ្ទៈ ១ ។ ខត្តិយៈ= ពួកក្សត្រ មានមុខការខាងផ្លូវគ្រប់គ្រងប្រទេសត្រូវរៀនសូត្រវិជ្ជាខាងយុទ្ធវិធី; ព្រាហ្មណៈ=ពួកព្រាហ្មណ៍ មានមុខការខាងផ្លូវបង្ហាត់បង្រៀនព្រមទាំងធ្វើពិធីផ្សេងៗត្រូវសិក្សាខាងផ្លូវសាសនានិងវិជ្ជាផ្សេងៗ; វេស្សៈ = ពួកវេស្សៈ មានមុខការធ្វើស្រែចំការនិងការលក់ដូរ ត្រូវសិក្សាវិជ្ជាសិល្បកម្មនិងកសិកម្ម ពាណិជ្ជកម្មៈ សុទ្ទៈ=ពួកសូទ្រៈ មានមុខការខាងផ្លូវស៊ីឈ្នួលធ្វើការងារឲ្យគេ ត្រូវសិក្សាក្នុងការងារដែលនឹងធ្វើដោយកម្លាំងកាយ ។ ឯក្សត្រនិងព្រាហ្មណ៍ចាត់ជាជាតិខ្ពង់ខ្ពស់, វេស្សៈ និងសូទ្រៈ ចាត់ជាជាតិថោកទាប ។

២០-ស. មនុស្សក្នុងជាន់នោះយល់ឃើញនូវសេចក្ដីកើត-ស្លាប់និងសុខទុក្ខដូចម្ដេច? បើបំប្រួញឲ្យខ្លីមកមានប៉ុន្មាន?

ច. មនុស្សក្នុងជាន់នោះ សង្កាត់ក្នុងវិជ្ជាធម៌ណាស់ បានជាកើតមានពួកអ្នកមេទិដ្ឋិច្រើន, គេយល់ឃើញនូវសេចក្ដីស្លាប់កើតសុខទុក្ខផ្សេងៗគ្នា ។ ប៉ុន្តែបើបំប្រួញសេចក្ដីយល់ឃើញទាំងអស់នោះឲ្យខ្លីមកនៅត្រឹម ២ យ៉ាង គឺពួកប្រកាន់ថាស្លាប់ហើយកើតទៀត ១, ពួកប្រកាន់ថាស្លាប់ហើយសូន្យ ១ ។ ក្នុងពួកដែលប្រកាន់ថាស្លាប់ហើយកើតទៀតនោះ ពួកខ្លះយល់ឃើញថាស្លាប់កើតជាអ្វី ក៏គង់នៅជាយ៉ាងនោះដដែល មិនប្រែប្រួលជាអ្វីទៀតទេ, ពួកខ្លះយល់ឃើញថាកើតហើយច្យុតប្រែប្រួលទៅជាអ្វីទៀតបាន ។ ក្នុងពួកដែលប្រកាន់ថាស្លាប់ហើយសូន្យនោះ ពួកខ្លះយល់ថាសូន្យដោយចំណែកៗ, ពួកខ្លះយល់ឃើញថាបណ្ដាមនុស្សនឹងបានសុខឬទុក្ខនោះ ឥតហេតុបច្ច័យទេ ។

២១-ស. ចូរពន្យល់ឲ្យឃើញច្បាស់ថា ព្រោះហេតុអ្វីបានជាក្នុងបុរាណកាលមានពួកគណាចារ្យប្រៀនប្រដៅលទ្ធិផ្សេងៗច្រើនគ្នាម្ល៉េះ ?

ច. ព្រោះមនុស្សក្នុងយុគនោះចូលចិត្តស្វែងរកធម៌ណាស់ ។ មានពួកមុនអ្នកប្រាជ្ញលះបង់ទ្រព្យសម្បត្តិក្នុងឃរាសចេញជាច្រើន ប្រគល់ជីវិតរបស់ខ្លួនទៅក្នុងការប្រៀនប្រដៅមនុស្សទាំងឡាយ ធ្វើជាគណាចារ្យតាំងទីលំនៅផ្សេងៗគ្នាតាមលទ្ធិមានបរិវារធ្វើតាមឱវាទបង្ហាញផល

ទីបំផុតនៃលទ្ធិនោះៗ ។ កេរ្តិ៍ឈ្មោះរបស់សាស្តាជាមេលទ្ធិល្បីខ្ចរខ្ចាយទៅមហាជនទាំងពួងមានម្ចាស់ផែនដីជាដើម តែងតែស្រឡាញ់រាប់អានលើកដំកើងយ៉ាងខ្ពង់ខ្ពស់ ព្រោះហេតុនេះបានជាពួកគណាចារ្យប្រាថ្នាចង់បានកេរ្តិ៍ឈ្មោះណាស់ ប្រកាសលទ្ធិរបស់ខ្លួនថាត្រឹមត្រូវថាបានខ្លឹមសារ, ឯលទ្ធិរបស់គណាចារ្យដទៃខុសឥតខ្លឹមសារ ។ ព្រោះហេតុនេះបានជាមានគណាចារ្យប្រៀនប្រដៅលទ្ធិផ្សេងៗគ្នាជាច្រើនរូប ។

សក្កជនបទ

២២–សំ. សក្កជនបទនោះតាំងនៅក្នុងទីណា? ហេតុអ្វីបានឈ្មោះថាសក្កជនបទ?

ចំ. សក្កជនបទនោះតាំងនៅក្នុងជម្ពូទ្វីប គឺប្រទេសឥណ្ឌៀប៉ែកខាងជើង ជិតដែនព្រៃហិមពាន្តៗ បានជាឈ្មោះថា សក្កជនបទដូច្នោះ ព្រោះមុនដំបូងគេចាប់ផ្ដើមកសាងឡើងក្នុងដងព្រៃសក្កៈ ។

២៣–សំ. សក្កជនបទជាប្រទេសធំឬតូច? មានអ្វីជាគោលល្មមយកមកអាងឲ្យឃើញផង?

ចំ. សក្កជនបទជាប្រទេសតូច ។ មានបាលីក្នុងឧបោសថសូត្រក្នុងតិកនិបាតអង្គុត្តរនិកាយជាគោលអាង គឺថាសក្កជនបទមិនមានប្រាកដក្នុងមហាជនបទទាំង ១៦ នោះទេ (ចូរមើលត្រង់ប្រស្នាទី ១៨) ។

២៤–សំ. ព្រះវង្សនៃព្រះសាស្តារបស់យើងហៅថាអ្វី? តាំងនៅក្នុងទីណា? មានមូលហេតុកើតមកដូចម្ដេច? ចូររៀបរាប់ដោយសង្ខេបឲ្យល្មមតែស្ដាប់បានមកមើល!

ចំ. ហៅថា សាក្យៈ ។ តាំងនៅក្នុងសក្កជនបទ នាជម្ពូទ្វីបប៉ែកខាងជើងដែនប្រទេសហិមពាន្ត ។ មានរឿងរ៉ាវដំណាលដោយសង្ខេបថា: ដោយសេចក្ដីភាំងភាត់របស់ព្រះបាទឱក្កាករាជ ដែលព្រះរាជទានព្រះពរដល់ព្រះមហេសីថ្មីឲ្យព្រះនាងរើសយករបស់តាមប្រាថ្នា, ព្រះនាងក៏ទូលសូមរាជសម្បត្តិឲ្យព្រះរាជឱរសរបស់ព្រះនាង ។ ដើម្បីនឹងរក្សាព្រះរាជសច្ចៈ ព្រះបាទឱក្កាករាជត្រូវតែបង្គាប់ឲ្យព្រះរាជឱរស ៤ ព្រះអង្គនិងរាជធីតា ៥ ព្រះអង្គដែលប្រសូតអំពីព្រះមហេសីមុន នាំគ្នាលើកចតុរង្គសេនាចេញចាកព្រះនគរ ទៅកសាងព្រះនគរក្នុងដងព្រៃសក្កៈ ប្រទេសហិមពាន្ត បានជាជនបទនោះមានឈ្មោះថា សក្កជនបទ ។ ឯពួកក្សត្រសាក្យៈនោះ គួរតែមានឈ្មោះតាមជនបទ ប៉ុន្តែក្នុងអដ្ឋកថាប្រាប់ថាបានជាឈ្មោះសាក្យៈដូច្នោះ ព្រោះជាអ្នកអាចតាំងស្រុកទេស នឹងតាំងវង្សតាមកម្លាំងខ្លួនបាន ទាល់តែព្រះបាទឱក្កាករាជជាព្រះរាជបិតាលាន់ព្រះឱស្ឋសរសើរថាជាអ្នកអាច ។

២៥–សំ. ក្នុងសក្កជនបទមាននគរប៉ុន្មាន? ឈ្មោះអ្វីខ្លះ?

ឆ. មាននគរ ៣ ។ នគរដើមរបស់ព្រះបាទឱក្កាករាជ ១, នគរកបិលព័ស្តុ ១, នគរទេវទហៈ ១, ។

២៦- ស. ហេតុអ្វីបានជាឲ្យឈ្មោះថា នគរកបិលព័ស្តុ ?

ឆ. ហេតុតែព្រះរាជបុត្រាបុត្រីទៅកសាងនគរថ្មី នៅត្រង់ទីលំនៅនៃកបិលតាបស បានជាសន្មតឈ្មោះនគរដែលកសាងថ្មីនេះ ថា កបិលព័ស្តុ ឲ្យត្រូវនឹងនាមនៃតាបស ។

សាក្យវង្សនិងកោលិយវង្ស

២៧- ស. ចូររៀបរាប់អំពីដើមកំណើតសាក្យវង្ស ឲ្យឃើញថា មានលំដាប់តគ្នាមកដូចម្តេច ?

ឆ. លំដាប់នៃសាក្យវង្សមានដូច្នេះ រាប់ចាប់ដើមអំពីព្រះរាជបុត្រាទាំង ៤ ព្រះអង្គ នឹងព្រះរាជបុត្រ ៤ ព្រះអង្គ ជាបងប្អូនផ្សំផ្គុំគ្នាឯង ជាលំដាប់រហូតមកដល់ព្រះបាទជយសេន ៗ នោះ មានព្រះរាជបុត្រា ១ អង្គ ព្រះនាម "សីហហនុ", មានព្រះរាជបុត្រ ១ ព្រះអង្គ ព្រះនាម "យសោធរា" ។ លុះព្រះបាទជយសេនទិវង្គតហើយ ព្រះសីហហនុកុមារបានសោយរាជសម្បត្តិតព្រះវង្សមក, ទ្រង់មានព្រះមហេសីព្រះនាម "កញ្ចនា" ជាព្រះកនិដ្ឋភគិនីរបស់ព្រះបាទអញ្ជនៈជាក្សត្រក្រុងទេវទហៈ ។ ព្រះបាទសីហហនុនេះមានព្រះរាជបុត្រា ៥ ព្រះអង្គ គឺសុទ្ធោទនៈ ១ សុក្កោទនៈ ១

អមិតោទនៈ១ ធោតោទនៈ១ ឃនិតោទនៈ១ នឹងមានព្រះរាជបុត្រី២ព្រះអង្គ គឺៈ បមិតា ១ អមិតា ១ ។ ឯសុទ្ធោទនកុមារបានសោយរាជ្យតព្រះវង្សមក, មានព្រះមហេសី ព្រះនាម "មាយា" មានព្រះរាជបុត្រា ១ អង្គ ព្រះនាម "សិទ្ធត្ថ" ។ តាំងក្រោយមក កាលព្រះនាងមាយាទិវង្គតទៅ ទ្រង់មានព្រះមហេសីថ្មី ១ ទៀតព្រះនាម "បជាបតី" ឬហៅថា "គោតមី", ជួនកាលហៅព្រះនាមភ្ជាប់គ្នាទាំងពីរថា "បជាបតីគោតមី" ។ កាលទ្រង់បានមហេសីក្រោយនេះ មានព្រះរាជបុត្រា ១ អង្គព្រះនាម "នន្ទ" មានព្រះរាជបុត្រី១ អង្គព្រះនាម "រូបនន្ទា" ។ ព្រះសិទ្ធត្ថមានមហេសីព្រះនាម "យសោធរា" (ឬពិម្ពា), មានព្រះរាជបុត្រ ១ អង្គព្រះនាម "រាហុល" ។

២៨–ស. ចូររៀបរាប់អំពីដើមកំណើតនៃកោលិយវង្សឲ្យឃើញ ថាមានលំដាប់តគ្នាមកដូចម្តេច ?

ឆ. លំដាប់នៃកោលិយវង្សមានដូច្នេះ រាប់ចាប់ដើមអំពីព្រះជេដ្ឋភគិនី ដែលបានរួមរស់រាសជាមួយនឹងព្រះបាទទេវទហៈ ជាលំដាប់មករហូតដល់ព្រះបាទអញ្ជនៈ ៗ នោះ មានព្រះមហេសីព្រះនាម "យសោធរា" មានព្រះរាជបុត្រា២ ព្រះអង្គគឺសុប្បពុទ្ធ១ ទណ្ឌបាណិ១, មានព្រះរាជបុត្រី២ព្រះអង្គគឺមាយា១ បជាបតី (ឬគោតមី) ១ ។

២៩ ស. ហេតុអ្វីបានជាពួកក្សត្រសាក្យវង្សប្រកាន់ខ្លួនខ្លាំងម្ល៉េះ?

ឆ. ហេតុតែត្រកូលរបស់ពួកសាក្យៈជាត្រកូលខ្ពង់ខ្ពស់ ហើយគេគោរពរាប់អានថាមានជាតិដ៏បរិសុទ្ធទាំងខាងបិតាទាំងខាងមាតា ដែលហៅថា ឧភតោសុជាតមិនច្របូកច្របល់នឹងជាតិថោកទាបដែលមហាជនមិនគោរពរាប់អានមានជាតិចណ្ឌាលជាដើម។ ព្រោះហេតុនេះឯងបានជាពួកក្សត្រសាក្យៈ ប្រកាន់ខ្លួនយ៉ាងខ្លាំង ប្រយ័ត្នមិនឲ្យពួកដែលមានជាតិត្រកូលនឹងគោត្រថោកទាបជាងខ្លួនចូលមកច្របូកច្របល់ ដើម្បីរក្សាត្រកូលរបស់ខ្លួនឲ្យបរិសុទ្ធ ជាទីគោរពរាប់អានរបស់មហាជនទៅអស់កាលជាអង្វែង ។

៣០ - ស. ព្រះសាស្តានៃយើងកើតក្នុងវង្សអ្វី? ជាតិអ្វី? ជាតិនោះមានសេចក្តីវិសេសដូចម្តេច?

ឆ. ព្រះអង្គកើតក្នុងវង្សទាំង ២ គឺក្នុងសាក្យវង្សខាងព្រះបិតា, ក្នុងកោលិយវង្សខាងព្រះមាតា ។ ជាជាតិអរិយកៈ ៗ នេះ ជាអ្នកចំរើនដោយចំណេះវិជ្ជានិងទំនៀមទំលាប់ ស្ទាត់ជំនាញខាងការគ្រប់គ្រងស្រុកទេស ព្រមទាំងមានអំណាចច្រើន ។

៣១ - ស. ប្រសិនបើ ព្រះសាស្តានៃយើងមិនកើតក្នុងសាក្យវង្សទេ បែរជាកើតក្នុងត្រកូលថោកទាបជាងនោះទៅវិញ តើនឹងបានផលខុសពីកើតក្នុងសាក្យវង្សដូចម្តេច ?

ឆ. បើព្រះអង្គកើតក្នុងត្រកូលថោកទាបជាងសាក្យវង្ស នឹងបានផលខុសគ្នាយ៉ាងនេះ៖ គឺកាលព្រះអង្គបានត្រាស់ដឹងជាព្រះពុទ្ធហើយ

នឹងយាងទៅប្រកាសព្រះសាសនាឲ្យផ្សាយទូលាយទៅមិនសូវបានផលប្រយោជន៍ ។ ព្រោះថាមនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់រមែងមានទិដ្ឋិមានះប្រកាន់ជាតិត្រកូលរបស់ខ្លួនថាជាធំ, ក្នុងវេលាដែលព្រះអង្គទ្រង់ទូន្មានប្រៀនប្រដៅគេក៏មិនជឿស្តាប់កាន់យកដំបូន្មានរបស់ព្រះអង្គ ព្រោះគេយល់ឃើញថាព្រះអង្គមានជាតិត្រកូលថោកទាបជាងខ្លួនគេ។ ឧទាហរណ៍ដូចក្នុងសម័យសព្វថ្ងៃនេះ សូម្បីមានអ្នកប្រាជ្ញចេះដឹងជ្រៅជ្រះ អាចតែងសៀវភៅឬសំដែងធម៌ទូន្មានគេយ៉ាងល្អ យ៉ាងពីរោះក្បោះក្បាយបាន ប៉ុន្តែអ្នកប្រាជ្ញនោះកើតក្នុងត្រកូលថោកទាប ក៏មិនអាចនឹងទូន្មានមនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់ឲ្យជឿស្តាប់ដោយងាយបានទេ ទូន្មានបានតែមនុស្សមានជាតិត្រកូលស្មើ ៗ នឹងខ្លួនឬទាបជាងខ្លួន ។ ដូច្នេះក៏ល្មមយល់ឃើញថាមនុស្សដែលមានជាតិត្រកូលខ្ពង់ខ្ពស់ រមែងមិនស្រឡាញ់គោរពរាប់អានអ្នកមានជាតិត្រកូលថោកទាបជាងខ្លួនទេ ។

មួយទៀត មនុស្សដែលមានជាតិត្រកូលថោកទាបជាងព្រះអង្គ ប៉ុន្តែជាអ្នកមានសេចក្តីគោរពរាប់អានបុគ្គលអ្នកមានជាតិត្រកូលខ្ពង់ខ្ពស់ ក៏គង់មានសេចក្តីជឿស្តាប់ដំបូន្មានរបស់ព្រះអង្គតែបន្តិចបន្តួច មិនជាហេតុបណ្តុះសទ្ធាជ្រះថ្លារបស់មនុស្សបែបនេះឲ្យដុះដាលឡើងបាន ។ ព្រោះហេតុនោះ ការណ៍ដែលព្រះអង្គកើតក្នុងជាតិត្រកូលខ្ពង់ខ្ពស់ជាទីនិយមរាប់អានរបស់មនុស្សទាំងឡាយ, សាសនារបស់ព្រះអង្គទើបបានចំរើនរីក

សាយកាយ ជាទីនិយមរាប់អានរបស់ជនទូទៅអស់កាលជាយូរអង្វែង ៗ

៣២- ស. ចូររៀបរាប់អំពីវង្សនៃព្រះសាស្តា ឲ្យឃើញថាមានសែស្រឡាយតគ្នាមកដូចម្តេច !

ប. ព្រះសាស្តាជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈនិងព្រះនាងមហាមាយា; ព្រះបាទសុទ្ធោទនៈជាព្រះរាជឱរសរបស់ព្រះបាទសីហហនុ ។ ជាព្រះរាជឱរសរបស់ព្រះបាទជយសេន; មានរឿងរ៉ាវដំណាលថា ព្រះបាទឱក្កាករាជជាដើមព្រះវង្សនៃព្រះសាស្តា ។

៣៣- ស. វង្សនៃព្រះសាស្តាគ្រប់គ្រងនគរណា ?

ប. វង្សខាងព្រះបិតា គ្រប់គ្រងនគរកបិលព័ស្តុ, វង្សខាងព្រះមាតាគ្រប់គ្រងនគរទេវទហៈ ។

ព្រះសាស្តាចុះចាប់បដិសន្ធិ

៣៤- ស. ព្រោះហេតុអ្វីបានជាព្រះសន្តុសិតទេវបុត្រ ច្យុតចាកតុសិតសួគ៌មកចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះមាតា ?

ប. ព្រោះទេវតានិងព្រហ្មទាំងឡាយក្នុង ១ ម៉ឺនលោកធាតុនាំគ្នាចូលទៅអញ្ជើញព្រះអង្គឲ្យចុះមកកើតក្នុងមនុស្សលោក ដើម្បីនឹងត្រាស់ដឹងជាព្រះពុទ្ធ ។

៣៥- ស. ហេតុអ្វីបានជាទេវតានិងព្រហ្មទាំងនោះដឹងថាព្រះសន្តុសិតទេវបុត្រនឹងបានត្រាស់ជាព្រះពុទ្ធ ?

ប. ហេតុតែទេវតានិងព្រហ្មទាំងនោះបានឮពុទ្ធកោលាហលដែលសុទ្ធាវាសមហាព្រហ្មស្រែកប្រកាសឃោសនាប្រាប់ថា "កន្លងទៅមុខ ១ សែនឆ្នាំទៀត ព្រះសព្វញ្ញុពុទ្ធនឹងកើតឡើងក្នុងលោក" ។

៣៦- ស. ចុះកោលាហល(សេចក្តីភ្ញាក់ផ្អើល)នោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ ?

ប. មាន៥យ៉ាង ។ គឺកប្បកោលាហល(ផ្អើលនឹងឆេះកប្ប)១, ពុទ្ធកោលាហល(ផ្អើលនឹងព្រះពុទ្ធត្រាស)១, ចក្កវត្តិកោលាហល,ផ្អើលនឹងស្តេចចក្រពត្តិ)១, មង្គលកោលាហល (ផ្អើលនឹងមង្គល)១, មោនេយ្យកោលាហល (ផ្អើលនឹងមោនេយ្យប្បដិបត្តិ)១ ។

៣៧- ស. ចូរអធិប្បាយអំពីកោលាហលទាំង ៥ យ៉ាងនោះមកឲ្យស្តាប់ផងមើល !

ប. អធិប្បាយថាៈ នៅរវាង ១ សែនឆ្នាំទៅមុខទៀត ភ្លើងនឹងឆេះកប្ប សុទ្ធាវាសមហាព្រហ្មទាំងឡាយបានដឹងហើយ ក៏ចុះមកស្រែកប្រកាសឃោសនា ប្រាប់មនុស្សទូទៅទាំង ១ ម៉ឺនលោកធាតុឲ្យដឹងគ្រប់គ្នា ឲ្យធ្វើបុណ្យទានរក្សាសីល នេះហៅថា កប្បកោលាហល ។

នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងកើតឡើងក្នុងលោក...... នេះហៅថា ពុទ្ធកោលាហល ។ នៅ ១ សែនឆ្នាំទៀត ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក..... នេះហៅថា ចក្កវត្តិកោលាហល ។ នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងទ្រង់សំដែងមង្គល ៣៨ ប្រការ.....នេះ ហៅថា មង្គលកោលាហល ។ នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងទ្រង់សំដែងមោនេយ្យប្បដិបត្តិ.......នេះហៅថា មោនេយ្យកោលាហល ។ ក្នុងកោលាហលមួយៗ សុទ្ធតែមានសុទ្ធាវាសមហាព្រហ្ម ហោះមកស្រែកប្រកាសឃោសនាប្រាប់មហាជនដូច ៗ គ្នា ។

៣៨-សួ. កាលព្រះសន្តុសិតទេវបុត្រដឹកនឹងច្យុតចាកតុសិតសួគ៌នោះ តើមានបុព្វនិមិត្តប៉ុន្មានយ៉ាង កើតឡើងដល់ព្រះអង្គ? គឺអ្វីខ្លះ?

ឆ. មាន ៥ យ៉ាង ។ គឺ ទិព្វបុប្ផា ដែលប្រដាប់ព្រះកាយស្វិតក្រៀម ១, សំពត់ទិព្វដែលទ្រង់នោះមានពណ៌សៅហ្មង ១, ព្រះសេទហូរចេញពីព្រះកច្ឆប្រទេស១, ព្រះសរីរកាយប្រកបដោយអាការចាស់ជរាប្រាកដ ១, មានព្រះទ័យអផ្សុកជាទុក្ខនឿយណាយចាកទេវលោក មិនត្រេកអរនឹងស្ថិតនៅលើអាសនៈជាទិព្វ ១ ។

៣៩-សួ. កាលព្រះសន្តុសិតទេវបុត្រដឹកនឹងច្យុតចាកតុសិតសួគ៌មកកើតក្នុងមនុស្សលោកនោះ តើព្រះអង្គពិចារណាមើលនូវអ្វី? មានប៉ុន្មាន?

ហេតុអ្វីបានជាចាំបាច់ពិចារណាមើលរបស់ទាំងនោះ? ចូរអធិប្បាយមកមើល ។

ឆ. ព្រះអង្គពិចារណាមើលនូវមហាវិលោកនៈទាំង ៥ យ៉ាង គឺ កាល ១ ប្រទេស ១ ទ្វីប ១ ត្រកូល ១ មាតា ១ ។ អធិប្បាយថា: បានជាមហាបុរសពិចារណាមើលនូវកាលនោះ ព្រោះអាស្រ័យហេតុជាធម្មតាថា បើក្នុងកាលណាសត្វមានអាយុច្រើនជាងមួយសែនឆ្នាំឬថយតិចចុះមកពី ១ រយឆ្នាំ កាលនោះព្រះពុទ្ធមិនដែលចុះមកកើតទេ, អាយុមនុស្ស យ៉ាងច្រើនត្រឹម ១ សែនឆ្នាំឬយ៉ាងតិចត្រឹម ១ រយឆ្នាំ ទើបព្រះពុទ្ធចុះមកកើតក្នុងលោក ។ ព្រះអង្គមើលមើលនូវប្រទេសនោះ ដ្បិតថាព្រះពុទ្ធមិនដែលកើតក្នុងបច្ចន្តប្រទេសទេ បុគ្គលទាំងឡាយមានយសច្រើនមានព្រះពុទ្ធជាដើម តែងតែកើតក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ។ ព្រះអង្គមើលមើលនូវត្រកូលនោះ ដ្បិតថាព្រះពុទ្ធមិនដែលកើតក្នុងត្រកូលទាប តែងតែកើតក្នុងត្រកូលពីរ គឺខត្តិយត្រកូល ១ ព្រាហ្មណត្រកូល ១ ។ ព្រះអង្គមើលមើលនូវមាតា ដ្បិតថា ស្ត្រីដែលជាពុទ្ធមាតាមិនមែនជាស្ត្រីឡេះឡោះ មិនមែនជាអ្នកលេងសុរាជាដើម ឯស្ត្រីជាពុទ្ធមាតានោះជាស្ត្រីមានអភិនីហារកសាងមករំពីអតីតភព មានបារមីធំបំពេញគ្រប់ ១ សែនកប្បហើយ ។

៤០-ស. ព្រះសន្តុសិតទេវបុត្រច្យុតចាកតុសិតសួគ៌មកចាប់បដិសន្ធិក្នុងផ្ទៃស្រីណា? ត្រកូលអ្វី? នៅថ្ងៃ ខែ-ឆ្នាំអ្វី? វេលាណា?

ប. ព្រះអង្គចុះចាប់បដិសន្ធិ ក្នុងផ្ទៃនៃព្រះនាងសិរីមហាមាយារាជទេវីអគ្គមហេសីនៃព្រះបាទសិរីសុទ្ធោទនមហារាជក្រុងកបិលពស្តុ ក្នុងសាក្យត្រកូល, នៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មី ខែអាសាឍ ឆ្នាំរកា, វេលាពេលទៀបភ្លឺ ។

៤១-ស. ក្នុងពេលដែលព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ ព្រះមហាមាយាទ្រង់សុបិនដូចម្ដេចខ្លះ?

ប. ព្រះមហាមាយាទ្រង់សុបិនថា មហារាជទាំង៤មកលើកព្រះនាងទាំងសិរីសយនានាំទៅកាន់ព្រៃហេមពាន្ត ដាក់លើមនោសិលាទំហំ ៦០ យោជន៍ ក្រោមដើមរាំងធំ១ដើមកំពស់ ១០០ យោជន៍ ។ ពួកទេវធីតាមកអញ្ជើញព្រះនាងទៅស្រង់ទឹកក្នុងស្រះអនោតត្ត ។ ទៅក្នុងព្រៃនោះមានភ្នំប្រាក់មួយ, មានវិមានមាសមួយ នៅលើភ្នំប្រាក់នោះ, ព្រះនាងផ្ទំក្នុងវិមានមាសនោះ បែរព្រះសិរទៅទិសខាងកើត ។ មានភ្នំមាសមួយ នៅជិតភ្នំប្រាក់នោះ, មានដំរីសមួយចុះអំពីភ្នំមាសនោះមកហើយឡើងទៅលើភ្នំប្រាក់ ប្រមោយកាន់ផ្កាឈូកស បន្លឺកោញ្ចនាទចូលមកក្នុងវិមានមាសដើរ

ប្រទក្សិណព្រះនាង ៣ ជុំហើយ ហាក់បីដូចជាចូលទៅក្នុងឧទរព្រះនាងខាងស្ដាំ ។ ព្រះបរមពោធិសត្វចុះចាប់បដិសន្ធិក្នុងវេលានោះឯង ។

៤២-ស. កាលព្រះបរមពោធិសត្វចុះចាប់បដិសន្ធិនោះ មានកើតបុព្វនិមិត្តប៉ុន្មានប្រការ? គឺអ្វីខ្លះ? ចូររាប់ឲ្យគ្រប់ដោយសេចក្ដីខ្លី ៗ មកមើល!

ប. មានកើតបុព្វនិមិត្ត ៣២ ប្រការ ។ គឺផែនដីកម្រើកញាប់ញ័រហើយមានរស្មីភ្លឺពេញលោកធាតុ១, ក្នុងលោកន្តរមហានរកដែលធ្លាប់តែងងឹតជានិច្ចត្រឡប់ជាភ្លឺ ១, មនុស្សខ្វាក់ភ្នែកត្រឡប់ជាមើលឃើញរូបផ្សេងៗ, មនុស្សថ្លង់ត្រចៀកឮសូរសម្លេង, មនុស្សគនិយាយបាន, មនុស្សខ្ទីងគមបែរជាលាត្រង់បាន, មនុស្សខ្វិនដើររួច ១, សត្វទាំងឡាយដែលត្រូវគេចាប់ចងក្រវាត់ក្នុងខ្នោះឃ្នាងបែរជារួចចេញបាន ១, ភ្លើងក្នុងនរកទាំងឡាយមានអវីចិនរកជាដើមបែរជារលត់១, សេចក្ដីស្រេកឃ្លានក្នុងបេតវិស័យរំងាប់ ១, ទ្វារនិងបង្អួចដែលបិទបើកចេញឯង ១, សំពៅនិងទូកទាំងឡាយដែលលឿនទៅក្នុងទិសផ្សេងៗ ក៏ទៅដល់កំពង់ដែលគេប្រាថ្នានឹងទៅនោះ១, ភ័យនៃសត្វតិរច្ឆានទាំងឡាយមិនមានក្នុងខណៈនោះ១, រោគនៃសត្វទាំងឡាយ រំងាប់១, សត្វដែលមានពៀរនឹងគ្នា មានមេត្តាចិត្តដល់គ្នា១, សត្វទាំងឡាយនិយាយសំដីជាទីស្រឡាញ់ដល់គ្នា១, ហ្វូងសេះទាំងឡាយបន្លឺសម្លេងរកគ្នា១, ហ្វូងដំរី បន្លឺសម្លេងគំគន ១,

ក្បូរគន្ធ៍ទាំងអស់ បន្លឺសូរសម្លេងឡើងឯង ១, គ្រឿងអាភរណៈរបស់ មនុស្សទាំងឡាយ មានពន្លឺភ្លឺឡើងទង្គិចគ្នាបន្លឺសម្លេងប្រាកដ ១, ទិស ទាំងឡាយភ្លឺ ១, ខ្យល់ព្យុះធំ មិនមានបក់ផាត់ ១, ខ្យល់បក់តិច ៗ ល្មម ត្រជាក់ជាសុខដល់សត្វទាំងឡាយ បង្កើតមានឡើង ១, អាកាសមេឃ បណ្ដាលឲ្យភ្លៀងធ្លាក់ ១, ទឹកទំលាយផ្ទៃផែនដីផុះឡើងមកហូរទៅ ក្នុងទីទាំងពួង ១, ហ្វូងសត្វស្លាបទាំងឡាយលែងហើរទៅក្នុងអាកាសចុះ មកដើរក្នុងភូមិភាគ ១, ខ្សែទឹកក្នុងស្ទឹងមិនបានហូរ នៅនឹងថ្កល់ដូចទឹក ក្នុងស្រះ ១, ទឹកប្រៃក្នុងមហាសមុទ្រប្រែជាផ្អែម ១, ផ្កាឈូកមានពណ៌ ៥ ទាំងអស់ កើតមានដេរដាសទៅក្នុងសមុទ្រស្ទឹងនិងផ្ទៃផែនដី ១, ផ្កា ដែលកើតក្នុងទឹកលើគោករីកទាំងអស់ ១, ព្រឹក្សាលតាវល្លិទាំងឡាយ កើតជាផ្កាឈូកចេញតាមដើមនិងមែកនិងទង ១, ឈូកទាំងឡាយសុទ្ធ តែមានដើមទំលាយផែនថ្មផុះឡើងមកមួយកន្លែងមានផ្កា ៧ ៗ គ្រប់ថ្មទាំង អស់ ១, ផ្កាឈូកទាំងឡាយកើតប្រាកដសំយុងចុះមកពីលើអាកាស ១, រុក្ខជាតិទាំងឡាយដែលជាឈើមានផ្កានិងផ្លែ ក៏ផ្កាផ្លែក្នុងខណៈនោះទាំង អស់ ១, ភ្លៀងផ្កាទិព្វមានផ្កាមន្ទារបុស្សជាដើម ធ្លាក់ចុះមកក្នុងទីទាំងពួង ដោយជុំវិញ ១, ក្បូរគន្ធ៍បន្លឺសម្លេងឡើងឯងក្នុងអាកាស ១, របៀបទង់ ជ័យទិព្វមានប្រាកដពេញទូទៅដូចគ្នាទាំងមួយម៉ឺនលោកធាតុ មានពណ៌ នឹងពន្លឺភ្លឺអស្ចារ្យ ១ ត្រូវជាបុព្វនិមិត្ត ៣២ ប្រការដូច្នេះ ។

៤៣ – ស. ព្រាហ្មណ៍ប៉ុន្មាននាក់ ទាយព្រះសុបិននិមិត្តថ្វាយ ព្រះរាជទេវី ? ហើយទាយជាគតិប៉ុន្មានប្រការ ?

ឆ. ព្រាហ្មណ៍ ៦៤ នាក់ទាយព្រះសុបិននិមិត្តថា ព្រះរាជទេវី នឹងមានព្រះរាជបុត្រ ១ នោះមានគតិ ២ ប្រការ គឺ ១ បើនៅជាឃរាវាសនឹង បានជាស្ដេចបរមចក្រពត្តិ, ២- បើចេញទ្រង់ព្រះផ្នួសនឹងបានត្រាស់ជា អង្គព្រះសម្មាសម្ពុទ្ធ ។

៤៤ – ស. កាលព្រះពោធិសត្វគង់នៅក្នុងផ្ទៃព្រះមាតានោះ តើ មានអ្នកណាមកនៅចាំថែរក្សាព្រះគភ៌ខ្លះ ?

ឆ. មានមហារាជទាំង ៤ ក្នុងចក្រវាលនេះ ព្រមទាំងក្នុងចក្រ- វាលឯទៀត កាន់ព្រះខាន់មកនៅចាំរក្សាព្រះពុទ្ធមាតា រហូតដល់គ្រប់ ១០ ខែ ។

៤៥– ស. ព្រះពោធិសត្វគង់នៅក្នុងផ្ទៃព្រះមាតានោះ មាន អាការដូចម្ដេច ?

ឆ. មានអាការដូច្នេះ គឺព្រះអង្គគង់ពែនភ្នែនបែរព្រះភក្ត្រទៅ ខាងផ្ទៃព្រះមាតា, បែរព្រះបង្គនៅខាងព្រះបិដ្ឋិមាតា ។ ព្រះមាតាទត ឃើញព្រះពោធិសត្វគង់ក្នុងគភ៌, ឯព្រះពោធិសត្វទតព្រះមាតាមិនឃើញ ទេ ។

ព្រះសាស្តាប្រសូត

៤៦- ស. ព្រះពោធិសត្វប្រសូតមុនពុទ្ធសករាជប៉ុន្មានឆ្នាំ? នៅថ្ងៃ-ខែ-ឆ្នាំអ្វី? វេលាណា?

ឆ. ព្រះអង្គប្រសូតមុនពុទ្ធសករាជ ៨០ ឆ្នាំ, នៅថ្ងៃសុក្រ, ពេញបូណ៌មីខែពិសាខ, ឆ្នាំច, វេលាជិតថ្ងៃត្រង់ ។

៤៧- ស. ព្រះពោធិសត្វប្រសូតនៅកន្លែងណា? ព្រះមាតាមានអាការដូចម្តេច?

ឆ. ព្រះអង្គប្រសូតនៅព្រៃលុម្ពិនី (ព្រៃសាលព្រឹក្ស) ជាចន្លោះនគរទាំង ២ គឺនគរកបិលពស្តុ នឹងនគរទេវទហៈ ។ ព្រះមាតាទ្រង់ឈរលើកព្រះហស្តម្ខាងតោងមែកសាលព្រឹក្សហើយប្រសូត មិនមែនផ្ទំប្រសូតដូចស្រីដទៃទេ ។

៤៨- ស. ហេតុអ្វីបានជាព្រះពោធិសត្វប្រសូតក្នុងព្រៃដូច្នោះ? ចូរកគោលមកអាងល្មមឲ្យស្តាប់បានផងមើល!

ឆ. ហេតុតែព្រះមាតាប្រាថ្នានឹងស្តេចទៅសួរព្រះមាតាបិតានៃព្រះនាងឯទេវទហនគរ, លុះយាងទៅដល់ព្រៃលុម្ពិនី ក៏ស្រាប់តែប្រឈួនព្រះឧទរ ហើយប្រសូតក្នុងព្រៃនោះឯង ។ មានគោលជាសំអាងមួយទៀតថា: តាមទំនៀមទំលាប់របស់ព្រាហ្មណ៍តែងប្រកាន់ថា កាលបើកិរិយា

មានគភ៌គ្រប់ខែហើយ មិនដែលប្រសូតនៅផ្ទះស្វាមីទេ តែងតែទៅប្រសូតនៅផ្ទះត្រកូលរបស់ខ្លួនវិញ ។

៤៩- ស. កាលព្រះពោធិសត្វប្រសូតរួចហើយ មានសេចក្តីអស្ចារ្យដូចម្តេចខ្លះ?

ឆ. មានសេចក្តីអស្ចារ្យដូច្នេះ គឺមានខ្សែទឹកក្តៅ ១ ខ្សែទឹកត្រជាក់១ ហូរធ្លាក់ពីអាកាសមកលាងជម្រះមន្ទិលគភ៌ ។ មានសុទ្ធាវាសមហាព្រហ្ម ៤ អង្គយកបណ្តាញមាសមកទទួលទ្រព្រះពោធិសត្វ ។ មហារាជទាំង ៤ អង្គទទួលយកពីមហាព្រហ្មទៅទៀត ។ ពួកស្រីស្នំទទួលយកពីមហារាជទៅទៀត ។ ព្រះពោធិសត្វចុះពីដៃស្រីស្នំហើយទ្រង់ឈរលើផែនដីដោយព្រះបាទទាំងពីរ ។ មហាព្រហ្មយកស្វេតច្ឆ័ត្របាំងថ្វាយ ។ សុយាមទេវរាជយកវាលវិជនីមកថ្វាយ ។ ទេវបុត្រ ១ អង្គកាន់កែវ ៧ ប្រការ ។ ទេវបុត្រ ១ អង្គកាន់សុវណ្ណបាទុកា (ស្បែកជើងមាស) ។ ទេវបុត្រ ១ អង្គកាន់គ្រឿងរាជកកុធភ័ណ្ឌ (គ្រឿងសម្រាប់រាជ្យ) ទាំង ៥ ប្រការគឺមកុដ ១ ព្រះខាន់ ១ ស្វេតច្ឆ័ត្រ ១ សុពណ៌បាទុក១ វាលវិជនី ១។ មនុស្សដែលនៅក្នុងទីប្រសូតទាំងអស់គ្នា ក៏បានឃើញសេចក្តីអស្ចារ្យទាំងនោះជាក់ច្បាស់ ។

៥០- ស. កាលព្រះពោធិសត្វប្រសូតរួចហើយចុះពីដៃស្រីស្នំទៅ

ទ្រង់យាងបានប៉ុន្មានជំហាន? មានបន្ទូលថាដូចម្តេចខ្លះ?

ឆ. ទ្រង់យាងទៅបាន ៧ ជំហានហើយឈប់ឈរនៅនឹង រួចបែរព្រះភ័ក្ត្រទៅខាងទិសឧត្តរ, ទ្រង់បន្លឺអាសភិវាចា (សំដីរបស់សប្បុរស) ថា “ខ្លួនយើងជាកំពូលនៃលោក ជាបុគ្គលប្រសើរជាងគេក្នុងលោក ជាច្បងជាងគេទាំងអស់ក្នុងលោក ជាតិនេះជាកំណើតចុងបំផុតរបស់យើង អំណើះតទៅមុខយើងលែងកើតទៀតហើយ” ៕

៥១-ស. កាលដែលព្រះពោធិសត្វប្រសូតមកភ្លាម យាងទៅបាន ៧ ជំហាន ហើយបន្លឺអាសភិវាចាបានយ៉ាងនេះ ជាការចំឡែកពីសាមញ្ញជនណាស់ រឿងនេះគួរឲ្យសន្និដ្ឋានថាដូចម្តេច?

ឆ. គួរឲ្យសន្និដ្ឋានថា ជាការសំដែងសេចក្តីប្រៀបធៀបនឹងបដិបទាក្នុងវេលាដែលព្រះអង្គបានត្រាស់ដឹងហើយ គឺថាការណ៍ដែលពោធិសត្វយាងទៅបាន ៧ ជំហានហើយឈប់ឈរនោះ ជាបុព្វនិមិត្តដល់ការផ្សាយសាសនាឲ្យផ្សាយខ្ចរទៅក្នុងជនបទទាំង ៧ ឬក៏យាងទៅដោយព្រះអង្គឯងក្នុងជនបទទាំង ៧ នោះ ៕ ឯជនបទទាំង ៧ នោះគឺ កាសីរួមនឹងកោសល ១ មគធៈរួមនឹងអង្គៈ ១ សក្កៈ ១ វជ្ជី ១ មល្លៈ ១ វង្សៈ ១ កុរុ ១, ក្រៅពីនេះមានតែជនបទតូច ៗ ដែលត្រូវឡើងជនបទធំ ៗ នោះ ៕ ការណ៍ដែលព្រះពោធិសត្វឈប់ឈរត្រឹមប៉ុណ្ណោះ ជាបុព្វនិមិត្តដល់ការ [illegible]ត្រឹមណោះ ៕ ការណ៍ដែលព្រះពោធិសត្វ

បន្លឺអាសភិវាចាប្រកាសព្រះអង្គថាជាឯកក្នុងលោកនោះ ជាបុព្វនិមិត្តដល់ការទ្រង់សំដែងធម៌ឲ្យមហាជនស្តាប់ ៗ ហើយក៏បានឃើញគុណវិសេសថាព្រះអង្គជាកំពូលនៃអ្នកប្រាជ្ញមែន ៕

៥២-ស. កាលព្រះពោធិសត្វប្រសូតនោះ មានមនុស្សសត្វនឹងរបស់ប៉ុន្មានយ៉ាង កើតក្នុងថ្ងៃជាមួយនឹងព្រះអង្គ?

ឆ. មានមនុស្សសត្វនឹងរបស់ ៧ យ៉ាងគឺព្រះនាងពិម្ពា ១ ព្រះអានន្ទជាបុត្រនៃព្រះបាទសុក្កោទនៈ ១ នាយឆន្នអាមាត្យ ១ កាឡុទាយីអាមាត្យ ១ សេះឈ្មោះកណ្ឋកៈ ១ ដើមពោធិព្រឹក្ស ១ កំណប់ទ្រព្យទាំងបួន ១ ហៅថាសហជាតវត្ថុ ៕

៥៣-ស. ចុះកំណប់ទ្រព្យទាំង ៤ នោះ មានឈ្មោះនឹងទំហំខុសគ្នាដូចម្តេច?

ឆ. ខុសគ្នាដូច្នេះ កំណប់ទ្រព្យ ១ ឈ្មោះសង្ខនិធិ មានសំណុំមាត់មូលជុំវិញ ១ គាវុត ៕ កំណប់ទ្រព្យ ១ ឈ្មោះឯលនិធិ មានវង់មាត់មូលជុំវិញកន្លះយោជន៍ ៕ កំណប់ទ្រព្យ ១ ឈ្មោះឧប្បលនិធិ មានវង់មាត់មូលជុំវិញ ៣ គាវុត ៕ កំណប់ទ្រព្យ ១ ឈ្មោះបុណ្ឌរីកនិធិ មានវង់មាត់ជុំវិញ ១ យោជន៍ ៕ កំណប់ទ្រព្យទាំង ៤ នេះ មានជម្រៅរហូតដល់ទីបំផុតផែនដីដូចគ្នា ៕

៥៤-ស. ក្នុងពេលដែលព្រះពោធិសត្វប្រសូតនោះ មានកើតហេតុអស្ចារ្យប៉ុន្មានប្រការ ?

ឆ. មាន ៣២ ប្រការ គឺមានការញាប់ញ័រផែនដីជាដើម ដូចជាក្នុងពេលដែលព្រះអង្គចុះចាប់បដិសន្ធិដែរ ។

៥៥-ស. ព្រះពោធិសត្វកើតក្នុងជនពួកណា ? ក្នុងជនបទនិងទ្វីបដែនឈ្មោះអ្វី? មានត្រកូលនិងគោត្រដូចម្ដេច ?

ឆ. ព្រះអង្គកើតក្នុងពួកជនជាតិអរិយកៈ, ក្នុងមជ្ឈិមជនបទជម្ពូទ្វីបដែនសក្កៈ, ត្រកូលក្សត្រសាក្យៈ ជាគោតមគោត្រ ជាព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនៈ ព្រះរាជាក្រុងកបិលព័ស្ដុ និងព្រះនាងសិរីមហាមាយារាជទេវី ។

៥៦ ស. មនុស្សក្នុងពួកអរិយកៈវិសេសយ៉ាងណា បានជាគេសរសើរច្រើនម្ល៉េះ? ឬក៏សរសើរដោយសារតែព្រះសាស្ដា កើតក្នុងមនុស្សពួកនោះទេ ? ចូរឆ្លើយឲ្យសមតាមហេតុផល !

ឆ. ជាតិអរិយកៈ ជាពួកអ្នកចំរើនដោយចំណេះវិជ្ជានិងទំនៀមទំលាប់ ប៉ិនប្រសប់ខាងយុទ្ធវិធីនិងការគ្រប់គ្រងស្រុកទេស ហើយមានឫទ្ធិអំណាចច្រើន; មិនមែនគេសរសើរដោយសារតែព្រះសាស្ដាកើតក្នុងវង្សជាតិអរិយកៈនេះទេ ; សូម្បីពីគ្រាមុនដែលព្រះសាស្ដាមិនទាន់កើត គេក៏បានសរសើរថាជាជាតិចំរើនមកហើយដូចជាកាលពួកអរិយកៈរុករានដេញ

ពួកមិលក្ខៈ ជាម្ចាស់ស្រុកដើមឲ្យរត់ចេញអស់ នោះក៏ព្រោះតែគេមានអំណាចនិងស្ទាត់ខាងវិធីចម្បាំង គេបានតាំងជាស្រុកទេសនៅខ្ជាប់ខ្ជួនជារបស់ខ្លួន រហូតមកល្បីកេរ្តិ៍ឈ្មោះថាជាតិអរិយកៈ អាចគ្រប់គ្រងស្រុកទេសព្រមទាំងធ្វើឲ្យកើតសេចក្ដីចំរើនបានច្រើនជាងពួកមិលក្ខៈ ជាម្ចាស់ស្រុកដើម ហេតុនេះបានជាគេសរសើរថាពួកអរិយកៈ វិសេសមែន មិនមែនដោយសារតែព្រះសាស្ដាកើតឡើងក្នុងពួកនោះទេ ។

ទំនាយព្រះលក្ខណៈនៃព្រះសាស្ដា

៥៧-ស. ចូរពណ៌នាអំពីកាឡទេវិលតាបសដែលចូលទៅមើលព្រះមហាបុរស ឲ្យឃើញថាមានសេចក្ដីអស្ចារ្យដូចម្ដេចខ្លះ !

ឆ. ក្នុងវេលាដែលកាឡទេវិលតាបសចូលទៅសុំព្រះរាជបុត្រមើលនោះ ព្រះបាទសិរីសុទ្ធោទនៈទ្រង់បង្គាប់ឲ្យរាជបុរសឲ្យយកព្រះរាជ-បុត្រមកថ្វាយបង្គំតាបស, ប៉ុន្តែក្នុងខណៈដែលរាជបុរសនាំយកមកដល់នោះ បែរជាព្រះបាទទាំងពីរនៃព្រះមហាបុរសទៅប្រតិស្ឋានលើជដាតាបសវិញ ។ ព្រះតាបសឃើញហេតុអស្ចារ្យដូច្នេះ ក៏ក្រោកចាកអាសនៈធ្វើអញ្ជលីទូលព្រះបាទាព្រះមហាសត្វ ។ ព្រះបិតាទតឃើញហើយ ក៏ថ្វាយបង្គំព្រះរាជឱរស ដោយសំគាល់ថាដូចជាមហាព្រហ្ម ។

៥៨-ស. ចុះកាឡទេវិលតាបសទាយព្រះមហាបុរសជាប៉ុន្មានយ៉ាង?

ប. ទាយតែម្យ៉ាងថាៈ ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធ មិនខានឡើយ ។

៥៩-ស. ចុះកាឡទេវិលតាបសប្រាប់អ្នកណា ឲ្យចេញបួសរង់ចាំព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងខាងមុខ ?

ប. ប្រាប់នាឡកកុមារជាក្មួយឲ្យចេញបួស ។ នាឡកកុមារក៏ចេញបួសតាមបណ្តាំតាបស, លុះបានជួបនឹងព្រះសាស្តាក៏បានទទួលប្រ-ព្រឹត្តិមោនេយ្យប្បដិបត្តិអំពីព្រះអង្គ ហើយបានសម្រេចព្រះអរហត្តបរិនិព្វានទៅ ។ ចំណែកកាឡទេវិលតាបសលុះអស់ជីវិតបានទៅកើតក្នុងអរូបភព ។

៦០-ស. ព្រះពោធិសត្វប្រសូតកន្លងមកបានប៉ុន្មានថ្ងៃ ទើបព្រះបិតាឲ្យព្រាហ្មណ៍មកទាយលក្ខណៈថ្វាយ ?

ប. រាប់ពីថ្ងៃប្រសូតបាន ៥ ថ្ងៃ ។

៦១-ស. ចុះព្រាហ្មណ៍ប៉ុន្មាននាក់ជាអ្នកទាយលក្ខណៈ ? ព្រាហ្មណ៍ទាំងនោះឈ្មោះអ្វីខ្លះ ?

ប. ព្រាហ្មណ៍ទាំង ១០៨ នាក់ ប៉ុន្តែទ្រង់ជ្រើសយកតែព្រាហ្មណ៍ដែលចេះដឹងត្រៃវេទស្ទាត់ជាងគេ បាន ៨ នាក់ទុកឲ្យទាយ សល់ពីនេះឲ្យត្រឡប់ទៅផ្ទះខ្លួនវិញ ។ ឯព្រាហ្មណ៍ទាំង ៨ នាក់នោះគឺរាមព្រាហ្មណ៍១

លក្ខណព្រាហ្មណ៍១ យញ្ញព្រាហ្មណ៍១ ធជព្រាហ្មណ៍១ ភោជព្រាហ្មណ៍១ សុទត្តព្រាហ្មណ៍១ សុយាមព្រាហ្មណ៍១ កោណ្ឌញ្ញព្រាហ្មណ៍១ ។

៦២-ស. ចុះបណ្តាព្រាហ្មណ៍ទាំង ៨ នាក់នោះ តើព្រាហ្មណ៍ណាទាយព្រះមហាបុរសថាមានគតិប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ប. ព្រាហ្មណ៍ ៧ នាក់ ខាងដើមលើកម្រាមដៃពីរឡើង ហើយទាយជាគតិ ២ យ៉ាងថា "ព្រះមហាបុរស បើនៅជាឃរាវាសនឹងបានសោយរាជសម្បត្តិជាស្តេចចក្រពត្តិ, បើចេញបួសនឹងបានត្រាស់ជាព្រះពុទ្ធ", ចំណែកកោណ្ឌញ្ញព្រាហ្មណ៍ ដែលក្មេងជាងគេលើកម្រាមដៃតែមួយឡើង ហើយទាយតែម្យ៉ាងថា "ព្រះមហាបុរសនឹងបានត្រាស់ជាព្រះពុទ្ធ ពិតប្រាកដ" ។

៦៣-ស. ព្រះមហាបុរសប្រកបដោយលក្ខណៈប៉ុន្មានប្រការ ? គឺអ្វីខ្លះ ? ចូររាប់ឲ្យគ្រប់មកមើល !

ប. ប្រកបដោយលក្ខណៈ ៣២ ប្រការគឺ១ មានផ្ទៃព្រះបាទទាំងគូរាបស្មើ ។ ២- ត្រង់ផ្ទៃព្រះបាទទាំងគូមានរូបចក្រប្រកបដោយកណ្តាប់កង់នឹងដុំព្រមទាំងកាំមួយពាន់មានចន្លោះស្មើគ្នាគ្រប់អន្លើ ។ ៣- មានព្រះបណ្ហិគឺកែងវែង (បើចែកសរីរប្បទេសត្រង់នោះជា ៤ ភាគ ពីរភាគជា

ចុងព្រះបាទ, មួយភាគជាព្រះបាទ, មួយភាគជាព្រះបណ្ហិ) ។ ៤- មាន ព្រះអង្គុលីគឺម្រាមព្រះហស្ដម្រាមព្រះបាទវែងៗ (ចំណែកម្រាមព្រះហស្ដ ទាំង ២ វែងស្មើគ្នា ម្រាមព្រះបាទទាំង ៥ វែងស្មើគ្នា) ម្រាមទាំងអស់ មូលក្រលូលរៀវល្អដូចដងទៀនសិលាដែលគេលាយប្រេងលុញ) ។ ៥- មានផ្ទៃព្រះហស្ដនិងផ្ទៃព្រះបាទទន់ល្មូន (ដូចជាដុំសំឡីដែលគេ -ខ្ចប់អស់ ១ រយដង) ។ ៦- មានព្រះហស្ដនិងផ្ទៃព្រះបាទប្រទាក់ ដោយក្រឡាដូចជាសំណាញ់ ។ ៧- មានព្រះបាទដូចជារណ្ដែតឡើង ខាងលើហាក់ដូចជាមិនជាប់គ្នានឹងខ្នងព្រះបាទ ។ ៨- មានព្រះជង្ឃគឺ ស្មងវែងមូលក្រលូលស្រដៀងនឹងស្មងសត្វទ្រាយ (គឺនោះលោកស្រ- ដៀងនឹងជង្គើមស្រូវ) ។ ៩- កាលបើទ្រង់ឈរមិនឱនព្រះអង្គចុះ អាច ស្ទាបព្រះជាណុគឺជង្គង់ដោយព្រះហស្ដទាំងពីរបាន ។ ១០- មានព្រះ អង្គាវយវ ដែលគប្បីលាក់ឲ្យកំបាំង ដោយសំពត់ស្ថិតនៅក្នុងស្រោម (ប្រហែលដូចជាអង្គជាតនៃសត្វដំរី ឬគោឈ្មោលជាដើម) ។ ១១- មាន ព្រះឆវិវណ្ណ គឺពណ៌សម្បុរថ្ងៃ (ល្បើងភ្លឺអន្លង់) ដូចជាសម្បុរនៃមាស ។ ១២- មានព្រះឆវី គឺសម្បុរថ្ងៃល្អិតផូរផង់លើងស្រិលរអិលធូលីធ្លាក់ មកត្រូវមិនជាប់ ។ ១៣ មានព្រះលោមាគឺរោមក្នុងរណ្ដៅមួយ ៗ តែ មួយសរសៃ ៗ (គ្រប់រណ្ដៅទាំងអស់) ។ ១៤- មានព្រះលោមា មាន ចុងងើបឡើងលើ (ជាទក្ខិណាវដ្ដវិលពទ្ធពេនទៅខាងស្ដាំ មានសម្បុរខៀវ

ស្រស់ដូចជាផ្កាអញ្ចន់) ។ ១៥- មានព្រះកាយត្រង់ដូចជាកាយព្រហ្ម ។ ១៦- មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌ (ព្រះមំសៈ ៧ អន្លើ នោះគឺ ត្រង់ខ្នងព្រះហស្ដទាំងពីរ, ខ្នងព្រះបាទទាំងពីរ, ព្រះអំសកូដ គឺ ចង្កូយស្មាទាំងពីរ, និងត្រង់ព្រះខន្ធប្បទេសគឺករង់ក, សរីរប្បទេស ទាំង ៧ អន្លើនេះ មានសាច់ពេញកន្ទួលល្អឥតមានឃើញសរសៃតិច តួចឡើយ) ។ ១៧- មានចំណែកកន្លះព្រះកាយខាងដើមស្រដៀង នឹងចំណែកកន្លះកាយនៃរាជសីហ៍ (ត្រង់កន្លែងដែលគួរវែង គួរខ្លី គួរធាត់ គួរស្គម ឬគួររៀវ គួរមូល, ក៏វែង ខ្លី ធាត់ ស្គម ឬរៀវ មូល សមល្អឥតមានគ្លង់) ។ ១៨- មានចន្លោះព្រះប្រិស្ឋ- ប្របទេសពេញបរិបូណ៌ គឺមានខ្នងពេញស្មើឥតមានចន្លោះផតខូងត្រង់ កណ្ដាលឡើយ ។ ១៩- មានទ្រង់ទ្រាយព្រះកាយប្រហែលនឹង បរិមណ្ឌលនៃដើមជ្រៃ គឺមានកាយនឹងព្យាមប្រវែងគ្នា (ដូចជាជ្រៃមាន ប្រវែងដើមនិងមែកមិនលើសមិនខ្វះហួសគ្នាប៉ុន្មាន) ។ ២០- មានព្រះ ខន្ធប្បទេស គឺកមូលសម ។ ២១- មានព្រះប្រសាទគឺសរសៃល្អិត ឆ្មារក្រៃលែងសម្រាប់ទទួលរសអាហារគឺមានសរសៃយ៉ាងឆ្មារល្អិត ៧ ពាន់ ប្រជុំស្រោបត្រង់កសម្រាប់ទទួល នាំរសអាហារឲ្យជ្រួតជ្រាបផ្សព្វផ្សាយ ក្នុងកាយទាំងមូលបានឥតមានទើសទាក់ (សូម្បីអាហារយ៉ាងតូចតិចត្រឹម ប៉ុនគ្រាប់ល្ង១ ក៏អាចជ្រួតជ្រាបសព្វសព៌ាង្គកាយបាន) ។ ២២- មានព្រះ

ហនុគឺចង្កាសណ្ឋានស្រដៀងនឹងចង្ការាជសីហ៍ (ពេញបរិបូណ៌ប្រហែលដូចជាព្រះចន្ទត្រង់ថ្ងៃ ១២ កើត) ។ ២៣- មានព្រះទន្តគឺធ្មេញ ៤០ គត់ ខាងលើ ២០ ខាងក្រោម ២០) ។ ២៤- មានព្រះទន្តរាបស្មើ (មិនប្រជួស ឬប្រពើសខ្ពស់ទាបដូចជាធ្មេញនៃមនុស្សសាមញ្ញពួកខ្លះនោះឡើយ) ។ ២៥- មានព្រះទន្តជិតស្និទ្ធល្អ ។ ២៦- មានព្រះទាឋា គឺព្រះចង្កូម (ទាំង ៤) សស្អាត (ភ្លឺរុងរឿងជាងពន្លឺនៃផ្កាយព្រឹក) ។ ២៧- មានព្រះជិវ្ហាគឺអណ្តាតល្មមវៃ (វែងជាងអណ្តាតនៃមនុស្សទាំងអស់ក្នុងលោក) ។ ២៨- មានព្រះសូរសៀងគឺសូរស័ព្ទសម្លេងក្រាំងក្រអៅដូចជាសម្លេងនៃព្រហ្ម; កាលបើបញ្ចេញវាចាលាន់ឮពីរោះដូចជាសម្លេងនៃសត្វករវិក ។ ២៩- មានព្រះនេត្រខៀវស្រស់ (ត្រង់កន្លែងដែលគួរខៀវ ក៏ខៀវស្រស់ដូចផ្កាត្រកៀតឬផ្កាកណ្តៀង, ត្រង់កន្លែងដែលគួរលឿង ក៏លឿងស្រស់ដូចផ្កាកណ្ណិការ, ត្រង់កន្លែងដែលគួរក្រហម ក៏ក្រហមស្រស់ដូចផ្កាចប្ការ, ត្រង់កន្លែងដែលគួរស ក៏សថ្លាត្រចះដូចផ្កាយព្រឹក, ត្រង់កន្លែងដែលគួរខ្មៅក៏ខ្មៅស្រស់ដូចផ្លែផ្គាំ) ។ ៣០- មានដួងព្រះនេត្រស្រដៀងនឹងដួងភ្នែកនៃគោ គឺមានដួងព្រះនេត្រទាំងពីរថ្លាយង់ ស្រដៀងនឹងដួងភ្នែកនៃកូនគោសម្បុរក្រហមដែលទើបនឹងសម្រាលមួយរំពេចនោះ ។ ៣១- មានព្រះឧណ្ណាលោម គឺរោមដុះត្រង់ចន្លោះព្រះភមូ (ចិញ្ចើម), មានសម្បុរសក្បុសទន់ល្មន់ដូចជាសំឡី ។ ៣២- មានព្រះសិរហាក់ដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ (រុងរឿង

ដូចជាព្រះមហាក្សត្រដែលទ្រង់នូវក្បាំងព្រះភ័ក្ត្រ); មានន័យមួយទៀតថា មានព្រះសិរមូលបរិបូណ៌ល្អដូចជាមកុដ, ឬមូលហាក់ដូចជាវត្ថុដែលគេក្រឡឹងហើយយកមកដំកល់, ពុំនោះសោត មូលហាក់ដូចជាពពុះទឹកដែលប៉ោងឡើង ។

៦៤- សំ. ព្រះមហាបុរសប្រកបដោយអនុព្យញ្ជនៈប៉ុន្មានប្រការ? គឺអ្វីខ្លះ? ចូររាប់ឲ្យគ្រប់មកមើល !

ច. អនុព្យញ្ជនៈ ៨០ ប្រការគឺ ១- ម្រាមព្រះហស្តនិងម្រាមព្រះបាទលឿង ។ ២- ម្រាមព្រះហស្តនិងម្រាមព្រះបាទខៀវ ។ ៣- ម្រាមព្រះហស្តនិងម្រាមព្រះបាទមូល ។ ៤- ព្រះនខា (ក្រចក) ទាំង ២០ មានពណ៌ក្រហម ។ ៥- ព្រះនខាទាំង ២០ នោះងស្មឹកឡើងលើ ។ ៦- ព្រះនខានោះមានពណ៌រលោងរលើប ។ ៧- កព្រះហស្តនិងព្រះបាទក្រួកនៅក្នុងព្រះមំសៈ ។ ៨- ព្រះបាទទាំងគូស្មើគ្នា ។ ៩- ព្រះអាការដំណើរល្អដូចជាដំណើរនៃកុញ្ជរជាតិ ។ ១០- ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍ ។ ១១- ព្រះដំណើរល្អដូចជាដំណើរនៃហង្ស ។ ១២- ព្រះដំណើរល្អដូចជាដំណើរនៃគោឧសភរាជ ។ ១៣- កាលទ្រង់ឈរនិងយាងទៅនោះ ទ្រង់លើកព្រះបាទខាងស្តាំឈានទៅមុន ។ ១៤- ព្រះជាណុមណ្ឌល (ជង្គង់) មូលល្អបរិបូណ៌ ។ ១៥- មានបុរិសព្យញ្ជនៈ បរិបូណ៌គឺមិនមានកិរិយាមារយាទស្រដៀងនឹងស្ត្រី ។ ១៦- ព្រះនាភី (ផ្ចិត) មិនខូងផត

[illegible]ប្រមូលល្អ ។ ១៧ ព្រះឧទរ (ពោះ) មានសណ្ឋានជ្រៅ ។ ១៨-ព្រះឧទរមានស្នាមខ្សៀវិលជាទក្ខិណាវដ្ដ ។ ១៩-ព្រះឧរូ (ភ្លៅ) ទាំងគូមូលល្អ ។ ២០-ព្រះហស្ដទាំងគូល្អ ។ ២១-ព្រះអង្គាវយវៈ ធំតូចទាំងពួងមានចំណែកដ៏ល្អ ។ ២២-ព្រះមំសៈដែលគួរក្រាស់ក៏ក្រាស់ ។ ២៣-ព្រះមំសៈមិនជ្រួញជ្រីវ ។ ២៤-ព្រះសរីរកាយទាំងអស់ ប្រាសចាកអាចម៍រុយនិងពព្រុយ ។ ២៥-ព្រះកាយល្អបរិសុទ្ធសមគួរដោយលំដាប់ទាំងខាងលើខាងក្រោម ។ ២៦-ព្រះកាយបរិសុទ្ធទាំងអស់ប្រាសចាកមន្ទិលទាំងពួង ។ ២៧-មានកម្លាំងច្រើន ។ ២៨-មានព្រះនាសិក (ច្រមុះ) ខ្ពស់ ។ ២៩-សណ្ឋានព្រះនាសិកល្អ ។ ៣០-បបូរព្រះឱស្ឋខាងក្រោមមិនបានចូលចេញជាន់គ្នា ត្រឹមស្មើគ្នាល្អ ។ ៣១-ព្រះទន្តបរិសុទ្ធប្រាសចាកមន្ទិល ។ ៣២-ព្រះទន្តសដូចសម្បុរស័ង្ខ ។ ៣៣-ព្រះទន្តរលីងស្អាតមិនគគ្រាត ។ ៣៤-ព្រះឥន្ទ្រិយទាំង ៥ ល្អបរិសុទ្ធ ។ ៣៥-ព្រះចង្កូមទាំង ៤ មូល[illegible]រិបូណ៌ ។ ៣៦-វង់ព្រះភក្ត្រមានសណ្ឋានវែងសមល្អ ។ ៣៧-ព្រះប្រាង្គ (ថ្ពាល់) ទាំងគូក៏ថ្វាល្អស្មើគ្នា ។ ៣៨-អញ្ចាញព្រះហស្ដមានស្នាមជ្រៅ ។ ៣៩-អញ្ចាញព្រះហស្ដមានស្នាមវែង ។ ៤០-អញ្ចាញព្រះហស្ដមានស្នាមត្រង់ ។ ៤១-អញ្ចាញព្រះហស្ដមានស្នាមក្រហមរុងរឿង ។ ៤២-ស្មើព្រះកាយខុកាស (គ្វី) ជាបរិមណ្ឌល ។ ៤៣-ព្រះប្រាង្គ (ថ្ពាល់) ទាំងគូពេញក៏ពុងរីណែនល្អបរិបូណ៌ ។ ៤៤-ស្របកព្រះ

នេត្រទូលាយវែងល្អសមគួរ ។ ៤៥-ព្រះនេត្រប្រកបដោយប្រសាទទាំង ៥ មានសជាដើមថ្លាស្អាតបរិសុទ្ធទាំងអស់ ។ ៤៦-ចុងសរសៃព្រះលោមាទាំងឡាយមិនបានវៀចវង ។ ៤៧-ព្រះជិវ្ហាមានសណ្ឋានដ៏ល្អ ។ ៤៨-ព្រះជិវ្ហាទន់មិនរឹង ។ ៤៩-ព្រះថនៈ (ដោះ) ទាំងគូមានសណ្ឋានវែងដូចជាក្របកបទុមជាតិ ។ ៥០-រន្ធព្រះកមានសណ្ឋានមូលល្អ ។ ៥១-របៀបសរសៃទាំងពួងស្លូតល្អមិនបានជ្រួញជ្រីវ ។ ៥២-ផ្លូវសរសៃទាំងឡាយគ្រួតនៅក្នុងព្រះមំសៈទាំងអស់ ។ ៥៣-ព្រះសិរមានសណ្ឋានល្អដូចឆត្រកែវ ។ ៥៤-បរិមណ្ឌលព្រះនលាដៈ (ថ្ងាស) ទូលាយវែងល្មមសមគួរ ។ ៥៥-ព្រះនលាដៈមានសណ្ឋានដ៏ល្អ ។ ៥៦-ព្រះភមូ (ចិញ្ចើម) មានសណ្ឋានដ៏ល្អដូចជធ្នូដ៏កោង ។ ៥៧-ព្រះលោមាក្រង់ព្រះភមូមានសរសៃដ៏ល្អិត ។ ៥៨-សរសៃព្រះលោមាក្រង់ព្រះភមូដុះឡើងហើយដួលពបទៅដោយលំដាប់ ។ ៥៩-ព្រះភមូនោះធំ ។ ៦០-ព្រះភមូនោះវែងផុតចុងព្រះនេត្រ ។ ៦១-ព្រះឆវិវណ្ណល្អិតឆ្មារពេញព្រះកាយ ។ ៦២-ព្រះសរីរកាយរុងរឿងទៅដោយសិរី ។ ៦៣-ព្រះសរីរកាយមិនរាប់សៅហ្មង់តែងភ្លឺថ្លាជានិច្ច ។ ៦៤-ព្រះសរីរកាយស្រស់ថ្លាដូចផ្កាបទុមជាតិ ។ ៦៥-ព្រះសរីរកាយមានសម្ផស្សទន់ភ្លន់ ។ ៦៦-ក្លិនព្រះសរីរកាយក្រអូបឈ្ងុយដូចសុគន្ធជាតិ ។ ៦៧-ព្រះលោមា មានសរសៃស្មើគ្នាទាំងអស់ ។ ៦៨-ព្រះលោមាមានសរសៃល្អិតឆ្មារ ។ ៦៩- មាន

ខ្យល់អស្សាសបស្សាសៈដ៏ល្អិត ។ ៧០- ព្រះឧស្នាមានសណ្ឋានល្អដូចផាញញឹមញញែម ។ ៧១- ក្លិនព្រះឧស្នាដូចជាក្លិនផ្កាឧប្បល ។ ៧២- ព្រះកេសាខ្មៅរលោងស្រិល ។ ៧៣- ក្លិនព្រះកេសាក្រអូបឈ្ងុយ ។ ៧៤- ព្រះកេសាមានក្លិនដូចជាផ្កាកោមល (ផ្កាឈូក) ។ ៧៥- ព្រះកេសាមានសណ្ឋានមូល ។ ៧៦- ព្រះកេសាខ្មៅស្និទ្ធ ។ ៧៧- សរសៃព្រះកេសាឆ្មារល្អិត ។ ៧៨- សរសៃព្រះកេសាស្លូតមិនក្រញាញ់ ។ ៧៩- សរសៃព្រះកេសារិលជាទក្ខិណាវដ្ត ។ ៨០- ល្អដោយព្រះរស្មីភ្លឺផ្ទុះលើព្រះសិរ ។

៦៥- សំ. ព្រះមហាបុរសប្រកបដោយមង្គលប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូររាប់ឲ្យគ្រប់មកមើល !

ឆ្លើ. ព្រះមហាបុរសមានផ្ទៃបាតព្រះបាទទាំងគូប្រកបដោយលាយលក្ខណ៍កង់ចក្រមួយម្ខាង នៅត្រង់ពាក់កណ្តាលបាតព្រះបាទ ។ ឯកង់ចក្រនោះមានកាំ ១ ពាន់ប្រកបដោយកង់និងដុំ បរិបូណ៌ដោយអាការទាំងពួង ខាងក្រៅជុំវិញកង់ចក្រនោះប្រដាប់ទៅដោយរូបមង្គល ១០៨ យ៉ាងគឺ៖ រូបលំពែង ១ រូបកញ្ចក់ឆ្លុះរូប ១ រូបផ្កាឡូនស្រី ១ រូបខ្សែសយ ១ រូបសង្វារ ១ រូបថាសមាស១ រូបជើងតាំង១ រូបមច្ឆាទាំងគូ១ រូបប្រាសាទ១ រូបកង្វេរ១ រូបសសរខឿន១ រូបស្វេតច្ឆត្រ១ រូបព្រះខាន់១ រូបផ្លិតស្លឹកត្នោត១ រូបផ្លិតកន្ទុយក្ងោក១ រូបផ្លិតវាលវិជនី១ រូបមកុដ១ រូបបាត្រ១ រូបកម្រងផ្កាម្លិះ១ រូបផ្កាឧប្បលខៀវ១ រូបផ្កាឧប្បលស១ រូបផ្កាឧប្បល

ក្រហម១ រូបផ្កាឈូកក្រហម១ រូបផ្កាឈូកស១ រូបឆ្នាំងពេញដោយទឹក១ រូបថាសពេញដោយទឹក១ រូបមហាសមុទ្រទាំងបួន១ រូបភ្នំចក្រវាឡ ១ រូបព្រៃហិមពាន្ត ១ រូបភ្នំសិនេរុ ១ រូបព្រះច័ន្ទ ១ រូបព្រះអាទិត្យ១ រូបពួកផ្កាយនក្ខត្តឫក្ស១ រូបទ្វីបធំទាំងបួន១ រូបទ្វីបតូចទាំងពាន់១ រូបស្តេចបរមចក្រពត្តិព្រមទាំងរាជបរិវារ១ រូបស័ង្ខទក្ខិណាវដ្ត១ រូបសុវណ្ណមច្ឆា១ រូបច័ក្រទាំងគូ១ រូបស្ទឹងទាំងប្រាំពីរ១ រូបស្រះធំទាំងប្រាំពីរ១ រូបភ្នំបរិភ័ណ្ឌទាំងប្រាំពីរ១ រូបស្តេចគ្រុឌ១ រូបក្រពើ១ រូបទង់ជ័យទង់សំពត់ទាំងផ្នត់១ រូបគេនបល្ល័ង្ក១ រូបកៅអី១ រូបភ្នំកៃលាស១ រូបរាជសីហ៍១ រូបព្យគ្ឃរាជ១ រូបដំរីឯករ័ណ១ រូបស្តេចវលាហក១ រូបព្រះបាទវាសុកីនាគរាជ១ រូបស្តេចហង្ស១ រូបមាន់ព្រៃ១ រូបគោឧសភរាជ១ រូបស្តេចដំរីឧបោសថ១ រូបស្តេចដំរីឆទ្ទន្ត១ រូបមករមាស ១ រូបមហាព្រហ្មមុខបួន១ រូបផ្ទះមាស ១ រូបអណ្តើកមាស១ រូបមេគោព្រមទាំងកូន១ រូបកិន្នរឈ្មោល១ រូបកិន្នរី១ រូបសត្វករវិក១ រូបសត្វក្រៀល១ រូបសត្វក្ងោក១ រូបសត្វចាក្រពាក១ រូបស្តេចសត្វក្រលិត១ រូបឆកាមាវចរទេវលោកទាំង ៦ជាន់ ១ រូបសោឡសមហាព្រហ្មទាំង ១៦ ជាន់១ ត្រូវជារូបមង្គល ១០៨

ប្រការជាបរិវារ តាមគេបកថាចក្រធំត្រង់កណ្ដាលបាតព្រះបាទទាំងគូឆ្វេងស្ដាំដូចគ្នា ។(១)

៦៦- ស. មហាបុរិសលក្ខណៈ ៣២ ប្រការក្ដី អនុព្យញ្ជនៈ ៨០ ប្រការក្ដី រូបមង្គល ១០៨ ក្ដី មានចំពោះតែព្រះសាស្ដានៃយើងមួយព្រះអង្គប៉ុណ្ណោះទេឬ ឬក៏ព្រះពុទ្ធទាំងឡាយមានដូចគ្នាដែរ?

ឆ. មានដូចគ្នាគ្រប់ព្រះអង្គទាំងអស់ ។

៦៧- ស. ការសរសើរលក្ខណៈព្រះកាយនៃព្រះមហាបុរស ទាល់តែជាហេតុឲ្យមានពាក្យទំនាយ ២ យ៉ាងនោះ តើមានប្រយោជន៍ដូចម្ដេច?

ឆ. សេចក្ដីក្រាស់ជីងមិនមែនជាប់ជំពាក់នឹងរូបកាយក៏ពិតមែនហើយ ប៉ុន្តែគុណធម៌សេចក្ដីល្អរបស់មនុស្សដោយច្រើន ៗ តែមានក្នុងសន្តាននៃអ្នកមានរូបកាយ ដែលនាំឲ្យកើតសេចក្ដីស្រឡាញ់រាប់អាន មិនសូវមានក្នុងសន្តាននៃមនុស្សអ្នកមានរូបកាយមិនសមរម្យទេ ; ការមានរូបកាយប្រកបដោយលក្ខណៈដ៏ល្អនោះ រមែងនាំឲ្យកើតសេចក្ដីជ្រះថ្លារបស់ពួកជនអ្នកធ្ងន់ក្នុងរូប ដែលហៅថា រូបប្បមាណិកា ជាហេតុនាំ

១- ក្នុងមាតិកាប្រាប់ថាមង្គលមាន ១០៨ ប៉ុន្តែរាប់មើលទៅឃើញតែត្រឹម ៧២ យ៉ាងប៉ុណ្ណោះ ស្វែងរកក្នុងច្បាប់ផ្សេង ៗ ក៏មិនឃើញលើសពីនេះទៀត មិនដឹងជាលោករាប់ចំនួនយ៉ាងណា សូមលោកអ្នកអានជួយរិះរកផងចុះ ។

ឲ្យមនុស្សពួកដទៃទៀតកើតសេចក្ដីជ្រះថ្លាជាខាងដើម ; ការសរសើរលក្ខណៈនៃព្រះកាយមានប្រយោជន៍ក្នុងការបង្ហាញឲ្យឃើញថា ជាភាជនៈដែលគួរទទួលរាប់រងព្រះពោធិញ្ញាណ ទាំងនាំឲ្យកើតសេចក្ដីជ្រះថ្លាក្នុងខាងដើមយ៉ាងនេះឯង ។ ព្រះជាតិទទួលរាប់រងព្រះពោធិញ្ញាណបានដូចម្ដេច ព្រះកាយដ៏ប្រកបដោយព្រះលក្ខណៈ ក៏ទទួលរាប់រងព្រះពោធិញ្ញាណបានដូច្នោះដែរ ហេតុនោះបានជាលោកសរសើរទុកមក ។

រាជាភិសេក

៦៨- ស. ព្រះមហាបុរសមានព្រះនាមថាអ្វីខ្លះ? ហេតុអ្វីបានជាគេថ្វាយព្រះនាមដូច្នោះដែរ ?

ឆ. ព្រះអង្គមានព្រះនាមថា "អង្គីរស" ព្រោះហេតុមានព្រះរស្មីភ្លឺចេញពីព្រះសរីរកាយ ។ មានព្រះនាមម្យ៉ាងទៀតថា "សិទ្ធត្ថ" ព្រោះហេតុព្រះអង្គជាអ្នកធ្វើឲ្យសម្រេចប្រយោជន៍ដល់សត្វលោកទាំងពួង ខាងក្រោយមក មានព្រះនាមម្យ៉ាងទៀតថា "គោតម" ដោយអំណាចគោត្រ ។

៦៩- ស. ហេតុដូចម្ដេចបានជាព្រះបាទសុទ្ធោទនៈបង្គាប់ឲ្យរក្សាព្រះរាជឱរសយ៉ាងម៉ាំមួនម្ល៉េះ ?

ឆ. ហេតុតែព្រះអង្គទ្រង់ជ្រាបដោយសារពួកព្រាហ្មណ៍ក្រាប

ទូលថា ព្រះរាជកុមារនឹងចេញទ្រង់ព្រះផ្នួស ព្រោះបានឃើញទេវទូតទាំង ៤ គឺមនុស្សចាស់ជរា១ មនុស្សឈឺ១ មនុស្សស្លាប់១ អ្នកបួស ១ ទើបទ្រង់ត្រាស់ហាមប្រាមមិនឲ្យមនុស្សទាំង ៤ ពួកនេះ ទៅជិតព្រះរាជបុត្រសោះ ។

៧០– ស. ចូរពិចារណាមើល ! បើព្រះសាស្តានៃយើងសោយរាជសម្បត្តិជាស្តេចចក្រពត្តិ ហើយនឹងធ្វើជាព្រះសាស្តាឯកក្នុងលោក តើណាមានប្រយោជន៍ច្រើនជាងណា ? កាលបើដូច្នោះ ហេតុអ្វីក៏ព្រះបិតាហាមឃាត់ទាំងទុកឲ្យនៅក្នុងកាមសុខវិញ ?

ឆ. ការសោយរាជ្យជាស្តេចចក្រពត្តិដែលមានសមុទ្រធំទាំង៤ជាអាណាខេត្ត នឹងធ្វើប្រយោជន៍ដល់មហាជនក្នុងទ្វីបនោះៗ បានតែត្រឹមសម្បត្តិមនុស្សនឹងសម្បត្តិសួគ៌ ដែលរាប់ថាជាលោកិយសុខប៉ុណ្ណោះ ។ ចំណែកធ្វើជាព្រះសាស្តាឯកក្នុងលោក នឹងបានយាងទៅទេសនាប្រោសសត្វឲ្យបានសម្រេចសម្បត្តិទាំងបី គឺសម្បត្តិមនុស្ស, សម្បត្តិសួគ៌ និងសម្បត្តិព្រះនិព្វាន តាមឧបនិស្ស័យ ដែលរាប់ថាជាលោកុត្តរសុខ ដ៏ខ្ពង់ខ្ពស់ជាងលោកិយសុខ ។ ប៉ុន្តែព្រះញាតិវង្សមានព្រះរាជបិតាជាដើម ប្រាថ្នានឹងឲ្យរាជឱរសគ្រងរាជសន្តតិវង្ស ទាំងមិនទ្រង់ជ្រាបថា ការដែលបានត្រាស់ជាព្រះពុទ្ធធ្វើជាព្រះសាស្តាឯកក្នុងលោកនោះ នឹងប្រព្រឹត្តទៅ

ដើម្បីប្រយោជន៍នឹងសេចក្តីសុខខ្ពង់ខ្ពស់ត្រឹមណាផង ហេតុនោះបានជាខំការពារមិនឲ្យព្រះរាជឱរសចេញទ្រង់ព្រះផ្នួស ។

៧១– ស. ព្រាហ្មណ៍ទាំង ៨ នាក់ដែលទាយលក្ខណៈថ្វាយព្រះមហាបុរស តើប៉ុន្មាននាក់ស្លាប់មុនទៅ ? ប៉ុន្មាននាក់នៅរស់ទាន់ព្រះអង្គ ?

ឆ. ព្រាហ្មណ៍ ៧ នាក់ខាងដើម (ចូរមើលប្រស្នាលេខ៦១) ស្លាប់ទៅមុនព្រះមហាបុរសបានត្រាស់ដឹង ប៉ុន្តែបានផ្តាំកូនគ្រប់គ្នាថា ឲ្យចេញបួសតាមព្រះសាស្តា ។ ចំណែកកោណ្ឌញ្ញព្រាហ្មណ៍នៅរស់ ចេញបួស បានជួបនឹងព្រះសាស្តា ។

៧២– ស. ព្រះញាតិវង្សនៃព្រះមហាបុរសមានចំនួនប៉ុន្មាន ? បានគោរពរាប់អានព្រះមហាបុរសដែរឬទេ ?

ឆ. ព្រះញាតិវង្សខាងព្រះមាតាចំនួន ៨០ ពាន់, ខាងព្រះបិតា ៨០ ពាន់ រួមជា ១៦០,០០០ព្រះអង្គ ។ បានគោរពរាប់អានព្រះមហាបុរសទាំងអស់អង្គ បានថ្វាយបុត្រមួយៗម្នាក់ ឲ្យធ្វើជាបរិវារនៃព្រះមហាបុរស ។

៧៣– ស. ព្រះនាងសិរីមហាមាយាប្រសូតព្រះមហាបុរស កន្លងមកបានប៉ុន្មានថ្ងៃទើបទិវង្គត ? ទិវង្គតហើយបានទៅកើតនៅស្ថានណា ? ទិវង្គតដោយហេតុអ្វី ?

ឆ. រាប់ពីថ្ងៃប្រសូតមកបាន ៧ ថ្ងៃ ។ បានទៅកើតក្នុងតុសិតស្ហួគ៌ ។ ដោយហេតុព្រះនាងអស់ព្រះជន្មត្រឹមប៉ុណ្ណោះ មិនមែនដោយហេតុដែលប្រសូតព្រះមហាបុរសទេ ។

៧៤-ស. ចុះព្រះនាងណាទទួលថែរក្សាបំបៅព្រះមហាបុរសតមកទៀត ?

ឆ. ព្រះបាទសុទ្ធោទនៈទ្រង់លើកព្រះនាងបជាបតិគោតមី ជាព្រះកនិដ្ឋភគិនីនៃព្រះនាងមហាមាយា ជាព្រះអគ្គមហេសីថែរក្សាព្រះមហាបុរសតមក ។

៧៥-ស. ព្រះមហាបុរសមានបងប្អូនរួមឧទរជាមួយដែរឬទេ ?

ឆ. គ្មានទេ ។ មានតែរួមបិតាជាមួយ គឺព្រះនន្ទកុមារ ១ ព្រះនាងរូបនន្ទា ១ ដែលប្រសូតអំពីព្រះនាងបជាបតិគោតមី ។ ព្រះនន្ទកុមារប្អូនព្រះមហាបុរសពីរបីថ្ងៃប៉ុណ្ណោះ ។

៧៦-ស. កាលព្រះមហាបុរសនៅជាព្រះកុមារ បានសម្រេចគុណវិសេសអ្វីដែរឬទេ ? ក្នុងព្រះជន្មប៉ុន្មាន ? មានរឿងរ៉ាវដូចម្ដេច ?

ឆ. ព្រះមហាបុរសបានសម្រេចបឋមជ្ឈាន ។ ក្នុងព្រះជន្មាយុ ៧ ខែ ។ មានរឿងដំណាលថា ថ្ងៃមួយព្រះបាទសុទ្ធោទនៈស្ដេចចេញច្រត់ព្រះនង្គ័ល បានឲ្យអញ្ជើញព្រះមហាបុរសទៅផង ឲ្យផ្ទុំក្រោមដើម

ព្រីងធំ, ស្រីស្នំនឹងបរិវារចេញទៅមើលពិធីច្រត់ព្រះនង្គ័លអស់ ចោលព្រះមហាបុរសឲ្យផ្ទុំនៅតែ ១ អង្គឯង ។ គ្រានោះព្រះមហាបុរសមានសេចក្ដីស្ងាត់ព្រះកាយស្ងាត់ព្រះទ័យ ទ្រង់គង់ពែនភ្នែនតាំងសមាធិ កំណត់ខ្យល់អស្សាសបស្សាសៈជាអារម្មណ៍ គឺចំរើនអានាបានស្សតិកម្មដ្ឋាន ក៏បានសម្រេចបឋមជ្ឈាន មានវិតក្ក, វិចារ, បីតិ, សុខ កើតអំពីវិវេក ចាត់ជាអភិសម្ពោធិនិមិត្តជាគ្រាដំបូង ។ ព្រះរាជាយាងមកថ្វាយបង្គំព្រះរាជបុត្រម្ដងទៀត ជាគំរប់ ២ ដង ។

៧៧-ស. កាលព្រះមហាបុរសមានព្រះជន្មាយុប៉ុន្មានឆ្នាំ ទើបព្រះបិតាឲ្យជីកស្រះបោក្ខរណីថ្វាយ ?

ឆ. កាលព្រះអង្គមានជន្មាយុ ៧ ឆ្នាំ ព្រះវេស្សកម្មទេវបុត្រចុះមកនិម្មិតស្រះបោក្ខរណីប្រកបដោយកែវ ៧ ប្រការថ្វាយ ។

៧៨-ស. ព្រះមហាបុរសមានព្រះជន្មប៉ុន្មានឆ្នាំ ព្រះបិតាឲ្យសាងប្រាសាទប៉ុន្មានថ្វាយ ? ឈ្មោះប្រាសាទអ្វីខ្លះ ?

ឆ. ព្រះមហាបុរសមានព្រះជន្ម ១៦ ឆ្នាំ ព្រះបិតាឲ្យសាងប្រាសាទ ៣ ថ្វាយ ។ គឺឈ្មោះចន្ទប្រាសាទ១, កោកនទប្រាសាទ១, កោញ្ចប្រាសាទ១ ដើម្បីឲ្យព្រះអង្គគង់ក្នុងរដូវទាំងបី ។

៧៩-ស. ព្រះមហាបុរសបានសោយរាជសម្បត្តិក្នុងព្រះជន្មប៉ុន្មាន ? នៅថ្ងៃ ខែ-ឆ្នាំអ្វី ? ស្ត្រីណាបានធ្វើជាព្រះអគ្គមហេសីនៃព្រះមហាបុរស ?

ឆ. ក្នុងព្រះជន្ម ១៦ ឆ្នាំ ។ នៅថ្ងៃសៅរ៍, ពេញបូណ៌មីខែពិសាខ, ឆ្នាំឆ្លូវ មុនពុទ្ធសករាជ ៦៤ ឆ្នាំ ។ ព្រះនាងយសោធរា (ពិម្ពា) ព្រះរាជធីតានៃព្រះបាទសុប្បពុទ្ធ ក្នុងក្រុងទេវទហៈ ដែលប្រសូតអំពីព្រះនាងអមិតាជាព្រះកនិដ្ឋភគិនីនៃព្រះបាទសុទ្ធោទនៈ មកធ្វើជាព្រះអគ្គមហេសី ។

ព្រះសាស្តាចេញទ្រង់ព្រះផ្នួស

៨០ – ស. ព្រះគន្ថរចនាចារ្យពណ៌នាអំពីការសោយកាមសុខរបស់ព្រះមហាបុរសថាជាការអស្ចារ្យណាស់ តើដើម្បីប្រាថ្នាប្រយោជន៍ដូចម្តេច ?

ឆ. ដើម្បីសំដែងឲ្យឃើញថា សូម្បីព្រះអង្គបានទទួលសេចក្តីសុខដូច្នោះដែលមនុស្សរាប់អានប្រកាន់ថាជារបស់ល្អ ព្រះអង្គក៏អាចលះបង់ចោលបាន គ្មានសេចក្តីត្រេកអរអាឡោះអាល័យសោះ ព្រមទាំងដើម្បីនឹងឲ្យបុគ្គលដែលមានសេចក្តីស្រវឹងក្នុងកាមសុខសម្បត្តិនឹងសរសើរកាមសុខថាជារបស់ល្អនោះ កើតសេចក្តីនឿយណាយធុញទ្រាន់ ដោយអាស្រ័យហេតុលើកយកព្រះសាស្តាមកប្រៀបធៀបហើយ នឹងកើតសទ្ធាជ្រះថ្លាចំពោះព្រះអង្គ មានយល់ឃើញតាមហេតុពិត អាចនឹងឲ្យបានសម្រេចគុណធម៌តាមសមគួរដល់សេចក្តីប្រតិបត្តិរបស់ខ្លួន ។

៨១ – ស. ហេតុអ្វីបានជាព្រះសាស្តាមិនស្រវឹងវង្វេងក្នុងកាមសុខនោះ ត្រឡប់ជានឿយណាយធុញទ្រាន់ទៅវិញ ?

ឆ. ធម្មតាកាមសុខជារបស់ដែលមហាជនត្រូវតែស្រឡាញ់ចង់បានគ្រប់គ្នា ។ មានបណ្តាជនជាច្រើនដែលនៅជាបុថុជ្ជនតែងសរសើរថាកាមសុខជារបស់ល្អគួរឲ្យចង់បាន ។ ប៉ុន្តែចំណែកលោកអ្នកមានបញ្ញាត្រិះរិះពិចារណាទៅហើយ ក៏បានឃើញតាមសេចក្តីពិតរបស់ធម្មតាចៀសមិនផុតពីធម្មតាៗ បន្តាប់កំណត់ទុកស្រេចមកហើយថា សភាវៈទាំងពួងរមែងមានជាគូៗ គ្នា ដូចមានក្តៅហើយត្រូវមានត្រជាក់ជាគ្រឿងកែជាដើម ។ ព្រោះហេតុនោះ កាលបើទីណាមានសុខ ទីនោះរមែងមានទុក្ខនៅលាយឡំផង នេះឯងជាធម្មតាកំណត់ទុកមក ។ ហេតុដូច្នេះការណ៍ដែលនឹងបានដឹងរឿថាជាទុក្ខ ក៏ត្រូវអាស្រ័យបានទទួលសេចក្តីសុខយ៉ាងពេញលេញរួចពីមុនមកហើយ ។ ព្រះមហាបុរសដែលនឹងជ្រាបបានថាកាមសុខជាទុក្ខក៏ព្រោះតែព្រះអង្គធ្លាប់សោយកាមសុខបរិបូណ៌រួចមកហើយ គឺក្នុងវាំងដែលព្រះអង្គនៅក្នុងឃរាវាសសម្បត្តិនោះ ពួកព្រះញាតិវង្សទាំងឡាយ មានសេចក្តីខ្វល់ខ្វាយជួយអភិបាលរក្សា ទ្រង់នឹងស្តេចទៅខាងណា ក៏មានស្វេតច្ឆត្របាំងដើម្បីនឹងការពារនូវសម្ផស្សផ្សេងៗ មានទាំងប្រាសាទ ៣ ខ្នង ជាទីគង់នៅដ៏សមគួរដល់សេចក្តីសប្បាយក្នុងរដូវទាំង ៣ ។ កាលព្រះអង្គមានព្រះជន្មល្មមនឹងមានព្រះជាយាបានហើយ

ព្រះវរបិតាក៏បញ្ជូនទូតឲ្យទៅសូមព្រះនាងពិម្ពា ដែលជាព្រះរាជធីតានៃព្រះបាទក្រុងទេវទហៈ មកផ្សំផ្គុំឲ្យជាព្រះជាយារាបដល់បានបង្កើតបុត្រ ១អង្គ ហៅថា រាហុល ។ ព្រះមហាបុរសបានសោយកាមសុខបរិបូណ៌មកដូច្នេះហើយ ទើបព្រះអង្គបានជ្រាប តាមសេចក្តីកើតពិតរបស់ធម្មតាថាមានទុក្ខនៅប្រឡូកប្រឡំ ទើបធ្វើឲ្យព្រះអង្គនឿយណាយក្នុងកាមសុខ ។

៨២ ស- ព្រះមហាបុរសទ្រង់ឃើញអ្វី ទើបស្តេចចេញទ្រង់ព្រះផ្នួស ?

ឆ. ព្រះអង្គបានឃើញទេវទូតទាំង ៤ គឺមនុស្សចាស់ជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ ភេទអ្នកបួស ១ ។

៨៣-ស. ព្រះអង្គឃើញទេវទូតទាំង៤ នោះ នៅទីណា ? អ្នកណាមកនិម្មិតថ្វាយ ? ឃើញតែម្តងគ្រប់ទាំង ៤ ឬដូចម្តេច ?

ឆ. ព្រះអង្គឃើញនៅក្នុងឧទ្យាន ។ សុទ្ធាវាសទេវតាមកនិម្មិតថ្វាយ ។ មិនមែនឃើញម្តងគ្រប់ទេវទូតទាំង ៤ នោះទេ គឺកន្លងទៅ ៤ ខែៗ ទើបឃើញទៅទូតមួយ ៗ ។

៨៤ - ស. ចុះទេវទូតប៉ុន្មាន ជាហេតុឲ្យព្រះអង្គនឿយណាយចាកកាមសុខ ? ប៉ុន្មានជាហេតុឲ្យព្រះអង្គជ្រះថ្លាក្នុងការទ្រង់ព្រះផ្នួស ?

ឆ. ទេវទូត ៣ ខាងដើម គឺមនុស្សចាស់ ឈឺ និង ស្លាប់ ជាហេតុឲ្យព្រះអង្គនឿយណាយចាកកាមសុខ ។ ទេវទូតទី ៤ គឺភេទអ្នកបួស ជាហេតុឲ្យព្រះអង្គជ្រះថ្លាក្នុងការចេញទ្រង់ព្រះផ្នួស ។

៨៥- ស. ព្រះអង្គចេញទ្រង់ព្រះផ្នួសក្នុងព្រះជន្មប៉ុន្មាន? នៅថ្ងៃ-ខែ-ឆ្នាំអ្វី? ពេលថ្មើរម៉ាន?

ឆ. ក្នុងព្រះជន្មគំរប់២៩ឆ្នាំ ។ នៅថ្ងៃព្រហស្បតិ៍ពេញបូណ៌មី, ខែអាសាឍ, ឆ្នាំថោះ ។ វេលាអធ្រាត្រ ។

៨៦- ស. កាលព្រះអង្គចេញទ្រង់ព្រះផ្នួសនោះ ព្រះរាហុលកុមារប្រសូតហើយឬនៅ ?

ឆ. ព្រះរាហុលកុមារប្រសូតក្នុងថ្ងៃដែលព្រះមហាបុរសចេញទ្រង់ព្រះផ្នួសនោះឯង គឺក្នុងពេលដែលព្រះអង្គនៅក្រសាលក្នុងឧទ្យានព្រះរាហុលកុមារប្រសូតក្នុងថ្ងៃនោះ លុះដល់ពាក់កណ្តាលអធ្រាត្រទើបព្រះអង្គចេញទ្រង់ព្រះផ្នួស ។

៨៧- ស. ចុះព្រះមហាបុរសគង់អ្វីចេញទៅទ្រង់ព្រះផ្នួស ? មានអ្នកណាតាមហែទៅផងដែរឬទេ ?

ឆ. ព្រះអង្គគង់សេះកណ្ឋកៈ មានដងខ្លួនប្រមាណ ១៨ ហត្ថ ។ មាននាយឆន្នអាមាត្យគោលគង្វាលសេះតាមហែទៅផង ។

៨៨- សិ. កាលព្រះមហាបុរសចេញផុតពីនគរទៅ បានជួបប្រទះនឹងអ្នកណាដែរឬ? អ្នកនោះមកនិយាយថាម្ដេច?

ប. ព្រះអង្គបានជួបនឹងទេវបុត្តមារចុះពីទេវលោកមកស្ថិតនៅឯអាកាស, មកនិយាយឃាត់ព្រះអង្គថា "នៃសិទ្ធត្ថ! អ្នកកុំចេញទៅបួសឡើយ, នៅតែ ៧ ថ្ងៃទៀតទេសម្បត្តិចក្រពត្តិនឹងមកដល់អ្នកហើយ" ។ ព្រះអង្គត្រាស់ថា "យើងដឹងហើយ យើងមិនអាល័យទេ" ។ មារក្ដូឈ្លោះចៀសចេញបាត់ទៅ ។

៨៩- សិ. ចុះព្រះអង្គស្ដេចចេញទៅក្នុងរាត្រីនោះកន្លងនគរប៉ុន្មាន? ឈ្មោះអ្វីខ្លះ? ចម្ងាយផ្លូវប៉ុន្មាន? ទៅគង់នៅទីកន្លែងណា?

ប. កន្លងនគរ ៣ គឺនគរកបិលពស្តុ ១ សាវត្ថី ១ វេសាលី ១ អស់រយៈផ្លូវចម្ងាយ ៣០ យោជន៍ ។ ទៅគង់នៅឆ្នេរស្ទឹងអនោមា ខាងត្រើយនាយ ។

៩០- សិ. សេះកណ្ឋកៈ ស្លាប់ហើយទៅកើតនៅឯណា? ឈ្មោះអ្វី?

ប. ទៅកើតក្នុងទេវលោកជាន់តាវត្តិង្ស ។ ឈ្មោះកណ្ឋកទេវបុត្រ ។

៩១- សិ. ចុះព្រះមហាបុរសទ្រង់បព្វជ្ជាដោយអាការដូចម្ដេច?

ប. កាលព្រះអង្គប្រគល់សេះនិងគ្រឿងប្រដាប់ទៅឲ្យនាយឆន្នអាមាត្យនាំទៅនគរវិញហើយ ទ្រង់គង់នៅលើផ្ទុកខ្សាច់ស ១ ព្រះអង្គឯងទ្រង់ប្រាថ្នានឹងកាត់ព្រះកេសា ។ គ្រានោះ ព្រះខាន់ទិព្វធ្លាក់មកថ្វាយ ។ ព្រះអង្គកាត់ព្រះកេសាទុកឲ្យសល់ប្រវែងពីរធ្នាប់ ព្រះកេសាដែលសល់នោះវិលជាទក្ខិណាវដ្ដ រួចទ្រង់អធិដ្ឋានមោលីហើយបោះទៅក្នុងអាកាស ព្រះឥន្ទ្រយកប្រអប់កែវមក ទទួលយកទៅបញ្ចុះទុកក្នុងចូឡាមណីចេតិយ នៅស្ថានតាវត្តិង្ស ។

៩២- សិ. ចុះព្រះមហាបុរសបានគ្រឿងបរិក្ខារសម្រាប់អ្នកបួសមកអំពីអ្នកណា? បរិក្ខារនោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

ប. ព្រះអង្គបានអំពីឃដិការមហាព្រហ្ម នាំយកមកថ្វាយ ។ បរិក្ខារនោះមាន ៨ យ៉ាង គឺស្បង់ ១ ចីពរ ១ សង្ឃាដិ ១ បាត្រ ១ កាំបិតកោរ ១ សំពង់ម្ជុល ១ វត្ថពន្ធចង្កេះ ១ ដម្រងទឹក ១ ។

៩៣- សិ. ចុះព្រះពស្ត្រចាស់ ១ គូ ដែលព្រះអង្គធ្លាប់ទ្រង់កាលនៅជាឃរាវាសនោះ តើទៅឯណាទៅ?

ប. មហាព្រហ្មយកទៅបញ្ចុះទុកក្នុងទុស្សចេតិយ កំពស់ ១២ យោជន៍ ក្នុងព្រហ្មលោក ។

៩៤– សំ. ព្រះមហាបុរសបានសិក្សាចេះដឹងក្នុងយុទ្ធវិធីសមគួរដល់ជាតិក្សត្រហើយ ត្រូវតែទ្រង់គ្រងអគារក្នុងឃរាវាសសម្បត្តិ ហេតុអ្វីទើបគាប់ព្រះទ័យក្នុងការទ្រង់ព្រះផ្នួសវិញ?

ឆ. ហេតុតែព្រះអង្គមានព្រះករុណាក្នុងមហាជនជាយ៉ាងធំ ទើបផ្លាស់ប្ដូរសេចក្ដីប្រព្រឹត្តិរបស់ព្រះអង្គ ដើម្បីនឹងធ្វើប្រយោជន៍ដល់បណ្ដាជនបានពេញទី ហើយបានឆ្ងាយទូលាយផង ។

៩៥– សំ. ក្នុងរឿងថា: ព្រះមហាបុរសឃើញផ្ទៃប្រាសាទដ៏ចង្អៀតណែនណាន់ទៅដោយបរិវារដូចព្រៃដុតខ្មោចនោះ គេមានអធិប្បាយដូចម្ដេច?

ឆ. មានអធិប្បាយថា: ព្រះអង្គទ្រង់នឿយណាយនឹងភាពនៃក្សត្រជាអ្នកសម្បូណ៌ទៅដោយកាមគុណ វង្វេងច្រឡំជ្រប់ទៅក្នុងកាមគុណ នៅជាមួយតែនឹងស្ត្រី មិនចុះចេញពីប្រាសាទ ដែលគេឃើញថាជាសុខ ប៉ុន្តែធ្វើជីវិតឲ្យឥតអំពើ ទតឃើញមិនជាទីគាប់ព្រះទ័យ ហាក់ដូចជានៅក្នុងព្រៃដុតខ្មោច នឹងទៅផ្លូវណាក៏ចេះតែជួបប្រទះនឹងរបស់ដែលជាទីតាំងនៃសេចក្ដីសង្វេគទាំងអស់ ។

៩៦– សំ. បើមានគេនិយាយថា ការណ៍ដែលព្រះមហាបុរសស្ដេចចេញបព្វជ្ជា ព្រោះតែចង្អៀតចង្អល់ព្រះទ័យដោយហេតុព្រះនាងបជាបតិ

គោតមីជាព្រះមាតុច្ឆារុកកួនប្រៀតប្រៀត ដើម្បីនឹងឲ្យរាជសម្បត្តិដល់ព្រះនន្ទកុមារជាព្រះឱរស, តើរឿងនេះមានគោលនៃសេចក្ដីពិតដូច្នោះឬទេ? ចូរឆ្លើយមក!

ឆ. រឿងនេះគ្មានគោលនៃសេចក្ដីពិតដែលគួរស្ដាប់បានទេ ខ តាមព្រះចរិយាដែលមានប្រាកដក្នុងប្រវត្តិនៃព្រះមហាបុរសនោះថា: កាលព្រះអង្គនៅជាឃរាវាស ទ្រង់បរិបូណ៌ដោយគុណសម្បត្តិជាក់ច្បាស់ដល់ប្រជាជន ខ ព្រះញាតិទាំងឡាយប្រាថ្នានឹងយកព្រះអង្គជាទីពឹង ដោយហេតុបានស្ដាប់ពាក្យព្យាករណ៍នៃកាឡទេវិលតាបស បានព្រមព្រះទ័យគ្នាថ្នមព្រះអង្គថ្វាយព្រះកុមារឲ្យជាបរិវារខ្លះ ជួយធ្វើកិច្ចធុរៈដទៃទៀតខ្លះ ខ ចំណែកព្រះមាតុច្ឆាក៏ទទួលនាទីជាអ្នកថែរក្សាព្រះអង្គ ខ ព្រះបិតាក៏ទ្រង់ចងទាក់ដោយប្រការផ្សេង ៗ ដើម្បីឲ្យព្រះអង្គត្រេកត្រអាលនៅក្នុងកាមសុខ ព្រោះត្រូវការឲ្យសោយរាជ្យជាស្ដេចចក្រពត្តិ ដែលជាហេតុឲ្យព្រះអង្គស្ដេចចេញបព្វជ្ជាបានដោយលំបាក ដូចមានដំណាលក្នុងពុទ្ធប្រវត្តិស្រាប់ហើយ ខ មួយទៀត កាលព្រះបាទសុទ្ធោទនៈទិវង្គតហើយ ព្រះនាងបានទៅទូលសូមបព្វជ្ជាជាភិក្ខុនីក្នុងសំណាក់ព្រះអង្គផង ខ រឿងនេះបង្ហាញឲ្យឃើញថា ព្រះនាងមានព្រះទ័យស្រឡាញ់ព្រះអង្គតាំងពីដើមមកមែនទែន ហេតុផលទាំងឡាយដូចបានបរិយាយមកនេះ នាំឲ្យសន្និដ្ឋានបាន

...ក ព្រះអង្គស្តេចចេញបព្វជ្ជាដោយទ្រង់ប្រាថ្នាស្វែងរកមោក្ខធម៌ មិនមែន
...ចេញទៅដោយសេចក្តីចង្អៀតចង្អល់ទាល់ព្រះរាជហឫទ័យទេ ។

៩៧– សំ. កាលព្រះមហាបុរសចេញបព្វជ្ជានោះ មិនមានអ្នកណា
ហាមឃាត់ខ្លះទេឬ ?

ឆ. មិនមានអ្នកណាហាមឃាត់ទេ ដ្បិតព្រះញាតិទាំងឡាយ
...មានព្រះបិតាជាដើម មានព្រះទ័យស្រឡាញ់ព្រះអង្គណាស់ចង់ឲ្យតែព្រះ
...អង្គនៅគ្រប់គ្រងរាជសម្បត្តិ ព្រោះព្រះអង្គក៏ជារជ្ជទាយាទសមគួរនឹងបាន
...សោយរាជ្យស្នងព្រះបិតាតទៅ , ការចង់ឲ្យនៅគ្រប់គ្រងរាជសម្បត្តិខ្លាំង
...ជាងការព្រមឲ្យព្រះអង្គចេញទ្រង់ព្រះផ្នួស ចាប់តាំងពីថ្ងៃដែលកាឡទេវិល
...តាបសបានទាយថា“ព្រះមហាបុរសមានគតិតែមួយយ៉ាង គឺប្រាកដជានឹង
...ចេញបួសហើយបានជាសាស្តាឯកក្នុងលោក ព្រោះព្រះអង្គប្រកបដោយ
...មហាបុរិសលក្ខណៈត្រូវតាមគម្ពីរព្រាហ្មណ៍”។ ប៉ុន្តែកាលព្រះអង្គនឹងចេញ
...ទ្រង់ព្រះផ្នួសនោះ ពួកព្រះញាតិទាំងឡាយមានព្រះបិតាជាដើមស្មានថា
...ជាការចេញបួសដើម្បីបំពេញវត្តមួយដងមួយកាលតាមសាសនាព្រាហ្មណ៍
...ប៉ុណ្ណោះ បានជាព្រមបណ្តោយឲ្យចេញបួសតាមប្រាថ្នាមិនហាមឃាត់ ទាំង
...ដើម្បីថ្នមព្រះទ័យនៃព្រះអង្គផង, លុះកាលព្រះអង្គចេញទៅបួសហើយ

មិនបានត្រឡប់មកវិញ , ចេះតែបាត់សូន្យឈឹងទៅ ។ ពួកព្រះញាតិមិនដឹងគិតធ្វើម្តេច ។ ថែមទាំងព្រះអង្គកាត់ព្រះមោលីចេញទៀត ដើម្បីនឹងឲ្យព្រះញាតិលែងចង់ឲ្យព្រះអង្គត្រឡប់មកវិញ ។ ព្រោះមនុស្សក្នុងសម័យនោះប្រកាន់ថា ការកោរសក់ជាការអប្រិយចង្រៃ ។ ព្រោះហេតុនេះឯង ទើបធ្វើឲ្យព្រះអង្គចេញបួសបានដោយងាយ ឥតមានអ្នកទាំងឃាត់ ។

៩៨– សំ. ហេតុអ្វីបានជាព្រះមហាបុរសមិនស្វែងរកមោក្ខធម៌ក្នុងឃរា-វាសវិស័យវិញ ?

ឆ. ហេតុតែឃរាវាសជាទីចង្អៀតចង្អល់ណាស់ ជាទីតាំងនៃអារម្មណ៍ធ្វើចិត្តឲ្យសៅហ្មងដោយសេចក្តីស្រឡាញ់ សេចក្តីស្អប់នឹងការវង្វេងដូចជាផ្លូវសម្រាប់ឲ្យធូលីហូរចូលមក បានជាព្រះអង្គមិនស្វែងរកមោក្ខធម៌ក្នុងឃរាវាសវិស័យ ។

៩៩– សំ. ព្រះមហាបុរសបានរៀនសូត្រចេះដឹងសមគួរដល់វង្សត្រកូលនៃព្រះអង្គហើយ គួរណាស់តែព្រះអង្គជាប់ព្រះទ័យត្រេកអរក្នុងឃរាវាសគ្រប់គ្រងរាណាចក្រមែនឬទេ ? ប៉ុន្តែហេតុអ្វីក៏សព្វព្រះទ័យក្នុងការចេញទ្រង់ព្រះផ្នួសជាសមណៈទៅវិញ ?

ឆ. ព្រះអង្គបានរៀនសូត្រចេះដឹងដូច្នោះមែនហើយ ដូចជាកាលទ្រង់សំដែងឲ្យប្រាកដក្នុងពួកព្រះញាតិ ព្រមទាំងទ្រង់សំដែងធំពិទេសនា

ជាប់ទាក់ទងដោយការសិក្សារបស់ឃរាវាសក៏មាន ។ ប៉ុន្តែព្រោះហេតុព្រះអង្គមានព្រះទ័យពេញទៅដោយព្រះករុណាដូចអន្លង់ទឹកដ៏ធំ ទើបចេញទ្រង់ផ្នួសប្រកាសសាសនាទាំងក្នុងអាណាចក្រនិងក្រៅអាណាចក្រ ទ្រង់ប្រាថ្នាប្រយោជន៍ដ៏ធំទូលាយយ៉ាងខ្ពង់ខ្ពស់បំផុតឲ្យមានដល់វេនេយ្យនិករទូទៅរាល់កាលជាយូរអង្វែង ដែលអ្នកនៅគ្រប់គ្រងផ្ទះសូម្បីជាស្តេចចក្រក៏មិនអាចនឹងបំពេញឲ្យស្មើបាន ហេតុនេះ ទើបព្រះអង្គសព្វព្រះទ័យក្នុងការទ្រង់ព្រះផ្នួស ។

១០០-ស. ព្រះមហាបុរសទ្រង់ប្រារព្ធហេតុអ្វី ទើបស្តេចចេញបព្វជ្ជា?

ឆ. តាមបាលីមជ្ឈិមនិកាយសំដែងថា ទ្រង់ប្រារព្ធជរា (សេចក្តីចាស់), ព្យាធិ (ការឈឺ), មរណៈ (សេចក្តីស្លាប់) ជាដើមហេតុ ។

១០១-ស. គ្រង់ពាក្យថា ព្រោះព្រះមហាបុរសទ្រង់ប្រារព្ធដល់ជរា ព្យាធិ មរណៈ ដែលធ្លាប់ជួបធ្លាប់ឃើញមកដោយប្រក្រតីអំពីមុនមកនោះឯង ជាហេតុឲ្យស្តេចចេញបព្វជ្ជា: បើប្រកាន់យកសេចក្តីតាមពាក្យខាងលើនោះ ឃើញថាខុសគ្នានឹងពាក្យដែលថាកាលព្រះអង្គនៅជាឃរាវាស មិនដែលបានឃើញមនុស្សចាស់, ឈឺ, ស្លាប់សោះ ព្រោះព្រះបិតាប្រយ័ត្នការពារមិនឲ្យព្រះអង្គឃើញ បើដូច្នេះតើយើងនឹងសន្និដ្ឋានថាដូចម្តេច ?

ឆ. ខុសគ្នាមែន, សន្និដ្ឋានថា ព្រះមហាបុរសមានព្រះជន្មដល់ទៅ២៩ ឆ្នាំហើយ, ក្នុងរយៈវេលាប៉ុណ្ណោះគង់តែធ្លាប់ឃើញព្រះញាតិវង្សចាស់ៗ ជរាខ្លះ ប្រឈួនខ្លះនិងអស់ព្រះជន្មខ្លះមិនខាន សូម្បីព្រះបិតាក៏គង់ព្រះជរាជារាល់ថ្ងៃ ដែលព្រះអង្គត្រូវតែជ្រាប ។ ឯការឈឺចាប់នោះព្រះអង្គឯងជួនកាលក៏គង់មានព្រះរោគកើតឡើងដែរ ដែលជាហេតុឲ្យទ្រង់ជ្រាបថាការឈឺចាប់នោះជាយ៉ាងណា ហេតុនោះពាក្យដែលថាព្រះអង្គមិនធ្លាប់ឃើញមនុស្សចាស់ឈឺស្លាប់សោះនោះ ជាពាក្យខុស ។

១០២ ស. បើសន្និដ្ឋានថា ព្រះមហាបុរសធ្លាប់បានឃើញមនុស្សចាស់ ឈឺ ស្លាប់មកហើយ, គ្រង់រឿងដែលព្រះអង្គត្រាស់ប្តេជ្ញាក្នុងព្រះធម្មចក្រនៅវេលាត្រាស់ដឹងហើយថា "តថាគតបានកើតមឹងឃើញឡើងក្នុងធម៌ទាំងឡាយ ដែលមិនធ្លាប់ស្តាប់មកហើយក្នុងកាលមុនថានេះទុក្ខ", ឯទុក្ខនោះគឺជាតិ ជរា ព្យាធិ មរណៈ ជាដើមនុ៎ះឯង បើដូច្នេះតើនឹងឆ្លើយដូចម្តេច ?

ឆ. ជាតិ ជរា ព្យាធិ មរណៈ ដែលព្រះអង្គធ្លាប់បានឃើញមកហើយនោះគ្រាន់តែត្រឹមថ្នាក់សន្មតិ មិនមែនជាផ្លូវបរមត្ថទេ ។ ចំណែកដែលទ្រង់ប្តេជ្ញាក្នុងព្រះធម្មចក្រទេសនានោះ ជាសេចក្តីដឹងឃើញថ្នាក់បរមត្ថ ដោយព្រះវិចារណញ្ញាណដ៏ល្អិតសុខុម ។ មុនដំបូងទ្រង់

ឃើញថា ជាតិ ក៏គឺសេចក្ដីប្រាកដនៃបញ្ចក្ខន្ធ, ជរា ក៏គឺសេចក្ដីប្រែប្រួលនៃបញ្ចក្ខន្ធ, មរណៈ ក៏គឺសេចក្ដីបែកធ្លាយនៃបញ្ចក្ខន្ធ ដែលជាជាន់សេចក្ដីដឹងឃើញក្នុងផ្លូវពោធិញាណ ។ ពាក្យដែលថាឃើញទុក្ខ គឺឃើញទុក្ខយ៉ាងល្អិតដែលកាលពីដើម ព្រះអង្គមិនធ្លាប់បានឃើញថាជាទុក្ខនោះឡើយ ។

១០៣ ស. ព្រះមហាបុរសចេញទ្រង់ព្រះផ្នួសដោយការលបរត់ទៅ ឬមួយដោយការទូលព្រះបិតា ? ចូរឆ្លើយដោយមានគោលជាសំអាងមកផង !

ប. រឿងដែលចេញបព្វជ្ជានេះ លោកអាចារ្យអ្នកតែងអដ្ឋកថាសំដែងថា ព្រះអង្គរត់ចេញទៅក្នុងវេលាអធ្រាត្រគង់សេះកណ្ឋកៈ មាននាយឆន្នអាមាត្យតាមហែទៅផង ។ ចំណែកលោកអាចារ្យអ្នករចនាព្រះបាលីសំដែងថា បានលាព្រះបិតាមាតា តែទ្រង់មិនអនុញ្ញាត, ក្នុងសម័យខាងក្រោយមកព្រះមហាបុរសទ្រង់ឈ្វេងយល់ថា ព្រោះតែអាត្មាអញនៅក្មេង មានសក់ខ្មៅស្និទ្ធ ស្ថិតនៅក្នុងបឋមវ័យ បានជាព្រះបិតាមាតាមានព្រះភក្ត្រទទឹកជោកដោយទឹកព្រះនេត្រទ្រង់ព្រះកន្សែងមិនអនុញ្ញាត ឃាត់ហាមមិនឲ្យចេញបព្វជ្ជា ដូច្នេះទើបព្រះអង្គកោរព្រះកេសានិងព្រះមស្សុ ហើយទ្រង់គ្រងសំពត់កាសាយៈដល់នូវភាវៈជាបព្វជិត នៅចំពោះព្រះភក្ត្រ

ព្រះមាតាបិតា ហើយបានលាស្ដេចចេញទៅតាំងព្យាយាមក្នុងឧរុវេលាសេនានិគម ។

១០៤-ស. កាលព្រះមហាបុរសស្ដេចចេញបព្វជ្ជា តាមរឿងរ៉ាវលោកពោលថាបានសំពត់កាសាយៈមកអំពីណា ? រឿងនោះនិងសន្និដ្ឋានថាម៉េច ?

ប. លោកពោលថា ឃដិការព្រហ្មនាំមកថ្វាយ ។ សន្និដ្ឋានថាគួរតែបានមកអំពីសំណាក់បព្វជិតអ្នកបានសមាបត្តិ ព្រោះសមាបត្តិជាហេតុនៃការកើតជាព្រហ្ម, ដែលថាបានមកអំពីឃដិការព្រហ្ម ក៏គឺបានមកអំពីបព្វជិតអ្នកបានសមាបត្តិនោះ ។

ព្រះសាស្ដាធ្វើទុក្ករកិរិយា

១០៥-ស. កាលព្រះមហាបុរសបព្វជ្ជាហើយ បានចូលទៅសិក្សាក្នុងសំណាក់អ្នកណា ? បានចេះដឹងដូចម្ដេច ? ហេតុអ្វីបានជាថាព្រះអង្គត្រាស់ដឹងឯង ?

ប. កាលព្រះអង្គបព្វជ្ជាហើយ បានចូលទៅសិក្សាក្នុងសំណាក់អាឡារតាបសកាលាមគោត្រ និងឧទ្ទកតាបសរាមបុត្រ, បានចេះដឹងក្នុងរូបឈានទាំង៤និងអរូបឈាន៤ ។ ចំណេះដែលបានចេះដឹងក្នុងសំណាក់តាបសទាំងពីរនោះគ្រាន់តែត្រឹមលោកិយធម៌ ។ ចំណេះដែលត្រាស់ដឹង-

ចុំនោះ គឺអរិយសច្ចៈ ៤ ជាលោកុត្តរធម៌ ហេតុនោះបានជាជាត្រាស់ដឹងដោយកំឡាំងព្រះអង្គឯង ។

១០៦-សួ. ទុក្ករកិរិយាបានសេចក្ដីថាម៉េច? ហេតុអ្វីបានជាព្រះមហាបុរសធ្វើ? ឬព្រះអង្គយល់ខុសទេ?

ឆ. ទុក្ករកិរិយានោះបានសេចក្ដីយ៉ាងខ្លីថា "ការបំពេញអត្តកិលមថានុយោគ" គឺការព្យាយាមធ្វើខ្លួនឲ្យលំបាកផ្សេង ៗ ដែលមិនមែនជាផ្លូវឲ្យបានសម្រេចមគ្គផល (មានច្បាស់នៅក្នុងពុទ្ធប្រវត្តិស្រាប់ហើយ)។ បានជាព្រះអង្គធ្វើទុក្ករកិរិយានោះ ដោយហេតុទ្រង់ឈ្វេងយល់ថាទុក្ករកិរិយានេះជាផ្លូវនៃសេចក្ដីត្រាស់ដឹងបានខ្លះ, មួយទៀតព្រោះក្នុងយុគនោះពួកអ្នកប្រព្រឹត្តវត្តប្រកាន់ការបំពេញទុក្ករកិរិយាថាជាវត្តយ៉ាងសំខាន់បំផុត ដែលជាហេតុឲ្យព្រះអង្គត្រូវតែប្រព្រឹត្តល្បងមើល ហើយឲ្យលើសគេទៅទៀត ។ មិនមែនទ្រង់យល់ខុសទេ ។

១០៧-សួ. កាលព្រះមហាបុរសចេញបព្វជ្ជាហើយ មុនត្រាស់ដឹង ព្រះអង្គបានស្ដេចចេញទៅកាន់ដែនសក្កជនបទដែរឬទេ? ដឹងដោយអ្វីបានជាឆ្លើយយ៉ាងនោះ?

ឆ. ព្រះអង្គបានយាងទៅដែរ ។ ដឹងដោយសារឃើញក្នុងពុទ្ធប្រវត្តិដំណាលថា ព្រះអង្គបានយាងទៅសិក្សាលទ្ធិក្នុងសំណាក់អាឡារ

តាបស និងឧទកតាបសដែលជាគណាចារ្យធំ មានទីលំនៅ ។ ក្នុងដែនសក្កជនបទ ។

១០៨-សួ. ព្រះមហាបុរសធ្វើទុក្ករកិរិយាក្នុងកន្លែងណា? មានអ្នកណាខ្លះដឹងឮឃើញជាបន្ទាល់ថាបានធ្វើមែន? ចូរឆ្លើយដោយមានកេងឲ្យសព្វគ្រប់!

ឆ. ព្រះអង្គធ្វើនៅតំបន់ឧរុវេលាសេនានិគម ដែនមគធជនបទ ។ មានអ្នកដឹងឃើញច្រើនជាង៥នាក់ឡើងទៅ ប៉ុន្តែអ្នកដែលបាននៅជាមួយ ៥ នាក់គឺព្រះកោណ្ឌញ្ញៈ ១ ព្រះវប្បៈ ១ ព្រះភទ្ទិយៈ ១ ព្រះមហានាម ១ ព្រះអស្សជិ ១ ក្រៅពីនេះមានពួកអ្នកស្រុកដែលមកនិយាយសរសើរព្រះចរិតនៃព្រះអង្គផងទៀត ។

១០៩-សួ. គំនិតឬកិច្ចការអ្វីដែលភ្លាត់ខុសទៅហើយជារបស់គួរបិទបាំង មិនគួរបញ្ចេញឲ្យគេឯងដឹងឮមែនឬទេ? ការដែលព្រះអង្គធ្វើទុក្ករកិរិយានោះជាអំពើភ្លាត់ខុសទៅហើយ ហេតុម្ដេចបានជាព្រះអង្គលើកយកមកសំដែងផ្សាយឲ្យគេដឹងក្នុងវេលាសំដែងបឋមទេសនា ដោយហេតុព្រះអង្គយល់ឃើញថាជាព្រះកិត្តិយសឬអ្វី?

ឆ. មិនមែនព្រះអង្គយល់ឃើញថាជាព្រះកិត្តិយសទេ, ទ្រង់យល់ឃើញថាជាប្រយោជន៍ក្នុងការទេសនា ដើម្បីនឹងពន្យល់ឲ្យឃើញថា

ការធ្វើដូច្នោះ ជាអត្តកិលមថានុយោគមិនមែនជាផ្លូវត្រូវទេ ដោយអាងថា ព្រះអង្គធ្លាប់ល្បងមើលដឹងរសជាតិមកហើយ ឥតបានផលប្រយោជន៍អ្វីសោះ ។ មួយទៀតដើម្បីពន្យល់ព្រះបញ្ចវគ្គិយភិក្ខុឲ្យឃើញច្បាស់ថា ការធ្វើទុក្ករកិរិយានោះជាទោសទេ ត្រូវលះបង់ការប្រកាន់ដូច្នោះចេញ ។

១១០-ស. ព្រះមហាបុរសប្រាថ្នាប្រយោជន៍ដូចម្តេច បានជាទ្រង់បំពេញទុក្ករកិរិយា ? ចុះការណ៍ដែលព្រះអង្គធ្វើទុក្ករកិរិយាហើយបែរជាលះបង់ចោលទៅវិញ មិនគឺព្រះអង្គយល់ឃើញថាទ្រង់ធ្វើខុសមែនឬទេ ? បើដូច្នោះ មិនខុសគ្នានឹងពាក្យដែលថាព្រះអង្គមានបញ្ញាលើសសាមញ្ញ-ជនទៅហើយឬ ?

ប. ព្រះអង្គប្រាថ្នាប្រយោជន៍ដើម្បីនឹងហាមឃាត់ចិត្តមិនឲ្យបង្អោនទៅក្នុងកាមារម្មណ៍ ។ ការណ៍ដែលព្រះអង្គលែងធ្វើទុក្ករកិរិយាទៅវិញនោះព្រោះទ្រង់យល់ឃើញថាជាផ្លូវខុសមែន ប៉ុន្តែមិនខុសពីពាក្យថាព្រះអង្គមានបញ្ញាលើសសាមញ្ញជនទេ ព្រោះព្រះអង្គមិនវង្វេងដូចមនុស្សទាំងឡាយដទៃដែលយល់ឃើញថាជាបុណ្យកុសលដោយជាប់ខាត ឯព្រះអង្គត្រិះរិះយល់ឃើញថាជាផ្លូវខុសហើយ ទើបលះបង់ចេញ ហេតុនោះ ទើបត្រឡប់សរសើរថាមានបញ្ញាយ៉ាងជ្រាលជ្រៅទៅវិញ ។

១១១-ស. ចូរគិតមើល ! បើព្រះសាស្តាត្រាស់ដឹងបានងាយៗ មិនបាច់ធ្វើទុក្ករកិរិយា ទាំងដែលទ្រង់ធ្វើទុក្ករកិរិយាដូច្នោះ តើវេលាព្រះអង្គបានត្រាស់ដឹងហើយបានផលខុសគ្នាដូចម្តេចខ្លះ ?

ប. បានផលខុសគ្នាយ៉ាងនេះ៖ បើព្រះអង្គបានត្រាស់ដឹងងាយៗ មិនបាច់ធ្វើទុក្ករកិរិយា ដល់វេលាយាងទៅសំដែងធម៌ប្រដៅវេនេយ្យសត្វអ្នកប្រកាន់ការប្រតិបត្តិទូន្មានរាងកាយឲ្យលំបាក (ដែលហៅថាអត្តកិលមថា-នុយោគ) បែរមកធ្វើដំណើរឲ្យប្រព្រឹត្តទៅក្នុងផ្លូវត្រូវ (ដែលហៅថាមជ្ឈិមាបដិបទា) វិញ កម្រនឹងធ្វើឲ្យគេជឿបាននាប់រហ័សព្រោះគេធ្លាប់ជឿការប្រតិបត្តិដូច្នេះជាយូរណាស់មកហើយ សាសនារបស់ព្រះអង្គក៏នឹងមិនផ្សាយទូទៅបាននាប់រួសរាន់; ការមិនធ្វើទុក្ករកិរិយាបានផលដូចអធិប្បាយមកហើយនេះ ។ ឯការដែលព្រះអង្គធ្វើទុក្ករកិរិយាចាត់ជាផ្លូវខុសនោះ អាចបង្អួលឲ្យឃើញជាបន្ទាល់មុនហើយ ទើបបានត្រាស់ដឹងជាខាងក្រោយ, ការទូន្មានវេនេយ្យសត្វ ដែលប្រកាន់រឹងរូសជាប់ស្អិតក្នុងការទូន្មានរាងកាយក៏បានងាយស្រួល ព្រោះអាស្រ័យលើកយកព្រះអង្គឯងមកអាងជាបន្ទាល់ថា ការទូន្មានខ្លួនបែបនេះ មិនមែនជាផ្លូវនៃសេចក្តីត្រាស់ដឹងទេ ព្រះអង្គធ្លាប់បានធ្វើល្បងមើលមកចាល់តែអស់ចិត្តហើយ អ្នកដែលទំព្យាយាមយ៉ាងខ្លាំងក្លាបំផុត មិនហួសពីសេចក្តីព្យាយាមរបស់ព្រះអង្គទៅដែរ ។

ព្រោះហេតុនោះ កាលបើបុគ្គលដែលមានសេចក្ដីប្រកាន់ភាប់រេនក្នុងការ ទូន្មានកាយបានស្ដាប់ឱវាទរបស់ព្រះអង្គហើយ ក៏នឹងផ្លាស់ទិដ្ឋិសេចក្ដីប្រកាន់មាំនោះចោលបាន ដោយអាស្រ័យលើកយកព្រះអង្គមកធ្វើជាបន្ទាល់ ។ ដូច្នេះ ត្រូវយល់ថាការណ៍ដែលព្រះអង្គធ្វើទុក្ករកិរិយានោះមិនឥតអំពើទេ គឺជួយឲ្យព្រះអង្គទេសនាប្រដៅមហាជនឲ្យបានយល់ងាយៗ ។

១១២-សួ. ព្រះអង្គគង់បំពេញសមណធម៌នៅកន្លែងណា ? ហេតុអ្វីបានជាព្រះអង្គទ្រង់សព្វព្រះទ័យគង់ក្នុងទីនោះ ?

ឆ. ទ្រង់គង់នៅតំបន់ឧរុវេលាសេនានិគមក្នុងមគធជនបទ ។ បានជាព្រះអង្គសព្វព្រះទ័យគង់ក្នុងទីនោះ ព្រោះបានទតឃើញផ្ទៃផែនដីរាបស្មើ ឈើនឹងស្មៅខៀវស្រស់ ជាទីរីករាយចិត្ត ស្ទឹងហូរមានទឹកថ្លាស្អាត មានកំពង់ស្រួលល្អគួរឲ្យសប្បាយ គោចរគ្រាមគឺស្រុកភូមិជាទីត្រាច់ទៅដើម្បីភិក្ខាក៏តាំងនៅជិតជុំវិញ ជាកន្លែងស្ងាត់មិនរឹករេដោយពួកជនត្រាច់ទៅមក ទ្រង់ព្រះតំរិះឃើញថាប្រទេសនោះគួរជាទីតាំងនៅនៃសេចក្ដីព្យាយាមរបស់កុលបុត្រ អ្នកមានសេចក្ដីប្រាថ្នានឹងបំពេញព្យាយាមបាន ។

១១៣-សួ. ក្នុងវេលាដែលព្រះអង្គទ្រង់បំពេញទុក្ករកិរិយានោះ - លោកថាអស់កាលជាយូរដល់ ៦ ឆ្នាំ, ក្នុងរវាងនេះបើព្រះអង្គនឿយ

ណាយព្រះទ័យលះបង់ព្យាយាម ហើយយាងចូលមកនគរវិញ ដូច្នេះតើព្រះអង្គនឹងបានផលល្អ ឬអាក្រក់យ៉ាងណា ?

ឆ. បើព្រះអង្គលះបង់ទុក្ករកិរិយាចេញហើយត្រឡប់ចូលមកនគរវិញ ក៏គង់មិនបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធអ្នកប្រតិស្ឋានព្រះពុទ្ធ-សាសនាឡើយ ។ ចំណែកក្នុងយុវកាលក៏មិនបានទទួលផលវិសេសអ្វីដែរ ព្រោះមនុស្សទាំងឡាយមើលងាយថាជាអ្នកគ្មានសេចក្ដីព្យាយាម ធ្វើអ្វីមិនទៀងទាត់ មិនចប់ចុងដើម; គប្បីឃើញគួយ៉ាងក្នុងវេលាដែលព្រះអង្គឈប់បំពេញទុក្ករកិរិយា ជាហេតុឲ្យព្រះបញ្ចវគ្គិយភិក្ខុនាំគ្នាសំគាល់ថាព្រះអង្គត្រឡប់ទៅជាអ្នកប្រាថ្នាច្រើនវិញ ហើយមុខជាមិនបានសម្រេចធម៌វិសេសណាមួយទេ ទើបនាំគ្នារត់ចោលលែងបំរើព្រះអង្គ ។

១១៤-សួ. ព្រះមហាបុរស បើពោលតាមព្រះពុទ្ធចរិយាថាមានព្រះបញ្ញាជ្រាលជ្រៅណាស់ ទ្រង់ជ្រាបហេតុក្នុងផ្លូវលោកគួរឲ្យអស្ចារ្យដូច្នេះជាដើម, ចុះដែលព្រះអង្គមានព្រះបញ្ញាច្រើននោះ ព្រោះទ្រង់បានរៀនសូត្រចេះដឹងម៉ត់ចត់រួចមកហើយឬ ឬក៏លុះតែបានត្រាស់ដឹងធម៌វិសេសជាព្រះសព្វញ្ញុពុទ្ធហើយ ទើបទ្រង់ជ្រាបហេតុទាំងអស់បាន?

ឆ. ព្រោះព្រះអង្គបានរៀនសូត្រចេះដឹងយ៉ាងម៉ត់ចត់ក្នុងខត្តិយធម៌នឹងគតិលោកដទៃៗ ជាច្រើនមកហើយដូចមានរឿងរំលាលថាព្រះរាជ

បិតាបាននាំយកទៅឲ្យរៀនក្នុងសំណាក់គ្រូវិស្វាមិត្រ ដើម្បីឲ្យរៀនអក្សរសម័យនិងសិល្បៈ ព្រះអង្គទ្រង់រៀនបានចេះដឹងស្ទាញ ស្ទាត់ទាល់តែអស់ចំណេះរបស់អាចារ្យ បានសំដែងឲ្យប្រាកដក្នុងពួកព្រះញាតិ មិនមានរាជកុមារដទៃប្រៀបផ្ទឹមបាន ។ មួយទៀតមានរឿងប្រាកដក្នុងពុទ្ធចរិយាថា កាលព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធហើយទ្រង់ជ្រាបសេចក្តីប្រព្រឹត្តទៅរបស់ស្រុកទេស និងការគ្រប់គ្រងយ៉ាងដទៃ ៗ ព្រះអង្គអាចទាញយកមកសំដែង ជាឧបមាក្នុងព្រះធម៌ដោយអនេកប្រការបាន, លុះត្រាស់ដឹងធម៌វិសេសហើយ ឈ្មោះថាជាការបន្ថែមព្រះបញ្ញាក្នុងផ្លូវបរមត្ថ ឲ្យរីកចំរើនច្រើនឡើងមួយជាន់ទៀត បានជាព្រះអង្គមានព្រះបញ្ញាញាណយ៉ាងអស្ចារ្យ ។

១១៥-ស. កាលព្រះមហាបុរសទ្រង់ព្រះផ្នួសហើយ ទ្រង់ស្វែងរកសេចក្តីត្រាស់ដឹងដោយឧបាយយ៉ាងណាខ្លះ ?

ឆ. ព្រះអង្គទ្រង់ព្រះផ្នួសរួចហើយស្តេចចារិកទៅកាន់សំណាក់អាឡារតាបសនិងឧទកតាបស ដែលមហាជនរាប់អានថាជាគណាចារ្យធំ សូមសិក្សាលទ្ធិសម័យដើម្បីល្បងមើលឲ្យឃើញថាជាឧបាយនឹងឲ្យបានសម្រេចដូចប្រាថ្នាឬទេ ។ កាលទ្រង់សិក្សាអស់ចំណេះគ្រូទាំងពីរ

នោះហើយ ទ្រង់យល់ឃើញថាមិនមែនជាផ្លូវនៃសម្មាសម្ពោធិញ្ញាណ ទើបទ្រង់ចេញអំពីសំណាក់តាបសទាំង ២ នោះយាងទៅទៀត បានទៅដល់ឧរុវេលាប្រទេសជាទីសប្បាយ គួរជាទីតាំងនៃសេចក្តីព្យាយាម ទើបគង់ធ្វើសេចក្តីព្យាយាមក្នុងទីនោះ ខ្នានព្រះកាយបំពេញទុក្ករកិរិយាដើម្បីបាមឃាត់ចិត្តដោយប្រការផ្សេង ៗ មានខាំសង្កត់ព្រះទន្តដោយព្រះទន្ត និងអត់ដង្ហើមនិងអត់អាហារជាដើម បានសោយទុក្ខវេទនាយ៉ាងខ្លាំងក្លា ប៉ុន្តែព្រះទ័យមិនរេរារាយ មានព្រះស្មារតីតាំងមាំមួន ។ កាលទ្រង់យល់ឃើញថាធ្វើយ៉ាងនេះមិនមែនជាផ្លូវត្រូវ ក៏ទ្រង់ផ្លាស់បោលចេញ ហើយរិះរកផ្លូវថ្មីទៀត មិនរួញរា ក្នុងទីបំផុតទ្រង់ធ្វើព្យាយាមខាងផ្លូវចិត្ត រាប់តាំងពីទ្រង់ព្រះផ្នួសមកបាន ៦ ឆ្នាំ ទើបបានត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណគឺជ្រាបអរិយសច្ច ៤ ដូច្នេះ ។

១១៦ ស. កាលព្រះមហាបុរសបព្វជ្ជារួចហើយ ទ្រង់គង់ក្នុងទីណា ? សោយអាហារដែរឬទេ? បានទទួលពាក្យប្តេជ្ញារបស់អ្នកណាដែរឬ?

ឆ. ទ្រង់គង់ក្នុងអនុបិយម្ពវ័ន ។ មិនសោយអាហារអស់ ៧ ថ្ងៃ, លុះដល់ថ្ងៃទី ៨ ទើបព្រះអង្គយាងទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ ព្រះអង្គបានទទួលពាក្យប្តេជ្ញារបស់ព្រះបាទពិម្ពិសារថា បើបានត្រាស់ដឹងហើយ នឹងយាងទៅប្រោសមុនគេ ។

១១៧-ស. កាលព្រះមហាបុរសកំពុងធ្វើទុក្ករកិរិយានោះ មានអ្នកណាខ្លះនៅបំរើព្រះអង្គ ?

ឆ. មានកូនព្រាហ្មណ៍ ៥ នាក់ឈ្មោះ កោណ្ឌញ្ញៈ ១ ភទ្ទិយៈ ១ វប្បៈ ១ មហានាម ១ អស្សជិ ១ ដែលចេញបួសតាមព្រះមហាបុរស ហៅថា បញ្ចវគ្គិយភិក្ខុ បាននៅគាល់បំរើព្រះអង្គ ។

១១៨-ស. កាលព្រះមហាបុរសជិតនឹងបានត្រាស់ដឹង ទ្រង់សុបិននិមិត្តប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. ៥ យ៉ាង គឺទី ១ ទ្រង់ឃើញថាទ្រង់ផ្ទំផ្ងារលើមហាប្រឹថពី ព្រះសិរកើយភ្នំហិមពាន្ត ព្រះបាទាទាំងគូសណ្ដូកចុះក្នុងមហាសមុទ្រខាងទិសទក្សិណ, ព្រះហស្តខាងឆ្វេងសណ្ដូកចុះក្នុងមហាសមុទ្រខាងទិសបូព៌ ព្រះហស្តខាងស្តាំសណ្ដូកចុះក្នុងមហាសមុទ្រខាងទិសបស្ចិម ។ ទី ២ ទ្រង់ឃើញស្មៅចំញ្ចៀនដុះលេចពីព្រះនាភីឡើងទៅដរាបទល់នឹងអាកាស ។ ទី ៣ ទ្រង់ឃើញដង្កូវច្រើនខ្លួនស ក្បាលខ្មៅ វារឡើងពីចុងព្រះបាទាដរាបដល់ព្រះជង្ឃា ។ ទី ៤ ទ្រង់ឃើញសត្វបក្សី ៤ ពួកមានពណ៌ខុសគ្នា ហើរពីទិសទាំង ៤ មកក្រាបទៀបព្រះបាទ ហើយក្រឡប់ជាមានពណ៌សទាំងអស់ ។ ទី ៥ ទ្រង់ឃើញថាព្រះអង្គយាងចង្ក្រមលើភ្នំលាមកដ៏ធំ តែព្រះបាទាមិនបានប្រឡាក់ដោយលាមកឡើយ ។

១១៩-ស. ព្រះមហាសុបិនទាំង ៥ ប្រការនេះ ជាបុព្វនិមិត្តប្លែកគ្នាដូចម្ដេច ?

ឆ. ទី ១ ការផ្ទំលើផែនដី ជាបុព្វនិមិត្តនៃការបាននូវអនុត្តរសម្មាសម្ពោធិញ្ញាណ ។ ព្រះសិរកើយភ្នំហិមពាន្ត ជាបុព្វនិមិត្តនៃការបាននូវខ្នើយគឺសព្វញ្ញុតញ្ញាណ ។ ការសណ្ដូកព្រះហស្តនឹងព្រះបាទចុះក្នុងសមុទ្រនោះ ជាបុព្វនិមិត្តនៃកិរិយាសំដែងនូវធម្មចក្រ ដល់ទេវតានឹងមនុស្ស ។ ការផ្ទំផ្ងារលើផែនដី ជាបុព្វនិមិត្តនៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ចុះឲ្យផ្ងារឡើង ។ កិរិយាផ្ទំបើកព្រះនេត្រ ជាបុព្វនិមិត្តនៃកិរិយាបាននូវទិព្វចក្ខុ ។ ការឃើញនូវពន្លឺភ្លឺដរាបដល់ភវគ្គព្រហ្ម ជាបុព្វនិមិត្តនៃអនាវរណញ្ញាណ ។ ទី ២ ទ្រង់ឃើញស្មៅចំញ្ចៀនដុះលេចពីព្រះនាភីនោះ ជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គ ។ ទី ៣ ទ្រង់ឃើញដង្កូវប្រកាយ ជាបុព្វនិមិត្តនៃបរិស័ទទាំង ៤ ដល់នូវត្រៃសរណគមន៍ស្មើដោយជីវិត ។ ទី ៤ ទ្រង់ឃើញសត្វបក្សី ៤ ពួក ជាបុព្វនិមិត្តនៃត្រកូលទាំង ៤ ចេញបួសប្រព្រឹត្តតាមធមវិន័យ ។ ទី ៥ ទ្រង់ឃើញថាចង្ក្រមលើភ្នំលាមក ជាបុព្វនិមិត្តនៃចតុប្បច្ច័យដែលកើតឡើងដល់ព្រះអង្គ តែព្រះទ័យមិនជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ នោះឡើយ ។

១២០-ស. ចុះនរណាទាយមហាសុបិនទាំង ៥ នោះថ្វាយព្រះអង្គ បានជាទ្រង់ជ្រាបដូច្នោះ ?

ឆ. គ្មានអ្នកណាទាយថ្វាយទេ គឺព្រះអង្គទ្រង់សន្និដ្ឋានក្នុងព្រះទ័យថា «អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ» រួចទ្រង់ទាយដោយព្រះអង្គឯងសព្វគ្រប់ប្រការ(ដូចបានឆ្លើយខាងលើនោះហើយ)

ពុទ្ធបូជា

១២១-ស. ក្នុងថ្ងៃដែលព្រះមហាបុរសបានត្រាស់ដឹង តើព្រះអង្គបានទទួលមធុបាយាសអំពីស្ត្រីណា? ជាកូនអ្នកណា? នៅស្រុកឈ្មោះអ្វី?

ឆ. ព្រះអង្គបានទទួលមធុបាយាសអំពីនាងសុជាតា ជាធីតានៃសេនកុដុម្ពិក, នៅស្រុកសេនានិគមក្នុងឧរុវេលាប្រទេស ។

១២២-ស. ចុះមធុបាយាសនោះ ព្រះអង្គពូតបានប៉ុន្មានពំនូត ? សោយនៅកន្លែងណា? លុះសោយរួចហើយទ្រង់ធ្វើដូចម្ដេចទៀត ?

ឆ. ព្រះអង្គពូតមធុបាយាសបាន ៤៩ ពំនូតប៉ុនៗគ្រាប់ត្នោត ។ ទ្រង់សោយក្បែរឆ្នេរស្ទឹងនេរញ្ជរា សោយស្រេចទ្រង់បណ្ដែតថាសមាសនោះទៅក្នុងស្ទឹង ថាសមាសក៏អណ្ដែតច្រាស់ទឹកទៅបាន ៨០ ហត្ថដោយ

អំណាចទ្រង់អធិដ្ឋាន ថាសនោះលិចទៅដល់ពិភពកាឡនាគ ទៅទង្គិចនឹងថាសនៃព្រះពុទ្ធ ៣ ព្រះអង្គពីបុរាណ ហើយស្ទើតស៊កពីក្រោមថាសទាំង ៣ នោះ ។

១២៣-ស. កាលព្រះមហាបុរសសោយមធុបាយាសរួចហើយ តើទ្រង់យាងទៅទីណា? បានទទួលអ្វីអំពីអ្នកណា ?

ឆ. ដល់វេលារសៀលព្រះអង្គយាងទៅកាន់ពោធិព្រឹក្ស ។ តាមផ្លូវទៅ ទ្រង់បានទទួលស្បូវភ្លាំង (១) អំពីសោត្ថិយព្រាហ្មណ៍ ទ្រង់ក្រាលស្បូវភ្លាំងក្រោមដើមពោធិព្រឹក្ស ។

១២៤-ស. រតនបល្ល័ង្កមានកំពស់ប៉ុន្មានហត្ថ ? ដើមពោធិព្រឹក្សមានកំពស់ប៉ុន្មានហត្ថ ?

ឆ. រតនបល្ល័ង្កកំពស់ ១៤ ហត្ថ ។ ដើមពោធិព្រឹក្សកំពស់ ៥០ ហត្ថ ។

១២៥-ស. ចុះរតនបល្ល័ង្កនោះកើតមកអំពីស្បូវភ្លាំងមែនឬទេ ?

---

១. បាលីថា កុស ប្រែតាមទំលាប់ថា "ស្បូវភ្លាំង" តែសម្ដេចព្រះមហាសមេធាធិបតី សង្ឃនាយក ជួន-ណាត កាលនិមន្តទៅវត្តឈ្នៀបានជ្រាបថា ស្មៅស្លា អ្នកវត្តឈ្នៀហៅថា កុស ៗ ដូច្នេះ កុស គួរប្រែថា «ស្មៅស្លា» វិញទើបត្រូវ ។

ច. មិនមែនទេ, គឺដុះឡើងឯងក្នុងគ្រានោះ ដោយអំណាចព្រះបារមីនៃព្រះមហាបុរស ។

១២៦-ស. កាលព្រះមហាបុរសគង់លើរតនបល្ល័ង្កទ្រង់អធិដ្ឋានព្យាយាមមានអង្គប៉ុន្មាន ? គឺអ្វីខ្លះ ? ទ្រង់អធិដ្ឋានថាម៉េច ?

ច. មានអង្គ ៤ ។ គឺស្បែក ១ សរសៃ ១ ឆ្អឹង ១ ឈាម១ ។ ព្រះអង្គទ្រង់អធិដ្ឋានថា " ស្បែក សរសៃ ឆ្អឹង ឈាម នៃយើង ចូរឯងស្ងួតអស់ទៅចុះ បើអាត្មាអញមិនបានត្រាស់ទេ នឹងមិនក្រោកចេញពីរតនបល្ល័ង្កនេះឡើយ " ។

មារវិជ័យ

១២៧-ស. ក្នុងពេលដែលព្រះមហាបុរសគង់លើរតនបល្ល័ង្កនោះ មានអ្នកណាមកផ្ចាញ់ព្រះអង្គដែរឬទេ ? មកផ្ចាញ់នោះតើដោយអាការដូចម្ដេចខ្លះ ?

ច. មានទេវបុត្តមារមកផ្ចាញ់ ៗ នោះដោយអាការលើកទ័ពមក, ពលខាងមុខនឹងខាងឆ្វេងខាងស្ដាំ កម្រាស ១២ យោជន៍ដូចគ្នា ខាងលើកម្រាស ៩ យោជន៍ ។ ទេវបុត្តមារជិះដំរីមេខលកំពស់ ១៥០ យោជន៍ និម្មិតដៃមួយពាន់កាន់អាវុធផ្សេង ៗ ។ ចំណែកពលមារនិម្មិត

ខ្លួនប្លែកគ្នាមានពណ៌ខៀវលឿងជាដើម ពលខ្លះខ្លួនជាសត្វក្បាលជាយក្ស ពលខ្លះខ្លួនជាយក្សក្បាលជាម្រឹគបក្សីជាដើម ។

១២៨-ស. ចុះទេវបុត្តមារសំដែងឫទ្ធិផ្ចាញ់ព្រះមហាបុរសដូចម្ដេចខ្លះ ?

ច. ទេវបុត្តមារសំដែងឫទ្ធិ ៩ ប្រការគឺ ខ្យល់ព្យុះធំ ១ ភ្លៀងធំ១ ភ្លៀងដុំថ្ម ១ ភ្លៀងគ្រឿងប្រហារ ១ ភ្លៀងរងើកភ្លើង ១ ភ្លៀងផេះក្ដៅ ១ ភ្លៀងដីខ្សាច់ ១ ភ្លៀងភក់ ១ ធ្វើឲ្យងងឹតផ្សែងអ័ព្ទគ្រប់ទិសទាំងបួន ១ ។ ប៉ុន្តែហេតុទាំង ៩ នេះ មិនអាចបៀតបៀនព្រះមហាបុរសបានឡើយ ត្រឡប់ក្លាយទៅជាគ្រឿងបូជាព្រះអង្គវិញ ។

១២៩-ស. ចុះមហាបុរសឈ្នះក្រុងមារដោយអំណាចអ្វី? មានប៉ុន្មានយ៉ាង ?

ច. ព្រះអង្គឈ្នះដោយអំណាចព្រះបារមី ៣០, មហាបរិច្ចាគ ៥ នឹងចរិយា ៣ ប្រការ ។

១៣០-ស. ចុះក្រុងមារអាងអ្វីជាសាក្សី? ព្រះមហាបុរសអាងអ្វីជាសាក្សី?

ច. ក្រុងមារអាងពលយោធាជាសាក្សី ។ ព្រះមហាបុរសអាងមហាប្រឹថពីជាសាក្សី ។

១៣១-ស. កាលក្រុងមារចាញ់ព្រះមហាបុរសហើយ បានធ្វើកិរិយា

ឆ. បានលើកដៃទាំង ១ ពាន់ដាក់លើសិរសី ហើយពោលសរសើរដោយគាថាដូច្នេះថា “នមោ តេ បុរិសាជញ្ញ” ជាដើមនមស្សការយ៉ាងនេះហើយហោះរត់បាត់ទៅ ។

អភិសម្ពោធិ

១៣២-ស. រាប់តាំងពីព្រះមហាបុរសទ្រង់ព្រះផ្នួសមកប៉ុន្មានឆ្នាំ ទើបព្រះអង្គបានត្រាស់ដឹង ? ហេតុអ្វីក៏យូរដល់ប៉ុណ្ណោះ ?

ឆ. ៦ ឆ្នាំ ។ បានជាយូរដល់ប៉ុណ្ណោះ ព្រោះធម្មតានិយមឲ្យព្រះអង្គស្វែងរកសេចក្តីត្រាស់ដឹងក្នុងលទ្ធិចាស់ទាល់តែឃើញច្បាស់ថាជាផ្លូវខុស ទើបបានស្វែងរកតាមបញ្ញារបស់ព្រះអង្គ ដើម្បីជាឧបការៈដល់ការទូន្មានវេនេយ្យនិករក្នុងវេលាដែលបានត្រាស់ដឹងហើយ ។

១៣៣-ស. កាលព្រះមហាបុរសផ្ចាញ់ក្រុងមារស្រេចហើយ ក្នុងរាត្រីនោះព្រះអង្គបានញាណប៉ុន្មាន ? គឺអ្វីខ្លះ ?

ឆ. ក្នុងបឋមយាមព្រះអង្គបាននូវបុព្វេនិវាសានុស្សតិញាណគឺរឭកឃើញជាតិតាំងពី ទី១ ទី២ រហូតដល់អនេកជាតិ, ក្នុងយាមទី ២ព្រះអង្គបាននូវចុតូបបាតញាណ គឺឃើញសត្វច្យុតនិងកើត, ក្នុងយាមទី ៣ ព្រះអង្គបាននូវអាសវក្ខយញ្ញាណគឺជ្រាបការធ្វើឲ្យអស់អាសវៈ ។

១៣៤-ស. ក្នុងយាមទី ៤ ព្រះមហាបុរសបានពិចារណាធម៌អ្វី ?

ឆ. ព្រះអង្គពិចារណាបច្ចយាការមានអង្គ ១២ យ៉ាង គឺបដិច្ចសមុប្បាទធម៌ ។

១៣៥-ស. បដិច្ចសមុប្បាទធម៌នោះ មានអធិប្បាយដូចម្តេច ?

ឆ. អធិប្បាយថាធម៌មានបច្ច័យអាស្រ័យគ្នាហើយកើតឡើង គឺជរានិងមរណៈមានជាតិជាបច្ច័យ, ជាតិមានភពជាបច្ច័យ, ភពមានឧបាទានជាបច្ច័យ, ឧបាទានមានតណ្ហាជាបច្ច័យ, តណ្ហាមានវេទនាជាបច្ច័យ, វេទនាមានផស្សៈជាបច្ច័យ, ផស្សៈមានសឡាយតនៈជាបច្ច័យ, សឡាយតនៈមាននាមរូបជាបច្ច័យ, នាមរូបមានវិញ្ញាណជាបច្ច័យ, វិញ្ញាណមានសង្ខារជាបច្ច័យ, សង្ខារមានអវិជ្ជាជាបច្ច័យ ។ ជរានិងមរណៈរលត់ទៅបានព្រោះរលត់ជាតិ, ជាតិរលត់ទៅបានព្រោះរលត់ភព ។ល។ សង្ខាររលត់ទៅបានព្រោះរលត់អវិជ្ជា ។

១៣៦-ស. ព្រះមហាបុរសបានត្រាស់ដឹងនៅស្រុកណា ? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ? វេលាណា ? ក្នុងព្រះជន្មប៉ុន្មាន ?

ឆ. នៅឧរុវេលាប្រទេសសេនានិគមក្បែរឆ្នេរស្ទឹងនេរញ្ជរា, ក្នុងថ្ងៃពុធ, ពេញបូណ៌មីខែពិសាខ, ឆ្នាំរកា, វេលាជិតអរុណរះ, ក្នុងព្រះជន្មគំរប់ ៣៥ ឆ្នាំ ។

១៣៧-ស. កាលព្រះមហាបុរសបានសម្រេចនូវសព្វញ្ញុតញ្ញាណហើយ ទ្រង់បន្លឺនូវឧទានគាថាដូចម្តេច?

ឆ. ដូច្នេះ អនេកជាតិសំសារំ ។ល។ តណ្ហានំ ខយមជ្ឈគា "តថាគតកាលមិនទាន់បានជួបប្រទះ (នូវពោធិញ្ញាណ) រវល់តែស្វែងរកនូវជាងផ្ទះគឺតណ្ហាអ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅអស់សង្សារមានជាតិមិនតែមួយ, ជាតិគឺកិរិយាកើតរឿយៗ រមែងនាំមកនូវសេចក្តីទុក្ខ; ម្នាលជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) តថាគតបានឃើញអ្នកច្បាស់ហើយ, អ្នកនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ឲ្យតថាគតទៀតពុំបានឡើយ, ឆ្អឹងជំនីរគឺកិលេសទាំងឡាយទាំងអស់របស់អ្នក តថាគតបានបំបាក់ចោលហើយ, ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នក តថាគតក៏បានបំបាក់បង់ហើយ; ចិត្តរបស់តថាគតបានដល់ហើយនូវព្រះនិព្វាន ដែលមានសង្ខារទៅប្រាសហើយ, តថាគតបានដល់ហើយនូវព្រះអរហត្ត គឺការអស់ទៅនៃតណ្ហាទាំងឡាយ" ។

១៣៨-ស. ព្រះអង្គជ្រាបធម៌អ្វី បានជាប្តេជ្ញាព្រះអង្គថាត្រាស់ដឹង?

ឆ. ព្រះអង្គជ្រាបហេតុជ្រាបផល បានដល់អរិយសច្ចទាំងបួន គឺព្រះអង្គជ្រាបថា សេចក្តីកើតចាស់ស្លាប់និងយំសោក សេចក្តីកន្ត្រៀកកន្ត្រល់ចិត្តទាំងអម្បាលនេះថាជាទុក្ខ ជ្រាបថាតណ្ហាគឺសេចក្តីអន្ទះ-

អន្ទែងចង់បានជាហេតុឲ្យកើតទុក្ខ ដែលហៅថា សមុទ័យ; ជ្រាបធម៌ជាគ្រឿងរំលត់តណ្ហា ដែលហៅថា មគ្គនិរោធ ជ្រាបបដិបទាដែលជាផ្លូវបដិបត្តិឲ្យដល់នូវសេចក្តីរំលត់ទុក្ខដែលហៅថា មគ្គ (មានអង្គ ៨ គឺបញ្ញាឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ តាំងចិត្តត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ រឭកត្រូវ ១ រួមជាអរិយសច្ច ៤ គឺទុក្ខ ១ សមុទ័យ ១ និរោធ ១ មគ្គ ១ ។

១៣៩-ស. ចុះអរិយសច្ចទាំង ៤ នោះចាត់ប៉ុន្មានជាហេតុ? ប៉ុន្មានជាផល?

ឆ. ចាត់សមុទ័យនិងមគ្គពីរនេះជាហេតុ, ទុក្ខនិងនិរោធពីរនេះជាផល; សមុទ័យជាហេតុនៃទុក្ខ មគ្គជាហេតុនៃនិរោធ ។

១៤០ ស. ហេតុអ្វីបានជាព្រះអង្គមានព្រះនាមថា អរហំ សម្មាសម្ពុទ្ធោ?

ឆ. ហេតុតែព្រះអង្គបានជ្រាបអរិយសច្ចទាំង ៤ (ដូចបានឆ្លើយខាងដើមហើយ) ។

១៤១-ស. ដែលដឹងថាព្រះអង្គជ្រាបអរិយសច្ចទាំង ៤ នោះតើមានអ្វីជាគ្រឿងធានា?

ឆ. មានព្រះធម្មចក្កប្បវត្តនសូត្រជាសំខាន់, ត្រង់ព្រះពុទ្ធដីកាថា "កាលណា បញ្ញាការដឹងការឃើញតាមសភាវៈពិត ក្នុងអរិយសច្ចទាំង ៤ នេះ របស់តថាគតហ្មត់ចត់ល្អហើយ កាលនោះតថាគតអាចប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ឥតអ្នកណាប្រៀបស្មើក្នុងលោក" ។

ពោធិសព្វញ្ញូ

១៤២ ស. កាលព្រះសាស្តាបានត្រាស់ដឹងថ្មី ៗ ទ្រង់គង់នៅកន្លែងណាខ្លះ ? ចំនួនប៉ុន្មានថ្ងៃ ?

ឆ ទ្រង់គង់នៅក្នុងទីទាំង ៧ ដែលហៅថាសត្តមហាឋាន គឺទី ១ គង់លើរតនបល្ល័ង្កក្រោមពោធិព្រឹក្ស ៧ ថ្ងៃ ។ ទី ២ គង់ក្នុងអនិមិសចេតិយដ្ឋាន ទតរតនបល្ល័ង្កនោះ ដោយព្រះនេត្រមិនប៉ព្រិចអស់ ៧ ថ្ងៃ ។ ទី ៣ គង់ក្នុងរតនចេតិយដ្ឋាន គឺព្រះអង្គយាងចង្ក្រមលើទីចង្ក្រមកែវអស់ ៧ ថ្ងៃ ។ ទី ៤ គង់ក្នុងរតនឃរចេតិយដ្ឋាន គឺផ្ទះកែវទ្រង់ពិចារណានូវបិដកទាំង ៣ អស់ ៧ ថ្ងៃ ។ ទី ៥ គង់ក្រោមដើមអជបាលនិគ្រោធ ទ្រង់ពិចារណាធម៌ដែលព្រះអង្គបានត្រាស់ដឹងអស់ ៧ ថ្ងៃ ។ ទី ៦ គង់ក្បែរឆ្នេរមុច្ចលិន្ទស្រះអស់ ៧ ថ្ងៃ ។ ទី ៧ គង់ក្រោមដើមកែសអស់ ៧ ថ្ងៃ ។ រួមថ្ងៃក្នុងទីទាំង ៧ នោះ ត្រូវជា ៤៩ ថ្ងៃ ។

១៤៣- ស. ចុះក្នុង ៤៩ ថ្ងៃនោះ ព្រះអង្គសោយចង្ហាន់ដែរឬទេ? ព្រោះហេតុអ្វី ?

ឆ. ឥតសោយចង្ហាន់ទេ, ព្រោះព្រះអង្គឆ្អែតដោយវិមុត្តិសុខ ។

១៤៤- ស. កាលព្រះសាស្តាគង់ក្រោមអជបាលនិគ្រោធ មានអ្នកណាចូលទៅគាល់ព្រះអង្គដែរឬទេ ?

ឆ. មានទេវបុត្តមារ ចូលទៅក្រាបទូលអារាធនាឲ្យព្រះអង្គបរិនិព្វាន ។ បន្ទាប់ពីនោះមក មារធីតាទាំង ៣ នាក់ គឺនាងតណ្ហា ១ អរតី ១ រាគា ១ ចូលមកចែចង់ព្រះអង្គទៀត ។

១៤៥- ស. ត្រង់ដែលថា ព្រះសាស្តាគង់ក្នុងផ្ទះកែវនោះ គឺមានផ្ទះកែវមែនឬទេ ?

ឆ. មិនមែនទេ ។ ផ្ទះកែវរបស់ព្រះអង្គជាវិការៈនៃព្រះសទ្ធម្មទាំងអស់គឺសតិបដ្ឋាន ៤ ជាភូមិភាគ, ឥទ្ធិបាទ ៤ ជាសសរ, វិនយបិដកជាជញ្ជាំង, សម្មប្បធាន ៤ ជាក្រប, សមាបត្តិ ៨ ជារតនឹងផ្ទៃ សុត្តន្តបិដកជាគ្រឿងដំបូល, អភិធម្មបិដកជាគ្រឿងប្រក់ ។

១៤៦- ស. ដែលថាព្រះសាស្តាមានរស្មី ៦ ពណ៌នោះ តើគឺពណ៌អ្វីខ្លះ ?

ឆ. គឺពណ៌ខៀវ ១ លឿង ១ ក្រហម ១ ស ១ ហង្សបាទ ១ ផ្លេក ៗ ១ ។

១៤៧-ស. កាលព្រះសាស្ដាគង់ក្រោមដើមកែស មានអ្នកណាយកវត្ថុអ្វីមកថ្វាយដែរឬទេ ?

ឆ. ព្រះឥន្ទយកផ្លែសម៉ ឈើស្ទន់នឹងទឹកមកថ្វាយព្រះសាស្ដា ។ បន្ទាប់ពីព្រះឥន្ទមក ពាណិជ ២ នាក់ ជាបងប្អូននឹងគ្នា បងឈ្មោះតបុស្សៈ ប្អូនឈ្មោះភល្លិកៈ បានយកសដូវដុំសដូវផង់មកថ្វាយព្រះសាស្ដា ។ ទ្រង់ប្រទានព្រះកេសធាតុ ៨ សរសៃឲ្យពាណិជនោះយកទៅបញ្ចុះក្នុងសិន្ទុក្ករចេតិយ ដើម្បីធ្វើសក្ការបូជា ។

១៤៨-ស. កាលដែលព្រះសាស្ដាទទួលសដូវពីពាណិជនោះ តើទ្រង់ទទួលដោយអ្វី ?

ឆ. ទ្រង់ទទួលដោយបាត្រថ្មដែលស្ដេចចតុលោកបាលយកមកថ្វាយ ។

១៤៩-ស. ទីសិន្ទុក្ករចេតិយនោះ គេបានបញ្ចុះវត្ថុអ្វីខ្លះ ?

ឆ. គេបានបញ្ចុះគ្រឿងបរិក្ខារនៃព្រះពុទ្ធ ៤ ព្រះអង្គ ក្នុងភទ្ទកប្បនេះ គឺបញ្ចុះធម្មក្រករបស់ព្រះពុទ្ធកកុសន្ធៈ ១ វត្ថពន្ធរបស់ព្រះ

ពុទ្ធកោនាគមនៈ ១ សាដករបស់ព្រះពុទ្ធកស្សបៈ ១ ព្រះកេសធាតុ ៨ សរសៃរបស់ព្រះពុទ្ធគោតម ១ ។

១៥០ ស. សិន្ទុក្ករចេតិយ គេធ្វើនៅស្រុកណា ?

ឆ. នៅក្នុងស្រុកភូមា ។

១៥១-ស. អ្នកណាជាឧបាសកមុនគេបំផុត ? ហៅថាអ្វី ?

ឆ. ពាណិជ ២ នាក់ គឺតបុស្សៈ នឹងភល្លិកៈ ដល់នូវសរណគមន៍ ២ ពីព្រះពុទ្ធនឹងព្រះធម៌ ហៅថាទ្វេវាចិកសរណគមន៍ ។

ព្រហ្មជ្ញៀសនៈ

១៥២-ស. ព្រះទ័យនៃព្រះសាស្ដាពេញពោរទៅដោយព្រះមហាករុណាមែនឬទេ ? ហេតុម្ដេចកាលព្រះអង្គបានត្រាស់ដឹងហើយ ត្រឡប់ជារួញរាព្រះទ័យក្នុងការសំដែងធម៌ទៅវិញ ? ខាងក្រោយមកទ្រង់ព្រះតម្រិះដូចម្ដេច បានជាទ្រង់អធិដ្ឋានព្រះទ័យថា នឹងទ្រង់សំដែងធម៌ប្រោសសត្វ ?

ឆ. រឿងនេះជាសេចក្ដីពិត, ព្រះសាស្ដានៃយើងទ្រង់ពេញពោរទៅដោយព្រះមហាករុណាមែន ។ ប៉ុន្តែ កាលព្រះអង្គបានត្រាស់ដឹងហើយត្រឡប់ជាមានព្រះទ័យរួញរាទៅវិញនោះ គ្រាន់តែមានក្នុងមួយ

ខណៈចិត្តប៉ុណ្ណោះទេ ដោយទ្រង់ព្រះតម្រិះថាធម៌ដែលតថាគតបានត្រាស់ដឹងហើយនោះជ្រាលជ្រៅណាស់ កម្រពួកសត្វអ្នកមានកិលេសដូចធូលីមានរាគៈជាដើម នឹងដឹងបានដោយឆាប់រហ័ស ។ ក្នុងករណីដូច្នេះ កុំថាតែព្រះបរមសាស្តា ដែលបានត្រាស់ដឹងធម៌ដ៏ល្អិតសុខុមហើយទ្រង់រស់ឯកក្នុងការសំដែងធម៌នេះឡើយ សូម្បីតែអ្នកដែលស្ម័គ្រចិត្តនឹងប្រព្រឹត្តតាមព្រះអង្គហើយ គេក៏គង់ធ្វើតាមទៅបានដោយលំបាក ព្រោះការប្រាសក្រ-បែលកិលេសរបស់សត្វអ្នកក្រាសទៅដោយរាគៈ ទោសៈ មោហៈ មិនមែនជាវិស័យកំចាត់បានងាយទេ ។ ហេតុនេះ កាលព្រះសាស្តាបានត្រាស់ដឹងហើយត្រូវមានព្រះទ័យរួញរាដូច្នោះ ។ សូម្បីតែសាមញ្ញជនអ្នកបានសិក្សាវិជ្ជាការណាខ្លះ ឬធ្វើការងារប្រភេទខ្លះដែលត្រូវរងទុក្ខលំបាកយ៉ាងច្រើន លុះបានសម្រេចហើយ គង់តែមានចិត្តរួញរាធុញទ្រាន់ខ្លះដូចគ្នាថាការងារបែបនេះ អ្នកមិនមានព្យាយាមនឹងមិនមានអំណត់ទេ មុខជាមិនអាចនឹងធ្វើឲ្យសម្រេចបានឡើយ ។

វេលាខាងក្រោយ ព្រះអង្គទ្រង់ពិចារណាឃើញថា វេនេយ្យសត្វមានប្រភេទច្រើនយ៉ាង គឺបុគ្គលខ្លះមានកិលេសស្រាលស្តើង ខ្លះមានកិលេសក្រាស់ ខ្លះមានឥន្ទ្រិយគឺសទ្ធា, វីរិយ, សតិ, សមាធិ, បញ្ញា ខ្លះមានឥន្ទ្រិយទន់ ខ្លះមានអាការល្អ ខ្លះមានអាការអាក្រក់ ខ្លះប្រដៅ-

ងាយ ខ្លះប្រដៅក្រ ខ្លះអាចនឹងដឹងបាន ខ្លះមិនអាចនឹងដឹងបាន, អ្នកមានគុណសម្បត្តិដូច្នោះជាប្រមាណ យ៉ាងកណ្តាល បានទទួលអប់រំក្នុងបដិបទាដ៏ជាបុព្វភាគទាល់តែមានឧបនិស្ស័យ ក៏នៅតែគួរបានទទួលការណែនាំក្នុងធម៌ជាន់ទាបជាមុន ដើម្បីឲ្យកើតមានឧបនិស្ស័យ, កាលបើដូច្នោះ ការទ្រង់សំដែងធម៌មុខជាមិនឥតផល អាចឲ្យសម្រេចប្រយោជន៍ដល់មនុស្សគ្រប់ពួកបាន វៀរលែងតែពួកដែលមិនមែនជាវេនេយ្យសត្វ ។ ព្រះសាស្តាមានព្រះញាណឃើញហេតុឆ្ងាយទ្រង់ព្រះចិន្តាដូចបានពោលមកហើយនេះ បានជាទ្រង់តាំងព្រះទ័យថានឹងសំដែងធម៌ប្រោសសត្វ ។

១៥៣–ស. ព្រះបរមសាស្តា កាលនឹងទ្រង់ទេសនាប្រោសវេនេយ្យជនទ្រង់ប្រៀបនឹងផ្កាឈូក ៤ យ៉ាង, រឿងនេះដោយមានព្រះពុទ្ធបំណងដូចម្តេច ? ចូររៀបរាប់មកមើល !

ច. ដោយព្រះអង្គមានព្រះបំណងថា នឹងមិនទេសនាទុកខាន សត្វទេ ព្រោះទ្រង់ឃើញថា ធម៌ដែលព្រះអង្គត្រាស់ដឹងនោះជ្រាលជ្រៅណាស់ សត្វដែលមានអាល័យគឺកិលេសកម្រនឹងដឹងតាមបាន ។ តែខាងក្រោយព្រះអង្គនឹកដល់បុគ្គល ៤ ពួក គឺឧគ្ឃដិតញ្ញូ បានដល់បុគ្គលដែលបានស្តាប់ធម៌លោកអ្នកប្រាជ្ញសំដែងចប់ហើយ ក៏បានដឹងយល់ភ្លាម

ប្រៀបដូចផ្កាឈូកគ្រាន់តែត្រូវកំដៅព្រះអាទិត្យក៏រីកមួយរំពេច នេះជាក់ជាពួកមួយ ។ វិបចិតញ្ញូ បានដល់បុគ្គលដែលបានស្ដាប់ធម៌អ្នកប្រាជ្ញសំដែង ទាល់តែលោកចែករំលែកសេចក្ដីនោះឲ្យល្អិតចេញទៅទៀត ទើបបាននឹងយល់ ប្រៀបដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃស្អែក នេះជាក់ជាពួកមួយ ។ នេយ្យបុគ្គល បានដល់វេនេយ្យសត្វដែលលោកជាសាស្ដាដឹកនាំពន្យល់ខ្លួនរឿយ ៗ ទៅ ដើម្បីឲ្យបានសម្រេចមគ្គផល ដូចផ្កាឈូកដែលនឹងរីកក្នុងថ្ងៃខាងមុខ ៗ ទៅ នេះជាក់ជាពួកមួយ ។ បទបរមបុគ្គល បានដល់សត្វអ្នកស្ដាប់ធម៌ចាំមិនបាន ទាំងមិនចង់បដិបត្តិតាម ប្រៀបដូចផ្កាឈូកដែលនឹងទៅជាចំណីនៃត្រីនឹងអណ្ដើកដូច្នោះ នេះជាក់ជាពួកមួយ ។

១៥៤ ស. អ្នកណាចូលទៅអារាធនាព្រះសាស្ដាឲ្យសំដែងធម៌ប្រោសសត្វ ? កាលព្រះអង្គគង់ក្នុងទីណា?

ប. សហម្បតិព្រហ្មចូលអារាធនា ។ ក្នុងគ្រាព្រះអង្គគង់ក្រោមដើមអជបាលនិគ្រោធ ។

ធម្មចក្កប្បវត្តនទេសនា

១៥៥-ស. កាលព្រះសាស្ដាគាំងព្រះទ័យថានឹងសំដែងធម៌ប្រោសសត្វហើយទ្រង់នឹកដល់អ្នកណាមុនគេ ?

ប. ទ្រង់នឹកដល់អាឡារតាបស កាលាមគោត្រ នឹងឧទក. តាបសរាមបុត្រមុនគេ រួចទ្រង់ជ្រាបថា តាបសទាំង ២ រូបនោះក្ស័យជីវិតហួសទៅហើយ ។

១៥៦-ស. ព្រះសាស្ដាសំដែងធម៌ប្រោសអ្នកណាមុនគេបំផុត ?

ប. ប្រោសបញ្ចវគ្គិយភិក្ខុមុនគេបំផុត ។

១៥៧ – ស. ចុះព្រះអង្គសំដែងធម៌អ្វី ប្រោសបញ្ចវគ្គិយភិក្ខុនោះ ? នៅកន្លែងណា ? ក្នុងស្រុកណា ?

ប. ទ្រង់សំដែងធម្មចក្រ ។ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន, ទៀបនគរពារាណសី ។

១៥៨ – ស. ចុះបណ្ដាបញ្ចវគ្គិយភិក្ខុទាំងនោះ តើលោកណាបានឃើញធម៌មុនគេ? ហើយលោកឃើញដូចម្ដេច ?

ប. ព្រះអញ្ញាកោណ្ឌញ្ញៈជាប្រធាននៃពួកភិក្ខុបញ្ចវគ្គិយ បានធម្មចក្ខុឃើញធម៌មុនគេ ។ លោកឃើញថា របស់ណាមួយ ដែលបច្ច័យប្រជុំតាក់តែងហើយរបស់នោះទាំងអស់ សុទ្ធតែជាទុក្ខមិនមែនខ្លួនប្រាណ, របស់ណាមួយកើតឡើងហើយ របស់នោះទាំងអស់ មានសេចក្ដីរលត់វិញជាធម្មតា

១៥៩- ស. ភិក្ខុបញ្ចវគ្គិយទាំងនោះបានសម្រេចព្រះអរហត្ត ព្រោះបានស្តាប់ធម៌ទេសនាអ្វី ? ធម៌នោះនិយាយពីអ្វី ? ចូរឆ្លើយឲ្យល្អ ស្តាប់បាន !

ឆ. ព្រោះបានស្តាប់ធម៌ទេសនា ហៅថាអនត្តលក្ខណសូត្រ ។ និយាយពីខ្លួនមិនទៀងថា: រាងកាយរបស់យើងនេះ ជារបស់មិនទៀងទាត់ មានសេចក្តីរលត់ នឹងសេចក្តីបែកធ្លាយទៅជាធម្មតា កាលបើមិនទៀងហើយក៏ជាទុក្ខ កាលជាទុក្ខហើយនឹងប្រកាន់ថាជាខ្លួនជាប្រាណជាយើង ជារបស់យើង គឺជាការមិនសមគួរ ។

១៦០- ស. ហេតុដូចម្តេចក្នុងព្រះធម៌ទេសនានោះ បានជាព្រះអង្គលើកខ្លួនឡើងបដិសេ ?

ឆ. ហេតុតែសេចក្តីចូលចិត្តរបស់មនុស្សទូទៅថា មានធម៌ជាតំមួយដែលហៅថា អត្តា ប្រែថា "ខ្លួន" ជាសភាពទៀងទាត់ស្ថិតស្ថេរ មិនចេះស្លាប់ សឹងនៅក្នុងរាងកាយរបស់សត្វ ដល់វេលាមរណៈ រាងកាយនោះទ្រុឌទ្រោមបាត់ទៅ, ចំណែកអត្តានោះ ចេញចាករាងកាយទៅចូលក្នុងសរីរៈដែលកើតឡើងថ្មី ។ ព្រះអង្គត្រាស់បដិសេធអត្តានេះ ដើម្បីនឹងសំដែងឲ្យឃើញហេតុនឹងផលដែលអាស្រ័យ អាយតនៈខាងក្នុងមានចក្ខុ

ជាដើម អាយតនៈខាងក្រៅមានរូបជាដើមមកខ្ទប់គ្នា កើតវិញ្ញាណឡើង ហើយកើតសម្ផស្ស វេទនា សញ្ញា សញ្ចេតនា វិតក្កៈ វិចារៈ តទៅ ប្រព្រឹត្តទៅដោយធម្មតា អ្នកណានឹងប្រាថ្នាធ្វើឲ្យខុសពីធម្មតាទៅមិនបាន តែថាបញ្ចក្ខន្ធនេះមានអ្វីជាមូលហេតុដឹងមិនបាន ដែលហៅថា អវិជ្ជា ខាងដើមរបស់អវិជ្ជាមិនប្រាកដ ។

១៦១- ស. គួរឲ្យឆ្ងល់ដែរ, បើព្រះអង្គទ្រង់ប្រកបអត្តកិលមថានុយោគមកជាយូរហើយ ដល់វេលាទេសនាជាដំបូងហេតុម្តេចក៏បែរជាទ្រង់តិះដៀលអត្តកិលមថានុយោគទៅវិញ ?

ឆ. ហេតុតែទ្រង់ប្រកបមកជាយូរហើយ ពុំបានសម្រេចប្រយោជន៍អ្វីសោះ ទើបទ្រង់តិះដៀលដូច្នោះ ។

១៦២- ស. ព្រះសាវ័កទាំងឡាយអ្នកបានត្រាស់ដឹងធម៌មិនចំពោះតែព្រះអញ្ញាកោណ្ឌញ្ញៈ១ អង្គប៉ុណ្ណោះទេ ចុះហេតុអ្វីបានជាព្រះបរមសាស្តាទ្រង់បន្លឺឧទានថា"អញ្ញាសិវតភោកោណ្ឌញ្ញោ"ចំពោះតែព្រះកោណ្ឌញ្ញៈ១ អង្គប៉ុណ្ណោះ? ចូរប្រាប់តាមសេចក្តីយល់ឃើញឲ្យជាក់ច្បាស់មកមើល !

ឆ. ព្រះអញ្ញាកោណ្ឌញ្ញៈជាព្រះសាវ័កមុនដំបូងដែលបានត្រាស់ដឹងធម៌ជាបន្ទាល់របស់សេចក្តីសម្រេចនៃការតាំងព្រះទ័យរបស់ព្រះ

អង្គ ។ ធម្មតាអ្នកធ្វើកិច្ចការអ្វី ដែលដឹងថាលំបាក កាលបើខំប្រឹងធ្វើទៅ ទាល់តែបានឃើញត្រើយនៃសេចក្តីសម្រេច ក៏រមែងកើតចិត្តរីករាយថា បានការហើយឬបន្លឺឧទានថា សម្រេចដូចចិត្តប៉ងហើយ ។ ព្រះសាស្តាទ្រង់ចំពេញបារមីមកជាយូរណាស់ ទម្រាំតែនឹងបានសម្រេចសែនក្រសែនលំបាក ដើម្បីនឹងទ្រង់សំដែងធម៌ប្រោសសត្វឲ្យបានត្រាស់ដឹងតាម ទាំងទ្រង់មានព្រះពុទ្ធបរិវិតក្កជាយូរហើយថា ព្រះធម៌ដែលព្រះអង្គត្រាស់ដឹងជារបស់ល្អិតសុខុមជ្រាលជ្រៅ សត្វកម្រនឹងត្រាស់ដឹងបាន ។ ប៉ុន្តែអាស្រ័យព្រះទ័យប្រកបដោយករុណា ទើបបានតាំងអធិដ្ឋានបួងព្រះឆន្ទទៅក្នុងការសំដែងធម៌ប្រោសសត្វ ។ ការតាំងព្រះទ័យរបស់ព្រះអង្គនឹងបានសម្រេចផលនោះក៏ដោយសារតែមានអ្នកត្រាស់ដឹងតាម សូម្បីមិនច្រើនត្រឹមតែមួយនាក់ក៏គង់តែទុកជាឧទាហរណ៍ ដែលនឹងត្រាស់ប្រោសអ្នកដទៃទៅទៀតបានព្រោះថាបើមានអ្នកណាម្នាក់បានដឹងហើយ មុខជាមានអ្នកណាម្នាក់ទៀតបានដឹងតៗគ្នាទៅ ។ អ្នកត្រាស់ដឹងតាមជាដំបូងបាក់ជាបន្ទាល់សំខាន់ដែលនឹងឲ្យសន្និដ្ឋានថាការប្រកាសសាសនាតទៅមិនមែនជាដំណែល ។ ព្រះអញ្ញាកោណ្ឌញ្ញៈជាព្រះសាវ័កអង្គដំបូងបានត្រាស់ដឹងធម៌ ជាបន្ទាល់សាក្សីរបស់សេចក្តីសម្រេចនៃការតាំងព្រះទ័យរបស់ព្រះអង្គ ទើបបានទ្រង់បញ្ចេញឧទានថា "អញ្ញាសិ វត ភោ កោណ្ឌញ្ញោ" ដូចជា

ត្រាស់ថា "បានការហើយ" ឬទ្រង់បន្លឺឧទានថា "សម្រេចការហើយ" ដូច្នោះដែរ ។

១៦៣-ស. ធម្មចក្កប្បវត្តនសូត្រ, អនត្តលក្ខណសូត្រ និង អាទិត្តបរិយាយសូត្រ ព្រះសាស្តាទ្រង់សំដែងប្រោសអ្នកណា? ក្នុងទីណា ?

ឆ. ធម្មចក្កប្បវត្តនសូត្រ និង អនត្តលក្ខណសូត្រទ្រង់សំដែងប្រោសបញ្ចវគ្គិយភិក្ខុ ក្នុងព្រៃឥសិបតនមិគទាយវ័នក្បែរពារាណសី, អាទិត្តបរិយាយសូត្រ ទ្រង់សំដែងប្រោសភិក្ខុបុរាណជដិល ១ ពាន់ ៣ អង្គ មានព្រះឧរុវេលកស្សបៈជាដើម ក្បែរឆ្នេរស្ទឹងគយាសីសប្រទេស ដែនមគធៈ ។

១៦៤-ស. ចុះមានហេតុដូចម្តេច បានជាព្រះសាស្តាទ្រង់លើកអាទិត្តបរិយាយសូត្រឡើងសំដែងប្រោសពួកភិក្ខុបុរាណជដិល ?

ឆ. ខ្ញុំចូលចិត្តថា ទ្រង់សំដែងដើម្បីឲ្យត្រូវនឹងអជ្ឈាស្រ័យរបស់បុរាណជដិលដែលជាអ្នកធ្លាប់បូជាភ្លើងជារបស់គេ ។

១៦៥-ស. ហេតុអ្វីព្រះសាស្តាកាលបានត្រាស់ដឹងហើយ មិនយាងទៅប្រោសព្រះពុទ្ធបិតាមាតានិងព្រះញាតិវង្សមុនជនឯទៀត ?

ឆ. ហេតុតែទ្រង់យល់ឃើញថា គួរប្រតិស្ឋានព្រះពុទ្ធសាសនាទុកក្នុងមគធជនបទជាមុនសិន ព្រោះជាដែនធំមានអំណាចព្រម-

ទាំងបរិបូណ៌ដោយសម្បត្តិ មានប្រជាជនច្រើនកុះករ ទាំងជាទីកំនៅនៃពួកគ្រូមេលទ្ធិជាច្រើន កាលបើពួកគ្រូទាំងនោះមកចុះចូលព្រះអង្គហើយ ព្រះអង្គងាយនឹងទូន្មានអ្នកដទៃតទៅទៀត ៗ មួយទៀតមនុស្សក្នុងជាន់នោះ ច្រើនមានទិដ្ឋិមានះប្រកាន់ថាខ្លួនជាពួកអ្នកធំ គឺជាបិតាមាតាជីដូនជីតាម៉ាមីងរបស់ព្រះអង្គ ៗ បើព្រះអង្គបានត្រាស់ដឹងហើយ រួចយាងត្រង់ទៅប្រដៅពួកសាក្យរាជក្នុងក្រុងកបិលព័ស្តុតែម្តង រមែងជាការលំបាកច្រើន ឬនឹងមិនបានសម្រេចផល ព្រោះលោកទាំងនោះកំពុងពេញទៅដោយទិដ្ឋិមានះប្រកាន់ថាជាអ្នកធំ ថែមទាំងមិនទាន់បាត់ទឹងក្នុងរឿងព្រះអង្គស្តេចចេញបួស ដែលគេសំគាល់ថាជាការប្រព្រឹត្តិបន្ទាបវង្សត្រកូលផង ៗ រួមឲ្យខ្លីថាឧបនិស្ស័យឥន្ទ្រិយរបស់លោកទាំងនោះ នៅមិនទាន់ចាស់ក្លា លុះកាលណាព្រះអង្គស្តេចទៅប្រោសអ្នកនេះអ្នកនោះ ឲ្យបានសម្រេចប្រយោជន៍ ទាល់តែព្រះកិត្តិគុណសេចក្តីល្អរបស់ព្រះអង្គល្បីទៅដល់ពួកសាក្យរាជ ៗ បាត់ទឹងកើតមានចិត្តស្រឡាញ់រាប់អានឡើងវិញ ស្តេចមកប្រោសវេលាខាងក្រោយទើបជាការងាយ ៗ ដោយហេតុដូចពោលមកនេះឯង ដែលបណ្តាលមិនឲ្យព្រះអង្គស្តេចទៅប្រោសពួកសាក្យរាជមុនគេ ៗ

១៦៦-ស. មានពួកមិច្ឆាទិដ្ឋិចោទថា ព្រះពុទ្ធមុននឹងទ្រង់ទូន្មានធម៌ដល់អ្នកណា ៗ ឬមុនត្រាស់សន្ទនានឹងអ្នកណា ៗ ដូចកាលមុននឹងទ្រង់សម្តែងធម្មចក្កក្តី មុនត្រាស់ទេសនាដល់ឧបកាជីវកក្តី ច្រើនតែលើកខ្លួនអួតខ្លួនថា តថាគតជាអ្នកប្រសើរយ៉ាងនោះយ៉ាងនេះ គឺថាតថាគតដឹងធម៌យ៉ាងនោះយ៉ាងនេះជាដើម បើដូច្នោះតើយើងនឹងឆ្លើយដោះសាថាម៉េចឲ្យផុតពីពាក្យគេចោទនោះ ?

ឆ. រឿងនេះ យើងគួរឆ្លើយថា កាលបើពិចារណាមើលតែអាការខាងក្រៅសើរ ៗ ក៏ឃើញត្រូវដូចជាគេចោទនោះមែន ៗ ប៉ុន្តែសេចក្តីពិតមិនមែនដូច្នោះទេ, ការណ៍ដែលព្រះអង្គលើកគុណសេចក្តីល្អរបស់ព្រះអង្គឡើងប្រកាសជាមុនដំបូងនោះ ដោយទ្រង់ព្រះមេត្តាប្រាថ្នានឹងឲ្យអ្នកស្តាប់ជឿមាំក្នុងព្រះអង្គជាមុន គឺធ្វើឲ្យអ្នកស្តាប់មានសេចក្តីជឿចំពោះការចេះដឹងនឹងការអង់អាចរបស់ព្រះអង្គ កាលបើអ្នកស្តាប់ជឿព្រះអង្គថាល្អមែនហើយ វេលាព្រះអង្គនឹងទ្រង់ប្រដៅអ្វី ក៏គង់ប្រព្រឹត្តតាមជាហេតុនាំប្រយោជន៍មកឲ្យដល់ខ្លួនឯង ៗ បើអ្នកស្តាប់មិនជឿព្រះអង្គថាល្អមែនថាចេះដឹងមែនទេ កាលណាឡើយគេនឹងធ្វើតាម ៗ ដូចកាលព្រះអង្គមុននឹងទេសនាប្រោសបញ្ចវគ្គិយភិក្ខុ បើព្រះអង្គធ្វើមិនឲ្យបញ្ចវគ្គិយភិក្ខុឃើញអនុភាពសម្ពោធិញ្ញាណនៃព្រះអង្គបានហើយ កាលណា

ឡើយ បញ្ចវគ្គិយភិក្ខុនឹងតាំងចិត្តស្ដាប់ព្រះធម៌ក្របាន មុខជានិយាយចាក់ដោតដោយប្រការផ្សេងៗ ហើយសំដែងអាការៈមិនគោរពចំពោះព្រះអង្គផង ។ ប្រសិនជាព្រះអង្គសំដែងឲ្យអ្នកមិនជឿដូច្នោះស្ដាប់ ក៏ហាក់ដូចជាផ្លុំខ្លុយក្របីស្ដាប់ ធម៌នោះក៏ឥតអំពើគ្មានផលដល់អ្នកស្ដាប់ដូចឧបកា-ជីវកមិនជឿព្រះអង្គថាជាអ្នកប្រសើរមែន សូម្បីជួបព្រះអង្គត្រង់កណ្ដាលផ្លូវ ព្រមទាំងចរចានឹងព្រះអង្គផង អាជីវកនោះក៏ឥតបានផលអ្វីដែរ ព្រោះតែខ្វះសេចក្ដីជឿនោះឯង ។ កជាគតពោធិសទ្ធា ជារបស់សំខាន់នៃអ្នកកាន់ព្រះពុទ្ធសាសនា ព្រោះហេតុនោះព្រះបរមសាស្ដារបស់យើងទើបទ្រង់ប្រកាសសេចក្ដីត្រាស់ដឹង នឹងសេចក្ដីល្អរបស់ព្រះអង្គជាមុនពេលសំដែងធម៌ ។ ប៉ុន្តែ បើអ្នកស្ដាប់ជឿព្រះអង្គស៊ប់ហើយ ព្រះអង្គក៏មិនប្រកាសទៀតទេ ដូចកាលមុននឹងសំដែងអនត្តលក្ខណសូត្រ ព្រះអង្គមិនត្រាស់ដូច្នោះទៀតឡើយ ព្រោះបញ្ចវគ្គិយភិក្ខុតាំងនៅក្នុងសេខភូមិសោតាបន្នអរិយបុគ្គលហើយ ។ បើព្រះអង្គជាអ្នកអំនួតមែន ក៏មុខជាចេះតែអួតប្រាប់អ្នកនេះ រួចប្រាប់អ្នកនោះឥតរើសមុខ ។ ហេតុនេះ នឹងថាព្រះអង្គជាអ្នកអំនួតមិនត្រូវទេ គួរនឹកដល់ព្រះមហាករុណាធិគុណឲ្យកាន់តែច្រើនឡើងថែមទៀត ។

១៦៧-ស. ក្នុងវស្សាត្រាស់ដឹងថ្មី ៗ ព្រះសាស្ដាបានធ្វើអ្វីឲ្យជាប្រយោជន៍ដ៏ធំសមគួរដែលព្រះអង្គបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ គួរឲ្យយើងយកមកទុកដាក់ក្នុងចិត្តធ្វើជាគំរូបាន ?

ឆ. រាប់តាំងពីថ្ងៃ ១៤ កើតខែវេសាខ ស្ដេចទៅកាន់ព្រៃឥសិបតនមិគទាយវ័ន គង់ចាំវស្សានៅទីនោះ លុះដល់បញ្ជូនសាវកទៅប្រកាសព្រះសាសនាក្នុងនានាប្រទេស ព្រះអង្គក៏យាងទៅកាន់ឧរុវេលាប្រទេសក្នុងវេលាចេញវស្សាហើយ ។ ក្នុងរយៈកាលនេះ ទ្រង់បានសំដែងធម៌ នឹងប្រទានឧបសម្បទដល់សាវកឲ្យសម្រេចអរហត្តដល់ ៦០ អង្គ គឺបញ្ចវគ្គិយភិក្ខុ៥, ព្រះយស១, សំឡាញ់ព្រះយស៤នឹងសំឡាញ់ព្រះយស៥០ទៀត ។ ទ្រង់ឲ្យមាតាបិតានឹងភរិយាព្រះយសដល់នូវព្រះរតនត្រ័យជាសរណៈជាឧបាសកម្នាក់ ជាឧបាសិកាក្នុងលោកជាដំបូង ២ នាក់ ។

១៦៨-ស. ពាក្យសរសើរព្រះគុណនៃព្រះសាស្ដា មានពាក្យមួយថាព្រះអង្គឈ្លាសវៃក្នុងវិធីទេសនា ទ្រង់សំដែងធម៌ត្រូវតាមកាល, ទេសៈ ទាំងត្រូវអធ្យាស្រ័យរបស់សត្វ សម្រេចប្រយោជន៍ដល់មនុស្សគ្រប់ជាន់, ដូច្នេះចូររើសយករឿងណាមួយមកជាឧទាហរណ៍ ហើយឆ្លើយជាសំអាងក្នុងពាក្យនេះមើល !

ឆ. សូមលើកឧទាហរណ៍មួយថា កាលព្រះសាស្តាទ្រង់សំដែងបឋមទេសនា ប្រោសបញ្ចវគ្គិយ, មហាជនក្នុងគ្រានោះរាប់អានលទ្ធិសាសនាព្រាហ្មណ៍ រមែងសរសើរអត្តកិលមថានុយោគ និងកាមសុខល្លិកានុយោគថា ជាផ្លូវឲ្យសម្រេចធម៌វិសេសបាន ។ ឯបព្វជិតក្នុងគ្រានោះ មានព្រះបញ្ចវគ្គិយជាដើម ក៏ដក់ចិត្តស៊ប់នៅក្នុងផ្លូវទាំងពីរយ៉ាងជាខ្លាំង ។ កាលព្រះសាស្តាបានទំព្យាយាមធ្វើហួសដល់ទីបំផុតហើយ មិនបានសម្រេចផលអ្វីក៏ទ្រង់លះបង់ចេញ ព្រះអង្គបែរមកធ្វើដំណើរតាមមជ្ឈិមាបដិបទាវិញ ក៏បានត្រាស់ដឹងធម៌វិសេស ហើយយកមកសំដែងប្រាប់ព្រះបញ្ចវគ្គិយភិក្ខុ ដែលជាអ្នកជួនចិត្តទៅក្នុងអត្តកិលមថានុយោគនោះ ទើបគួរហៅថាត្រូវតាមកាលៈទេសៈ ទាំងត្រូវតាមឧបនិស្ស័យរបស់សត្វ ទ្រង់ញ៉ាំងព្រះបញ្ចវគ្គិយភិក្ខុឲ្យមានសេចក្តីជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាបាន; ក្នុងទីបំផុត លោកទាំងនោះ បានសម្រេចធម៌វិសេសដោយបានស្តាប់អនត្តលក្ខណសូត្រ ។

មានឧទាហរណ៍មួយទៀតថា ជដិលកស្សប ៣ នាក់ ជាបងប្អូន ប្រកាន់ខ្លួនថាជាព្រះអរហន្ត បំពេញពិធីបូជាយញ្ញ គឺដុតភ្លើងបូជាសែនព្រេនតាមលទ្ធិរបស់សាសនាព្រាហ្មណ៍ ។ កាលព្រះសាស្តាស្តេចយាងទៅប្រោស បានទ្រង់សំដែងអាទិត្តបរិយាយសូត្រសំដែងថា របស់ទាំងពួង

គឺអាយតនៈខាងក្នុងនិងខាងក្រៅ មានចក្ខុនិងរូបជាដើមជារបស់ក្តៅខ្លោច ជាការត្រូវនឹងអធ្យាស្រ័យរបស់ជដិលទាំងនោះ ដែលនិយមការបូជាភ្លើង ដ៏ជារបស់ក្តៅ ។ ក្រៅពីឧទាហរណ៍នេះ នៅមានឧទាហរណ៍ជាច្រើនទៀត ប៉ុន្តែលើកមកប៉ុណ្ណោះល្មមជាទីសំអាងបានហើយ ។

១៦៩ ស. បើប្រសិនជាព្រះសាស្តាមិនយាងទៅប្រោសបុរាណជដិលឲ្យសូមឧបសម្បទជាភិក្ខុពុទ្ធសាវ័កមុនទេ នឹងយាងទៅក្រុងរាជគ្រឹះតែមួយព្រះអង្គឯងជាដំបូង តើការយាងទៅនេះ នឹងបានផលខុសគ្នាឬទេ? ចូរអធិប្បាយ !

ឆ. នឹងបានផលខុសគ្នា គឺថាមនុស្សក្នុងក្រុងរាជគ្រឹះនោះស្រឡាញ់រាប់អានបុរាណជដិលជាច្រើន បើព្រះសាស្តាស្តេចទៅតែមួយព្រះអង្គឯង ចុះជាគេមិនងាយចុះចូលទេ ។ ដូចជាកាលព្រះអង្គយាងទៅដល់ហើយគង់នៅក្នុងលដ្ឋិវ័ន, រាជបរិវាររបស់ព្រះបាទពិម្ពិសារដែលចូលមកគាល់មានអាការផ្សេងៗគ្នា មិនទន់លំទោន មិនរៀបរយ ។ ព្រះសាស្តាត្រាស់ប្រើព្រះឧរុវេលកស្សបដែលជាទីស្រឡាញ់រាប់អានរបស់បរិវារទាំងនោះ ឲ្យប្រកាសលទ្ធិចាស់ដែលឥតខ្លឹមសារ ឲ្យគេដឹងឲ្យគេអស់សង្ស័យ ហើយតាំងចិត្តស្តាប់ព្រះធម៌ទេសនា ។ ដូច្នេះល្មមយល់

បានថា ការបណ្តុះសេចក្តីនិយមរបស់មនុស្សទាំងឡាយ ត្រូវធ្វើឲ្យអ្នកដែលជាទីគោរពរបស់គេនិយមជាមុន ទើបនឹងសម្រេចបានល្អ ។

១៧០-ស. ព្រោះហេតុអ្វី បានជាព្រះសាស្តាទ្រង់សំដែងធម៌ដល់ពួកបព្វជិតមុនគ្រហស្ថ ?

ឆ. ព្រោះបព្វជិតធ្លាប់បានអប់រំក្នុងផ្លូវប្រតិបត្តិមកជាច្រើនហើយ ដូចផ្កាឈូកដែលដុះឡើងផុតពីទឹក គ្រាន់តែត្រូវរស្មីព្រះអាទិត្យក៏រីកភ្លាម ។

យសបព្វជ្ជា

១៧១-ស. កាលព្រះសាស្តាប្រោសភិក្ខុបញ្ចវគ្គិយរួចហើយ តើព្រះអង្គទ្រង់ប្រោសអ្នកណាតមកទៀត ?

ឆ. ទ្រង់ប្រោសយសកុលបុត្រ ជាបុត្រនាងសុជាតាដែលបានថ្វាយមធុបាយាសដល់ព្រះសាស្តា ។ យសកុលបុត្របានស្តាប់អនុបុព្វីកថាចប់ហើយ ក៏បានសម្រេចសោតាបត្តិផលក្នុងព្រៃឥសិបតនមិគទាយវ័ន ។ តពីនោះមកទៀតទ្រង់ប្រោសសេដ្ឋីជាបិតាព្រះយស និងភរិយាសេដ្ឋីជាមាតាព្រះយសព្រមទាំងភរិយាព្រះយសឲ្យបានសម្រេចសោតាបត្តិផល ។ ខាងក្រោយមក ព្រះយសបានឧបសម្បទាជាឯហិភិក្ខុ ។

១៧២-ស. ចុះកាលព្រះសាស្តាប្រោសព្រះយសនិងបិតាមាតាភរិយានៃព្រះយសរួចហើយ តើទ្រង់ប្រោសអ្នកណាទៀត ? ឈ្មោះអ្វីខ្លះ ?

ឆ. ទ្រង់ប្រោសសំឡាញ់ព្រះយស ៤ នាក់ទៀតគឺឈ្មោះវិមលៈ១ សុពាហុ១ បុណ្ណជិ១ គវម្បតិ១ ។ តពីនោះមក ទ្រង់ប្រោសសំឡាញ់ព្រះយស៥០ទៀត ប៉ុន្តែមិនដឹងជាឈ្មោះអ្វីខ្លះ ។ សំឡាញ់ព្រះយសទាំង៥៤នាក់នេះ ក៏បានឧបសម្បទាជាឯហិភិក្ខុដែរ ។

១៧៣-ស. ចុះអ្នកណាជាឧបាសកនិងឧបាសិកាមុនគេបំផុត ?

ឆ. បើជាទ្វេវាចិកសរណគមន៍ គឺអ្នកដល់ព្រះពុទ្ធនិងព្រះធម៌ជាទីពឹងមុនគេ បានដល់ពាណិជពីរនាក់ឈ្មោះតបុស្សៈ១ ភល្លិកៈ១ ។ បើជា តេវាចិកសរណគមន៍ គឺអ្នកដល់ព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាទីពឹង បានដល់សេដ្ឋីជាបិតាព្រះយស ហៅថា បឋមឧបាសក ។ ចំណែកមាតានិងភរិយានៃព្រះយស ហៅថា បឋមឧបាសិកា ។

១៧៤-ស. កាលព្រះសាស្តាគង់ក្នុងព្រៃឥសិបតនមិគទាយវ័នស្ងាត់តែមួយព្រះអង្គឯងនោះ តើមារាធិរាជចូលទៅក្រាបទូលព្រះអង្គថាដូចម្តេច ?

ប. ចូលទៅក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន! ព្រះអង្គបានរួចចាកមារព័ន្ធទាំងពួងហើយ ប៉ុន្តែព្រះអង្គគង់មិនរួចពីដៃខ្ញុំទេ” ។ ព្រះសាស្តាត្រាស់តបថា “ម្នាលមារអើយ ! សេចក្តីប្រាថ្នានៃតថាគតក្នុងរូប សំឡេង ក្លិន រស សម្ផស្សមិនមានឡើយ តថាគតអាចកំចាត់បង់នូវមច្ចុមារបាន” ។ មារស្តាប់ហើយក៏កើតទុក្ខព្រួយចិត្តត្រឡប់វិលទៅវិញ ។

ឧរុវេលាគមនៈ

១៧៥-ស. កាលព្រះសាស្តាចេញពីព្រៃឥសិបតនមិគទាយវ័នហើយ ទ្រង់យាងទៅគង់ក្នុងទីណាទៀត ?

ប. ទ្រង់យាងទៅគង់ក្នុងឧរុវេលាប្រទេស ។

១៧៦-ស. កាលទ្រង់យាងទៅតាមផ្លូវ តើបានប្រោសអ្នកណាដែរ?

ប. បានប្រោសភទ្ទវគ្គិយកុមារ ៣០ នាក់ ក្នុងព្រៃកប្បាសឲ្យបានជាឯហិភិក្ខុឧបសម្បទា ។

១៧៧-ស. ចុះកាលព្រះសាស្តាគង់ក្នុងឧរុវេលាប្រទេស បានប្រោសអ្នកណាខ្លះ ?

ប. ប្រោសជដិល៣នាក់ជាបងប្អូននឹងគ្នាគឺ ឧរុវេលកស្សបៈ មានបរិវារ ៥ រយ, នទីកស្សបៈ មានបរិវារ ៣ រយ, គយាកស្សបៈ មាន

បរិវារ ២ រយ ឲ្យបានសម្រេចជាឯហិភិក្ខុឧបសម្បទា ទាំង ៣ នាក់ និងបរិវារ ១ ពាន់នាក់ផង ។

១៧៨-ស. ព្រះសាស្តាសំដែងបាដិហារ្យចំនួនប៉ុន្មាន? ហើយទេសនាធម៌អ្វី ក្នុងកាលដែលប្រោសជដិលទាំងនោះ ?

ប. ទ្រង់សំដែងបាដិហារ្យ ចំនួន ១ ៥០០ យ៉ាង ។ ទ្រង់ទេសនាអាទិត្តបរិយាយសូត្រ ។

១៧៩-ស. ចុះកាលព្រះសាស្តាប្រោសជដិលរួចហើយ ទ្រង់យាងទៅប្រោសអ្នកណាទៀត?

ប. ទ្រង់យាងទៅប្រោសព្រះបាទពិម្ពិសារ ក្សត្រក្រុងរាជគ្រឹះ ព្រមទាំងព្រាហ្មណ៍និងគហបតី ១១ ម៉ឺននាក់ ឲ្យបានសម្រេចសោតាបត្តិផល, ព្រាហ្មណ៍និងគហបតី ១ ម៉ឺនទៀត បានស្ថិតនៅក្នុងព្រះត្រៃសរណគមន៍ ។

១៨០-ស. ព្រះសាស្តាទ្រង់ទេសនាធម៌អ្វី ប្រោសព្រាហ្មណ៍និងគហបតីទាំងនោះ?

ប. ទ្រង់ទេសនាមហានារទជាតក ដោយពិស្តារ ។

អគ្គសាវកបព្វជ្ជា

១៨១-ស. ព្រះអគ្គសាវ័ករបស់ព្រះសាស្តា គឺអ្នកណា? លោកមានគុណវិសេសជាយ៉ាងសំខាន់ដល់សាសនាដូចម្តេច បានជាព្រះសាស្តាទ្រង់តាំងទុកក្នុងតំណែងដ៏សំខាន់ដូច្នោះ?

ឆ. គឺព្រះសារីបុត្រនិងព្រះមោគ្គល្លាន ។ លោកបានជាកម្លាំងរបស់ព្រះសាស្តាក្នុងការប្រកាសផ្សាយសាសនា ញ៉ាំងមហាជនឲ្យកើតសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាជាច្រើន ។ សូម្បីព្រះសាស្តាក៏បានសរសើរលោកទាំងពីរព្រះអង្គនោះ ដោយឧបមាថា ព្រះសារីបុត្រប្រៀបដូចមាតាអ្នកញ៉ាំងទារកឲ្យកើត, មោគ្គល្លានប្រៀបដូចស្រីមេដោះចិញ្ចឹមរក្សាទារកដែលកើតហើយនោះ ។ សារីបុត្រតែងដឹកនាំមហាជនឲ្យតាំងនៅក្នុងសោតាបត្តិផល, មោគ្គល្លាន តែងដឹកនាំមហាជនឲ្យតាំងនៅក្នុងគុណខាងលើដែលខ្ពង់ខ្ពស់ជាងនោះទៅទៀត ។

បើនិយាយឲ្យចំទៅថា ព្រះសារីបុត្រព្រះសាស្តាទ្រង់លើកដំកើងថាប្រសើរដាច់គេខាងផ្លូវបញ្ញា អាចសំដែងធម្មចក្រ និងចតុរារិយសច្ចឲ្យផ្សាយទូលាយពិស្តារបានដូចជាព្រះអង្គដែរ ទាំងជាអ្នកឈ្លាសវៃក្នុងការទេសនាទូន្មានមហាជន ។ ចំណែកព្រះមោគ្គល្លាន, ព្រះសាស្តាទ្រង់លើកដំកើងសរសើរថា ជាអ្នកមានឫទ្ធិច្រើន អាចធ្វើអ្វី ៗ បានដូចសេចក្តី

ប្រាថ្នា ទាំងជាអ្នកឈ្លាសវៃក្នុងការដឹកនាំគ្រួសដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាបាន មិនធ្វើសទ្ធានិងទ្រព្យសម្បត្តិរបស់ទាយកឲ្យខូចខាត ដូចជាមេឃ្មុំដែលហើរចូល ទៅក្នុងសួនផ្កា មិនធ្វើពណ៌និងក្លិនរបស់ផ្កាឲ្យជាំនាំឲ្យបាត់បង់ គ្រាន់តែក្រេបដង្ហក់យកតែខ្លឹមជារសហើយហើរបាត់ទៅ ព្រះសាស្តាទ្រង់ត្រាស់ប្រដៅឲ្យភិក្ខុឯទៀតប្រព្រឹត្តយកតាមជាគំរូ ។

១៨២-ស. ព្រះសារីបុត្រនិងព្រះមោគ្គល្លានបានបួសក្នុងលទ្ធិដទៃរួចទៅហើយ ហេតុអ្វីក៏បានជាលះបង់លទ្ធិនោះចោលទៅវិញ ហើយចូលមកបួសក្នុងព្រះពុទ្ធសាសនា?

ឆ. ហេតុតែលោកមានប្រក្រតីជាអ្នកភ្ញាក់រឭកជានិច្ចមិនភ្លេចខ្លួន បានបួសក្នុងលទ្ធិរបស់អាចារ្យសញ្ជ័យវេលដ្ឋបុត្រហើយមិនបានសម្រេចមោក្ខធម៌ ក៏ធ្វើកតិកានឹងគ្នាថា បើអ្នកណាបានមោក្ខធម៌មុន អ្នកនោះចូរប្រាប់ដល់អ្នកម្នាក់ទៀត ។ ថ្ងៃមួយ ព្រះសារីបុត្របានទៅជួបនឹងព្រះអស្សជិត្ថេរ ក៏មានចិត្តជ្រះថ្លានឹងឥរិយាបថរបស់លោក បានគាកសួរដឹងថាលោកជាពុទ្ធសាវ័កហើយ ក៏អារាធនាឲ្យលោកសំដែងធម៌ ។ ព្រះអស្សជិត្ថេរបានសំដែងប្រាប់ត្រង់គោលព្រះពុទ្ធសាសនាថា "ធម៌ទាំងឡាយតែងកើតឡើងព្រោះហេតុ តែងរលត់ទៅវិញក៏ព្រោះរលត់

ហេតុ" ។ ព្រះសារីបុត្រស្តាប់ធម៌នេះចប់ហើយក៏បានធម្មចក្ខុ ទើបត្រឡប់មកដំណាលប្រាប់ព្រះមោគ្គល្លាន ៗ បានស្តាប់ធម៌នោះ ហើយក៏បានធម្មចក្ខុដូចគ្នា ទើបបបួលគ្នាចូលទៅគាល់ព្រះសាស្តា ។

១៨៣-ស. អារាមឈ្មោះអ្វី ដែលកើតមានឡើងជាដំបូង ក្នុងព្រះពុទ្ធសាសនា? កើតនៅប្រទេសណា ? អ្នកណាជាអ្នកថ្វាយ ៗ ក្នុងវេលាណា?

ឆ. អារាមឈ្មោះវេឡុវ័នគឺជាទីព្រះរាជឧទ្យានព្រៃឫស្សីតាំងនៅជិតក្រុងរាជគ្រឹះ ក្នុងដែនមគធៈ ជាទីស្ងប់ស្ងាត់សមគួរដល់សមណៈ ។ ព្រះបាទពិម្ពិសារ ក្សត្រក្រុងរាជគ្រឹះជាអ្នកថ្វាយ ៗ ក្នុងវេលាដែលព្រះសាស្តាព្រមដោយភិក្ខុសង្ឃ យាងទៅទទួលភត្តាហារក្នុងព្រះរាជនិវេសន៍ ក្នុងកាលព្រះសាស្តាស្តេចទៅក្នុងដែនមគធៈ ដើម្បីប្រកាសព្រះសាសនាជាដំបូង ។

១៨៤-ស. ចុះព្រះនាមដើមរបស់ព្រះសារីបុត្រនឹងព្រះមោគ្គល្លាន ហៅថាអ្វី ? លោកកើតនៅស្រុកណា ? ជាបុត្រអ្នកណា ?

ឆ. ព្រះនាមដើមរបស់ព្រះសារីបុត្រ ហៅថា ឧបតិស្សៈ លោកកើតក្នុងឧបតិស្សគ្រាម ជាបុត្រនៃនាងសារីព្រាហ្មណី ។ ព្រះនាមដើមរបស់ព្រះមោគ្គល្លាន ហៅថា កោលិតៈ លោកកើតក្នុងកោលិតគ្រាម ជាបុត្រនៃនាងមោគ្គល្លី ។

១៨៥-ស. ចុះកាលព្រះសារីបុត្រនឹងព្រះមោគ្គល្លាន ចូលទៅសូមបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះសាស្តានោះ តើបាននាំបរិវារប៉ុន្មាននាក់ទៅផង ?

ឆ. បាននាំបរិវារ ២៥០នាក់ទៅផង ។

១៨៦-ស. បណ្តាព្រះអគ្គសាវ័កទាំង ២ ព្រះអង្គ, លោកណាបានសម្រេចព្រះអរហត្តមុន ? ព្រោះបានស្តាប់ធម៌អ្វី ?

ឆ. ព្រះមោគ្គល្លានបានសម្រេចព្រះអរហត្តមុន គឺរាប់ពីថ្ងៃដែលលោកបួសមកបាន ៧ ថ្ងៃ ។ ព្រោះបានស្តាប់ធាតុកម្មដ្ឋាន ក្នុងវេលាដែលលោកទៅគង់នៅក្នុងស្រុកកល្លវាឡគ្រាមក្នុងដែនមគធៈ ។ ឯព្រះសារីបុត្របានសម្រេចព្រះអរហត្តក្រោយ គឺរាប់ពីថ្ងៃដែលលោកបួសមកបាន១៥ថ្ងៃ ព្រោះបានស្តាប់វេទនាបរិគ្គហសូត្រ ដែលព្រះសាស្តាកំពុងសំដែងប្រោសទីឃនខបរិព្វាជកជាក្មួយរបស់ខ្លួនក្នុងគុហាឈ្មោះសូករខាតៈ ។

១៨៧-ស. ចុះព្រះសារីបុត្រមានបញ្ញាច្រើនណាស់ ហេតុអ្វីក៏បានជាសម្រេចព្រះអរហត្តក្រោយព្រះមោគ្គល្លានទៅវិញ ?

ឆ. ហេតុតែលោកមានគំនិតល្អិតជ្រាលជ្រៅទៅទៀតព្រះទ័យលោកមិនបានស្ទុះចុះទៅក្នុងធម៌តែមួយ ប្រៀបដូចអ្នកដំណើរបើទៅ

ម្នាក់ឯងបានឆាប់ចាស់ បើទៅគ្នាច្រើនរមែងយឺតយូរ ព្រោះរង់ចាំឲ្យជួបជុំគ្នា ។

១៨៨-ស. ព្រះសាស្តាទ្រង់តាំងអគ្គសាវ័កទាំងគូ ព្រមទាំងទ្រង់សំដែងឱវាទបាតិមោក្ខនៅទីណា ? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ?

ឆ. ក្នុងវត្តវេឡុវ័ន ក្បែរក្រុងរាជគ្រឹះ ដែនមគធៈ ។ នៅថ្ងៃ ១៥ កើតខែមាឃ ឆ្នាំវក ។

កបិលវត្ថុគមនៈ

១៨៩-ស. កាលព្រះសាស្តាគង់ក្នុងវត្តវេឡុវ័ននោះ តើព្រះបាទសុទ្ធោទនៈប្រើអាមាត្យប៉ុន្មាននាក់ ? ហើយប៉ុន្មានដងឲ្យទៅនិមន្តព្រះសាស្តាមកកាន់ក្រុងកបិលពស្តុ ?

ឆ. ព្រះរាជាប្រើអាមាត្យ ១០ នាក់ ក្នុងម្នាក់ៗ មានបរិវារ ១ ពាន់ ៗ ប្រើឲ្យទៅ ១០ ដង គឺ ១ នាក់ ១ ដង ។

១៩០ ស. ចុះអាមាត្យទាំងអស់នោះ បានបួសបានសម្រេចគុណអ្វីដែរឬទេ ?

ឆ. អាមាត្យទាំងអស់នោះ បានបួសហើយបានសម្រេចព្រះ-អរហត្តផលជាឯហិភិក្ខុឧបសម្បទា ។

១៩១-ស. ព្រះថេរៈអង្គណាដែលបាននិមន្តព្រះសាស្តាឲ្យយាងទៅកាន់កបិលពស្តុ ?

ឆ. ព្រះកាឡុទាយិត្ថេរ ដែលជាអាមាត្យគំរប់ដប់ ទៅក្រោយអាមាត្យទាំងអស់ បាននិមន្តព្រះសាស្តា ។

១៩២-ស. កាលព្រះសាស្តាយាងទៅដល់នគរកបិលពស្តុហើយ ទ្រង់គង់នៅទីណា ? មានព្រះសង្ឃជាបរិវារប៉ុន្មានអង្គ ?

ឆ. ព្រះអង្គគង់ក្នុងនិគ្រោធារាម ។ មានព្រះសង្ឃជាបរិវារ ២ ម៉ឺនអង្គ សុទ្ធតែជាព្រះខីណាស្រព ។

១៩៣-ស. ព្រះសាស្តាទ្រង់ប្រោសព្រះពុទ្ធបិតានិងព្រះញាតិវង្សដោយវិធីដូចម្តេច ?

ឆ. ដោយវិធីធ្វើយមកបាដិហារ្យ គឺទ្រង់និម្មិតទីចង្ក្រមកែវ ហើយយាងចង្ក្រមក្នុងអាកាស ទ្រង់និម្មិតជាព្រះពុទ្ធមួយព្រះអង្គទៀតឲ្យឆ្លើយប្រស្នារបស់ព្រះអង្គ ។ នៅទីបំផុតទ្រង់យាងចុះពីអាកាសមកហើយត្រាស់ទេសនាវេស្សន្តរជាតក ព្រោះទ្រង់ប្រារព្ធភ្លៀងបោក្ខរពស្សឲ្យជាដើមហេតុ ។

១៩៤ ស. ចុះព្រះពុទ្ធបិតាបានសម្រេចមគ្គផលអ្វី? បានទ្រង់ព្រះផ្នួសឬទេ ?

ប. កាលជួបនឹងព្រះសាស្តាគ្រាដំបូង បានសម្រេចព្រះអនាគាមិផល, លុះដល់ជិតនឹងអស់ព្រះជន្ម ទើបបានសម្រេចព្រះអរហត្តផល ហើយបរិនិព្វានទៅ ។ ព្រះអង្គមិនបានទ្រង់ព្រះផ្នួសទេ ។

ពិម្ពាពិលាប

១៩៥–ស. ក្នុងថ្ងៃទីពីរ(១) ព្រះសាស្តាបានប្រោសអ្នកណា ? ឲ្យបានសម្រេចមគ្គផលអ្វី ? ដោយទេសនាធម៌អ្វី ?

ប. បានប្រោសព្រះនាងបជាបតិគោតមី ជាព្រះមាតុច្ឆា, ឲ្យបានសម្រេចព្រះសោតាបត្តិផល, ដោយទេសនាមហាធម្មបាលជាតក ។

១៩៦–ស. ក្នុងថ្ងៃទីបីព្រះសាស្តាទ្រង់ប្រោសអ្នកណា ? ឲ្យបានសម្រេចមគ្គផលអ្វី ? ដោយទេសនាធម៌អ្វី ?

ប. បានប្រោសព្រះនាងពិម្ពាជាមាតាព្រះរាហុលកុមារ, ឲ្យបានសម្រេចព្រះសោតាបត្តិផល, ដោយទេសនាចន្ទកិន្នរីជាតក ។

សាក្យបព្វជ្ជា

១៩៧–ស. ក្នុងថ្ងៃជាគំរប់បួន ព្រះសាស្តាបានប្រោសអ្នកណា ? ឲ្យបានសម្រេចមគ្គផលអ្វី ?

១-ថ្ងៃដែលព្រះអង្គស្តេចទៅដល់ក្រុងកបិលព័ស្តុទុកជាថ្ងៃទី ១, ថ្ងៃបន្ទាប់មកជាថ្ងៃទី ២ ។

ប. បានប្រោសព្រះនន្ទកុមារ គឺក្នុងថ្ងៃដែលព្រះនន្ទកុមារកំពុងតែធ្វើវិវាហមង្គលជាមួយនឹងនាងជនបទកល្យាណី ព្រះសាស្តាទ្រង់នាំព្រះនន្ទកុមារទៅឯវត្តនិគ្រោធារាម ហើយទ្រង់បំបួសព្រះនន្ទកុមារ ។ ដល់ថ្ងៃក្រោយមក ព្រះនន្ទភិក្ខុបានសម្រេចព្រះអរហត្តផល ។

១៩៨–ស. ចុះព្រះនន្ទត្រូវជាព្រះញាតិនឹងព្រះសាស្តាដូចម្តេច ?

ប. ត្រូវជាព្រះកនិដ្ឋភាតា គឺប្អូនបង្កើតរបស់ព្រះសាស្តា រួមព្រះបិតាជាមួយ ឯព្រះមាតាផ្សេងគ្នា ។

១៩៩–ស. ចុះព្រះមាតារបស់ព្រះនន្ទព្រះនាមអ្វី ? ត្រូវជាអ្វីនឹងព្រះសាស្តា ?

ប. ព្រះនាមព្រះនាងមហាបជាបតិគោតមី, ត្រូវជាព្រះមាតុច្ឆា គឺម្តាយមីងរបស់ព្រះសាស្តា ។

២០០–ស. ថ្ងៃក្រោយមក ព្រះសាស្តាបានប្រោសអ្នកណាទៀត?

ប. រាប់ពីថ្ងៃដែលព្រះសាស្តាបំបួសព្រះនន្ទមកបាន ៧ ថ្ងៃ ព្រះអង្គទ្រង់បង្គាប់ព្រះសារីបុត្រ ឲ្យបំបួសព្រះរាហុលកុមារជាសាមណេរ ក្នុងថ្ងៃដែលព្រះរាជកុមារគាបសូមកំណប់ទ្រព្យអំពីព្រះអង្គ ។

២០១–ស. វត្តជេតពន នៅក្នុងនគរណា ? អ្នកណាកសាងថ្វាយព្រះសាស្តា ?

ឆ. នៅក្នុងនគរសាវត្ថី ។ អនាថបិណ្ឌិកសេដ្ឋីកសាងថ្វាយ ។

២០២-ស. មានក្សត្រសាក្យត្រកូលប៉ុន្មានព្រះអង្គ បានចេញទ្រង់ព្រះផ្នួសក្នុងសំណាក់ព្រះសាស្តា ?

ឆ. មាន ៦ ព្រះអង្គ គឺ ភទ្ទិយៈ ១ អនុរុទ្ធ ១ ភគុ ១ កិម្ពិលៈ ១ អានន្ទ ១ ទេវទត្ត ១ ។

២០៣-ស. ចុះបណ្តាលោកទាំង ៦ ព្រះអង្គនេះ អង្គណាបានសម្រេចគុណវិសេសដូចម្តេច ?

ឆ. ព្រះភទ្ទិយៈបានសម្រេចវិជ្ជា ៣, ព្រះអនុរុទ្ធបានទិព្វចក្ខុ សម្រេចព្រះអរហត្តផល, ព្រះភគុនិងព្រះកិម្ពិលៈ បានសម្រេចព្រះអរហត្តផល, ព្រះអានន្ទ បានសម្រេចព្រះសោតាបត្តិផល, ព្រះទេវទត្ត បានឫទ្ធិជារបស់បុថុជ្ជន ។

មេត្តេយ្យព្យាករណ៍

២០៤-ស. កាលព្រះសាស្តាយាងមកកាន់នគរកបិលព័ស្តុ ក្នុងលើកទី ២ គង់ក្នុងនិគ្រោធារាម មានអ្នកណាយកវត្ថុអ្វីទៅថ្វាយព្រះអង្គដែរឬទេ ?

ឆ. មាន គឺព្រះនាងមហាបជាបតីគោតមី ជាព្រះមាតុច្ឆារបស់ព្រះអង្គ បានយកសំពត់សាដកពីរផ្ទាំងមកថ្វាយ, ក្នុងមួយផ្ទាំងៗបណ្តោយ ១៤ ហត្ថ ទទឹង ៨ ហត្ថដូចគ្នា ។ សំពត់នេះព្រះនាងធ្វើដោយព្រះហស្តឯង តាំងពីដាំកប្បាសមក ដរាបដល់ត្បាញបានជាសាច់សំពត់ ។

២០៥-ស. ព្រះសាស្តាទ្រង់ទទួលសំពត់អំពីព្រះនាងឬទេ ?

ឆ. មិនទទួលទេ, ទ្រង់បង្គាប់ឲ្យព្រះនាងថ្វាយដល់សង្ឃវិញ ។

២០៦-ស. ចុះភិក្ខុអង្គណាទទួលសំពត់នោះ ?

ឆ. ព្រះអជិតភិក្ខុដែលទើបនឹងបួសថ្មី គង់ចុងអាសន៍បំផុត បានទទួលសំពត់នោះ ។

២០៧-ស ចុះព្រះអជិតភិក្ខុនោះ តើជាបុត្រលោកណា ? ទៅអនាគតនឹងបានជាអ្វី ?

ឆ. ព្រះអជិតភិក្ខុ ជាព្រះរាជបុត្រនៃព្រះនាងកាញ្ចនា ជាអគ្គមហេសី នៃព្រះបាទអជាតសត្តុរាជ; ទៅអនាគតលោកនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមថា មេត្តេយ្យ ក្នុងភទ្ទកប្បនេះ ។

ពុទ្ធបិតុនិព្វាន

២០៨- ស. ព្រះសាស្តាត្រាស់ដឹងបានប៉ុន្មានវស្សា ទើបព្រះពុទ្ធបិតានិព្វាន ហើយអ្នកណាថ្វាយព្រះភ្លើងព្រះពុទ្ធបិតា ?

ឆ. បាន ៥ វស្សា ។ ព្រះសាស្តាទ្រង់បង្គាប់ឲ្យព្រះមហាកស្សបត្ថេរ តាក់តែងជើងថ្ករស្រេចហើយ ព្រះអង្គលើកព្រះសរីរនៃព្រះបិតាដោយព្រះហស្ត ព្រះអង្គទ្រង់ស្រោចដោយសុគន្ធវារីរួចលើកព្រះបរមសពដាក់ក្នុងមឈូសរតន៍ ទើបព្រះសាស្តាលើកមឈូសដោយព្រះអង្គឯងនាំទៅកន្លែងបូជា ទ្រង់ថ្វាយព្រះភ្លើងដោយព្រះអង្គឯង ។

២០៩- ស. ព្រះនាងមហាបជាបតិគោតមី បានទូលសូមបព្វជ្ជាក្នុងសំណាក់ព្រះសាស្តាប៉ុន្មានដង? នៅទីណាខ្លះ?

ឆ. ព្រះនាងទូលសូម ៣ ដង ។ សូមដំបូងក្នុងនិគ្រោធារាម ព្រះសាស្តាមិនអនុញ្ញាត, សូមទីពីរក្នុងកូដាគារសាលាព្រៃមហាវ័ន បានព្រះអានន្ទជួយអង្វរផង ព្រះអង្គក៏នៅមិនទ្រង់អនុញ្ញាតទៀត, សូមទីបីក្នុងវត្តជេតពននគរសាវត្ថី បានព្រះអានន្ទជួយអង្វរទៀត ព្រះសាស្តាក៏អនុញ្ញាតឲ្យបព្វជ្ជាឧបសម្បទា ដោយគរុធម៌ ៨ ប្រការ ។

២១០- ស. ព្រះនាងសូមបព្វជ្ជាតែមួយព្រះអង្គឯងទេឬ ?

ឆ. មានខត្តិយកញ្ញា ៥០០ នាក់ ជាបរិវារបានបព្វជ្ជាជាមួយនឹងព្រះនាងដែរ ។

យមកប្បាដិហារ្យ

២១១- ស. កាលព្រះសាស្តាទ្រង់ធ្វើយមកប្បាដិហារ្យផ្ចាញ់ពួកអន្យតិរ្ថិយនោះ តើព្រះអង្គគង់ក្នុងទីណា ?

ឆ. ព្រះអង្គគង់ក្នុងវត្តជេតពនក្បែរក្រុងសាវត្ថី ។

២១២- ស. គ្រូទាំង ៦ នាក់នោះ ដែលធ្វើបាដិហារ្យប្រឡងនឹងព្រះសាស្តានោះតើឈ្មោះអ្វីខ្លះ ?

ឆ. គ្រូទាំង ៦ នាក់នោះ គឺឈ្មោះ បូរណកស្សបៈ ១ មក្ខលិគោសាល ១ និគ្គណ្ឋនាដបុត្រ ១ សញ្ជយវេលដ្ឋបុត្រ ១ បកុធកច្ចាយនៈ ១ អជិតកេសកម្ពលៈ ១ ។

២១៣ ស. មានរឿងដូចម្តេច បានជាព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទមិនឲ្យសាវ័កធ្វើបាដិហារ្យ ?

ឆ. មានរឿងដំណាលថា: កាលដែលសេដ្ឋីព្យួរបាត្រខ្លឹមច័ន្ទន៍ ដើម្បីចង់ល្បងឲ្យដឹងថា បើមានលោកណាជាព្រះអរហន្តមែន សូមឲ្យលោកនោះហោះទៅយកបាត្រនោះចុះ ។ វេលានោះព្រះមោគ្គល្លាន-

ភ្លើង ប្រើព្រះបណ្ណា បេការទូតភ្លើង ឲ្យសំដែងបាដិហារ្យក្នុងអាកាស ហើយ ហោះទៅយកបាត្រនោះបានមក ។

ទេសនាបរិវត្តន៍

២១៤ ស. - កាលព្រះសាស្ដាធ្វើយមកបាដិហារ្យផ្ចាញ់អន្យតិរ្ថិយ ស្រេចហើយទ្រង់ហោះទៅគង់ចាំវស្សានៅទីណា ? ដើម្បីប្រយោជន៍អ្វី ?

ប គង់ក្នុងតាវត្តិង្សពិភព, ដើម្បីទេសនាព្រះអភិធម្មប្រោស ព្រះពុទ្ធមាតា ។

២១៥ ស. ព្រះសាស្ដាគង់ក្នុងស្ថានតាវត្តិង្សចំនួនប៉ុន្មានខែក្នុង មនុស្សលោក ? លុះចប់ទេសនាហើយ ព្រះពុទ្ធមាតាបានសម្រេចមគ្គផល អ្វី ?

ប. ចំនួន៣ខែ ។ បានសម្រេចព្រះសោតាបត្តិផល ។

ទេវោរោហនបរិវត្តន៍

២១៦-ស. ព្រះសាស្ដាយាងចុះពីទេវលោកដោយអ្វី? មកគង់ក្នុង ទីណា ?

ប. ដោយជណ្ដើរទិព្វ ៣ ដែលព្រះឥន្ទនិម្មិតថ្វាយ គឺខាង ឆ្វេងជណ្ដើរមាស, ខាងស្ដាំជណ្ដើរប្រាក់, កណ្ដាលជណ្ដើរកែវ ។ មកគង់ ក្បែរទ្វារនៃនគរសង្កស្ស ។

អគ្គសាវកនិព្វាន

២១៧-ស ព្រះសារីបុត្រនឹងព្រះមោគ្គល្លានៈ លោកណានិព្វាន មុន? ហើយលោកណានិព្វានក្នុងទីណា ?

ប. ព្រះសារីបុត្រនិព្វានមុន លោកនិព្វានក្នុងនាលន្ទគ្រាម ជាលំនៅរបស់មាតាលោក ក្នុងបន្ទប់ដែលលោកប្រសូត ។ ចំណែក ព្រះមោគ្គល្លាននិព្វានក្រោយព្រះសារីបុត្រ លោកទៅនិព្វានក្នុងកាឡសិលាប្រទេស ។

២១៨-ស. ព្រះអគ្គសាវកទាំងពីរព្រះអង្គនោះ និព្វានមុនព្រះ សាស្ដាឬក្រោយ ? ហេតុអ្វីបានជាដូច្នោះ ?

ប. លោកនិព្វានមុនព្រះសាស្ដា ។ ហេតុតែតាមធម្មតានៃ ព្រះពុទ្ធពីបុរាណមក ។

២១៩-ស. មាតាព្រះសារីបុត្រ បានសម្រេចមគ្គផលអ្វីដែរឬទេ ?

ប. បានសម្រេចព្រះសោតាបត្តិផល ។

២២០ ស ព្រះសារីបុត្រនឹងព្រះមោគ្គល្លាន និព្វានក្នុងថ្ងៃ-ខែណា ?

ប. ព្រះសារីបុត្រនិព្វានក្នុងថ្ងៃ១៥កើត ខែកត្ដិក, ព្រះ មោគ្គល្លាននិព្វានក្នុងថ្ងៃ១៥រោចខែកត្ដិក ។

ពុទ្ធបរិនិព្វាន

២២១-ស. ចូរប្រាប់ព្រះជន្មាយុនៃព្រះសាស្តាក្នុងរយៈកាលនេះ គឺកាលស្តេចចេញបព្វជ្ជា, កាលត្រាស់ដឹង, កាលបរិនិព្វាន ?

ច. កាលស្តេចចេញបព្វជ្ជា ព្រះជន្មាយុបាន ២៩ ឆ្នាំ, កាលបានត្រាស់ដឹង ព្រះជន្មាយុបាន ៣៥ ឆ្នាំ, កាលស្តេចចូលបរិនិព្វាន ព្រះជន្មាយុបាន ៨០ ឆ្នាំ ។

២២២-ស. តាំងអំពីព្រះសាស្តាត្រាស់ដឹងរហូតបរិនិព្វាន រួមវស្សាបានប៉ុន្មាន ?

ច. បាន ៤៥ វស្សា ។ ព្រះជន្ម ៨០ ឆ្នាំ ។

២២៣-ស. ក្នុងវស្សាតំរប់ ៤៥ ព្រះសាស្តាគង់ចាំវស្សាក្នុងទីណា?

ច. ក្នុងស្រុកវេឡុវគ្រាម ។

២២៤-ស. ក្នុងរវាង ៤៥ ព្រះវស្សានោះ ព្រះសាស្តាទ្រង់បំពេញពុទ្ធកិច្ចប៉ុន្មានប្រការ ? គឺអ្វីខ្លះ ?

ច. ទ្រង់បំពេញពុទ្ធកិច្ច ៥ ប្រការ ។ គឺៈក្នុងវេលាព្រឹកយាងទៅបិណ្ឌបាត ១ ក្នុងវេលារសៀលទ្រង់ទេសនាប្រោសមហាជន ១ ក្នុងវេលាព្រលប់ទ្រង់ប្រទាននូវឱវាទចំពោះពួកភិក្ខុ ១ ក្នុងវេលាកណ្តាល

អធ្រាត្រទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា ១ ដល់វេលាបែកបច្ចូស ទ្រង់ប្រមើលនូវសត្វដែលមានភ័ព្វ និងឥតភ័ព្វ ១ ។

២២៥-ស. ក្នុងរវាងដែលទ្រង់បំពេញពុទ្ធកិច្ចនោះ បានស្តេចចារិកទៅក្នុងនគរណាខ្លះ ។

ច. កាលព្រះអង្គគង់ព្រះជន្មនោះ បានស្តេចចារិកទៅក្នុងនគរផ្សេងៗជាច្រើន គឺនគរពារាណសី ១ នគររាជគ្រឹះ ១ នគរសាវត្ថី ១ នគរកបិលពស្តុ ១ នគរវេសាលី ១ នគរបាដលិបុត្រ ១ នគរកោសម្ពី១ នគរវេរញ្ជា ១ នគរកុសិនារា ១ នគរបាវា ១ នគរសាកេត១ នគរចម្ប៉ា ១ នគរវេដ្ឋទីបកៈ ១ នគរអល្លកប្បៈ ១ នគរកោរិយៈ ១ ។

២២៦-ស. កាលព្រះសាស្តាដាក់អាយុសង្ខារ ទ្រង់គង់ក្នុងទីណា? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ? ដោយមានអ្នកណាចូលទៅទូលអារាធនា ?

ច. លុះចេញវស្សាជាតំរប់ ៤៥ ហើយព្រះសាស្តាយាងទៅគង់ក្នុងបាវាលចេតិយ, ទ្រង់ដាក់អាយុសង្ខារក្នុងថ្ងៃពេញបូណ៌មីខែមាឃ, ឆ្នាំម្សាញ់បញ្ចស័ក; ដោយមានមារាធិរាជចូលទៅទូលអារាធនាឲ្យព្រះអង្គបរិនិព្វាន ។

២២៧-ស. ព្រះសាស្តាបរិនិព្វានក្នុងទីណា ? ក្នុងថ្ងៃ-ខែ-ឆ្នាំអ្វី ? ក្នុងព្រះជន្មតំរប់ប៉ុន្មាន ?

ឆ. ក្នុងសាលវ័នឧទ្យាន ចន្លោះដើមរាំងទាំងគូ[១] ក្បែរក្រុងកុសិនារា, ក្នុងថ្ងៃអង្គារពេញបូណ៌មីខែវិសាខ ឆ្នាំម្សាញ់វេលាព្រាកជិតភ្លឺ ក្នុងព្រះជន្ម ៨០ ឆ្នាំគត់ ។

២២៨-សួ. ក្នុងថ្ងៃព្រះសាស្ដាបរិនិព្វាន មានសាវ័កជាធំប៉ុន្មានរូប ដែលជាប្រធាននៅក្នុងទីនោះ? អ្នកណាជាម្ចាស់ចាត់ការព្រះសព? ដំកល់ព្រះសពក្នុងទីណា?

ឆ. មានព្រះសាវ័កជាធំពីររូប គឺព្រះអនុរុទ្ធត្ថេរ និងព្រះ-អានន្ទត្ថេរ ជាប្រធាននៅក្នុងទីនោះ ។ ពួកមល្លក្សត្រក្រុងកុសិនារា ជាម្ចាស់ចាត់ការព្រះសព ។ ព្រះសពដំកល់នៅក្នុងមកុដពន្ធនចេតិយ ខាងទិសបូព៌នៃក្រុងកុសិនារា ។

២២៩-សួ. ព្រះសាស្ដាប្រឈួនព្រះរោគអ្វី មុននឹងនិព្វាន? គេដំកល់ព្រះសពទុកប៉ុន្មានថ្ងៃ ទើបថ្វាយព្រះភ្លើង?

ឆ. ប្រឈួនព្រះរោគចុះព្រះលោហិត ឬហៅថាបក្ខន្ទិកាពាធ ។ គេដំកល់ព្រះសពទុក ៧ ថ្ងៃទើបថ្វាយព្រះភ្លើង ។

១– យមកសាលា តាមទំលាប់ប្រែថា "ដើមរាំងទាំងគូ" តែសម្ដេចសង្ឃនាយក ជួន-ណាត កាលនិមន្តទៅឥណ្ឌាទៅមើលត្រង់កន្លែងនោះឃើញថាមិនមែនជាដើមរាំងទេ ដល់សួរអ្នកឥណ្ឌាថា សាលព្រឹក្ស ។ ដូច្នេះយមកសាលា គួរប្រែថា "សាលព្រឹក្សទាំងគូ" វិញ ។

២៣០ សួ. កាលព្រះសាស្ដាជិតបរិនិព្វាន អ្នកណាចូលទៅសួរប្រស្នា? ហើយបានជាអ្វី?

ឆ. សុភទ្ទបរិព្វាជក បានចូលទៅក្រាបទូលសួរប្រស្នា, លុះចប់ធម៌ទេសនាបានសម្រេចព្រះអរហត្តផល ជាបច្ឆិមសាវ័ក ។

២៣១-សួ. កាលជិតនឹងបរិនិព្វាន ព្រះសាស្ដាបានប្រទានព្រះបរមពុទ្ធោវាទជាទីបំផុតថាដូចម្ដេច?

ឆ. ព្រះអង្គបានប្រទានព្រះបច្ឆិមោវាទ (ឱវាទទីបំផុត) ទុកថា: "ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួង គឺប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ និងត្រៃសិក្ខា គឺសីល សមាធិ បញ្ញា ឲ្យដល់ព្រម ដោយសេចក្ដីមិនប្រមាទចុះ" ។

ធាតុវិភជ្ជនៈ

២៣២-សួ. អ្នកណាជាអ្នកចាត់ការចែក ព្រះបរមសារីរិកធាតុ? បើមិនបានអ្នកនោះមកចាត់ការចែកទេតើនឹងមានសេចក្ដីវិនាសយ៉ាងណា?

ឆ. ទោណព្រាហ្មណ៍ ។ បើមិនបានលោកនេះមកធ្វើជាមេចាត់ការចែកទេ នឹងកើតសឹកសង្គ្រាមច្បាំងគ្នាធំដុំឡើង ព្រោះពួកក្សត្រផ្សេងៗ នឹងមកដណ្ដើមយកដោយពលាការ, ពួកអ្នកមានអំណាចឬមានកំឡាំងជាងនឹងដណ្ដើមយកព្រះធាតុទាំងអស់ទៅទុកតែក្នុងនគរខ្លួន ពួក

អ្នកមានកំឡាំងតិច ក៏ក្រោធខឹងហើយរួមកំឡាំងគ្នាមកច្បាំងដណ្តើមយកឲ្យបានទៅវិញ; កាលបើដូច្នេះ លោកសន្និវាសនឹងកើតវិវាទគ្មានសេចក្តីស្ងប់ស្ងៀម, ព្រះបរមសារីរិកធាតុក៏មិនបានផ្សាយទូទៅច្រើនប្រទេស ។

២៣៣-ស. ព្រះសារីរិកធាតុនៃព្រះសាស្តា គេចែកជាប៉ុន្មានចំណែក? គឺអ្វីខ្លះ? ហើយចំណែកដែលនៅល្អស្អាតមិនបែកបាក់មានប៉ុន្មានព្រះអង្គ? ចូររាប់មកឲ្យសព្វគ្រប់!

ឆ. គេចែកជា ២ ចំណែក ។ គឺព្រះសារីរិកធាតុដែលនៅល្អស្អាតមិនបែកបាក់ ១ ចំណែក, ព្រះសារីរិកធាតុដែលបែកបាក់ល្អិតៗ ១ ចំណែក ។ ចំណែកព្រះសារីរិកធាតុដែលនៅល្អស្អាតមិនបែកបាក់នោះមាន ៧ ព្រះអង្គ គឺព្រះឧណ្ហីសធាតុ (ឆ្អឹងថ្ងាស) ១, ព្រះទាឋាធាតុ (ព្រះចង្កូម) ទាំង ៤, ព្រះអក្ខកធាតុ (ឆ្អឹងដងកាំបិត) ទាំង ២ រួមជា ៧ ព្រះអង្គ ។ ព្រះសារីរិកធាតុក្រៅពីនេះបែកចេញជាបំណែកតូចនិងបំណែកធំ ។

២៣៤-ស. ចុះព្រះសារីរិកធាតុ ដែលបែកចេញជាបំណែកតូចបំណែកធំទាំងអស់នោះ តើមានខ្នាតប៉ុន្មានយ៉ាង? ខ្នាតណាមានចំនួនប៉ុន្មាននាឡិ? មានទំហំប៉ុនណា? មានពណ៌ដូចម្តេច?

ឆ. មានខ្នាត ៣ យ៉ាង។ គឺព្រះធាតុខ្នាតធំមានចំនួន៥នាឡិ មានទំហំប៉ុនគ្រាប់សណ្តែកបាយមួយកំណាត់មានពណ៌ដូចមាស, ព្រះធាតុ

ខ្នាតកណ្តាលមានចំនួន ៦ នាឡិ មានទំហំប៉ុនគ្រាប់អង្ករមួយកំណាត់មានពណ៌ដូចកែវផ្លេក, ព្រះធាតុខ្នាតតូចមានចំនួន ៥ នាឡិ មានទំហំប៉ុនគ្រាប់ស្ពៃ មានពណ៌ដូចផ្កាពិកុល គឺពណ៌សស្រគាំ ។

២៣៥-ស. ព្រះសារីរិកធាតុទាំងអស់នោះ បានទៅប្រតិស្ឋាននៅកន្លែងណាខ្លះ? ចូររាប់ឲ្យគ្រប់មក!

ឆ. ព្រះទាឋាធាតុស្តាំខាងលើ ប្រតិស្ឋាននៅត្រៃត្រិង្ស, ព្រះទាឋាធាតុស្តាំខាងក្រោម ប្រតិស្ឋាននៅសីហឡទ្វីប, ព្រះទាឋាធាតុឆ្វេងខាងលើ ប្រតិស្ឋានក្នុងដែនគន្ធារៈ, ព្រះទាឋាធាតុឆ្វេងខាងក្រោម ប្រតិស្ឋានក្នុងពិភពនាគ, ព្រះអក្ខកធាតុខាងឆ្វេងទាំងពីរអង្គ ប្រតិស្ឋានក្នុងព្រះស្តូបកំពស់ ១២ យោជន៍នៅនាព្រហ្មលោក (ព្រះអក្ខកធាតុខាងស្តាំមិនឃើញមានប្រាប់ថាប្រតិស្ឋាននៅទីណា), ព្រះកេសធាតុដែលព្រះសាស្តាកាត់ក្នុងពេលទ្រង់ព្រះផ្នួស ប្រតិស្ឋានក្នុងចូឡាមណិចេតិយនៅនាស្ថានត្រៃត្រិង្ស ព្រះទន្តធាតុទាំង ៤០ គត់ ព្រះកេសធាតុ ព្រះលោមធាតុនិងព្រះនខធាតុ ពួកទេវតានាំយកព្រះកេសធាតុមួយអង្គៗ ទៅកាន់ចក្រវាឡដទៃៗក្នុងចក្រវាឡមួយ ១ អង្គ ។

២៣៦-ស. ពុទ្ធបរិក្ខារមានប៉ុន្មាន? គឺអ្វីខ្លះ? ពុទ្ធបរិក្ខារណាទៅប្រតិស្ឋានក្នុងប្រទេសណា? ចូរប្រាប់ឲ្យគ្រប់មកមើល!

ច. ក្នុងគម្ពីរបឋមសម្ពោធិ គ្រង់ធាតុវិភជ្ជនបរិវត្តន៍ ប្រាប់ថា ពុទ្ធបរិក្ខារមាន ១០ យ៉ាង ទៅប្រតិស្ឋាននៅប្រទេសផ្សេងៗគ្នាគឺៈ

១- កាយពន្ធនិងបាត្រ	នៅក្នុងនគរបាដលិបុត្រ
២- សំពត់ឧទកសាដក	" នគរបញ្ចាលរាជ
៣- សំពត់ចម្មក្ខន្ធ	" នគរកោសលរដ្ឋ
៤- ឈើស្ទន់	" នគរមិថិលា
៥- សំពត់តម្រងទឹក	" នគរវិទេហរដ្ឋ
៦- កាំបិតកោរនិងបំពង់ម្ជុល	" នគរឥន្ទបត្ត
៧- ទ្រនាប់ព្រះបាទនិងស្ពាយបាត្រ	" ឧសិរព្រាហ្មណគ្រាម
៨- គ្រឿងកម្រាល	" មកុដនគរ
៩- ត្រៃចីវរ	" នគរកម្ពុរដ្ឋ
១០- និសីទនសន្ថត	" នគរកុរុរដ្ឋ

២៣៧- ស. កាលព្រះសាស្តាគង់ព្រះជន្មនៅ ទ្រង់បានប្រតិស្ឋានស្នាមព្រះបាទក្នុងទីណាខ្លះ? រួមជាប៉ុន្មានកន្លែង?

ច. ទ្រង់បានប្រតិស្ឋានទុកលើកំពូលភ្នំសុវណ្ណមាលិកៈ ១ លើភ្នំសុវណ្ណបពិត ១ លើភ្នំសុមនកូដ ១ នៅយោនកបុរី ១ នៅឆ្នេរស្ទឹងនម្មទាៈ ១ រួមជា ៥ កន្លែង ។

២៣៨- ស. សំវេជនីយស្ថានមានប៉ុន្មានកន្លែង? នៅក្នុងទីណាខ្លះ? ចូរចង្អុលប្រាប់ឲ្យគ្រប់មកមើល!

ច. មាន ៤ កន្លែងគឺ ទីប្រសូត ១ ទីត្រាស់ដឹង ១ ទីសំដែងព្រះធម្មចក្រ ១ ទីបរិនិព្វាន ១ ។ ឯទីប្រសូត នៅក្នុងព្រៃលុម្ពិនី ប្រទល់ដែនក្រុងកបិលពស្តុ និងក្រុងទេវទហៈ ។ ទីត្រាស់ដឹង នៅក្នុងដែនមគធៈ ក្រោមម្លប់ព្រះមហាពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ។ ទីសំដែងព្រះធម្មចក្រ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី ។ ទីបរិនិព្វាន នៅត្រង់ចន្លោះដើមរាំងទាំងគូ ក្នុងសាលវ័នឧទ្យានរបស់មល្លក្សត្រ ក្បែរនគរកុសិនារា ។

២៣៩- ស. កាលព្រះពុទ្ធបរិនិព្វានហើយ ជាន់ដំបូងមានព្រះស្តូបចេតិយប៉ុន្មានកន្លែង? នៅទីណា? អ្នកណាជាអ្នកសាង?

ច. មានធាតុចេតិយ ៨ កន្លែង ។ គឺព្រះបាទអជាតសត្រូវ ទ្រង់សាងក្នុងនគររាជគ្រឹះ ១, ក្សត្រលិច្ឆវីទ្រង់សាងក្នុងនគរវេសាលី ១, ក្សត្រសាក្យៈទ្រង់សាងក្នុងនគរកបិលពស្តុ ១, ថូលិយក្សត្រទ្រង់សាងក្នុងអល្លកប្បនគរ១, ក្សត្រកោលិយៈទ្រង់សាងក្នុងរាមគ្រាម១, ព្រាហ្មណ៍អ្នកវេដ្ឋទីបកៈ បានសាងក្នុងដែនវេដ្ឋទីបកៈ១, ពួកមល្លក្សត្រអ្នកក្រុងបាវា បានសាងក្នុងក្រុងបាវា ១, ពួកមល្លក្សត្រអ្នកក្រុងកុសិនារា បានសាង

ក្នុងក្រុងកុសិនារា១, ទោណព្រាហ្មណ៍ បានសាងទុកក្នុងក្រុងកុសិនារាដែរ, ពួកក្សត្រមោរិយៈ បានសាងក្នុងក្រុងបិប្ផលិវ័ន, រួមជាព្រះស្តូប ៨ កន្លែង, បញ្ចូលព្រះស្តូបដែលដំកល់ព្រះកុម្ភៈ និងព្រះស្តូបដែលដំកល់ព្រះអង្គារៈ ២ ទៀត ត្រូវជា ១០ កន្លែង ។

២៤០- ស. ព្រះចេតិយរបស់ព្រះពុទ្ធជាម្ចាស់ ចែកចេញជាប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? មានន័យផ្សេងគ្នាដូចម្ដេច?

ឆ. ចែកចេញជា ៤ យ៉ាងគឺៈ ធាតុចេតិយ ១ បរិភោគចេតិយ១ ធម្មចេតិយ ១ ឧទ្ទេសិកចេតិយ ១ ។ ចេតិយទាំង ៤ នេះមានន័យផ្សេងគ្នាដូច្នេះ គឺ ចេតិយដែលបញ្ចុះព្រះសារីរិកធាតុ ហៅថាធាតុចេតិយ ។ ចេតិយដែលបញ្ចុះគ្រឿងពុទ្ធបរិក្ខារ ហៅថា បរិភោគចេតិយ ។ ចេតិយដែលបញ្ចុះព្រះធម៌មានបដិច្ចសមុប្បាទធម៌ជាដើម ហៅថា ធម្មចេតិយ ។ ព្រះពុទ្ធរូបដែលគេសាងឡើង ដើម្បីស្ទង់អង្គព្រះសម្មាសម្ពុទ្ធកាលគង់ព្រះជន្មនៅ ហៅថា ឧទ្ទេសិកចេតិយ ។

២៤១- ស. ការប្រតិស្ឋានពុទ្ធចេតិយ មានប្រយោជន៍ដូចម្ដេចខ្លះ?

ឆ. មានប្រយោជន៍ដូច្នេះ គឺនឹងបានជាគ្រឿងដាស់តឿនចិត្តប្រជាជន ឲ្យនឹករឭកដល់ព្រះសាស្ដារបស់យើង ឲ្យនឹករឭកដល់

សេចក្ដីល្អ នឹងគុណសម្បត្តិរបស់ព្រះអង្គ នឹងគុណដែលមានដល់ប្រជាជនជាច្រើន ជាគ្រឿងជំនួយឲ្យពុទ្ធបរិស័ទចំរើនពុទ្ធានុស្សតិបានងាយ ។ ការរឭកដល់ព្រះសាស្ដារបស់យើង ជាផ្លូវនាំឲ្យយើងយកតម្រាប់តាមគតិដំណើរតាមលំអានរបស់ព្រះអង្គ សឹងមានរឿងដំណាលថាៈ ព្រះថេរៈមួយអង្គកំពុងតែបានបោសសំអាតទីវត្តបានឃើញព្រះពុទ្ធរូប ដែលមាននិម្មិតចំពោះព្រះភ័ក្ត្រ លោកនឹករឭកដល់ព្រះពុទ្ធជាម្ចាស់ ហើយចំរើនវិបស្សនាបានសម្រេចព្រះអរហត្តផល ។

សង្គាយនា ៥

២៤២- ស. កាលសម្ដេចព្រះបរមសាស្ដាបរិនិព្វានផុតទៅហើយ ព្រះសង្ឃសាវ័កទាំងឡាយបាននាំព្រះពុទ្ធសាសនាតៗគ្នាមកដោយអាការដូចម្ដេច?

ឆ. ដោយអាការដូច្នេះគឺ កាលបើមានសេចក្ដីខុសកើតឡើង ក៏ប្រជុំគ្នាជម្រះហើយរួបរួមសេចក្ដីដែលត្រឹមត្រូវទុកជាពួកក្រុម ដែលហៅថា សង្គាយនា ។ សង្គាយនានោះ ដែលរាប់ថាជាគ្រាធំមាន ៥ ដង គឺក្នុងជម្ពូទ្វីប ៣ ដង, ក្នុងលង្កាទ្វីប ២ ដង ដូចតទៅនេះ ៖

ក- បឋមសង្គាយនា= ព្រះមហាកស្សបត្ថេរជាប្រធាន ព្រោះឮពាក្យរបស់សុភទ្ទវុឌ្ឍបព្វជិត ដែលនិយាយប្រមាថមើលងាយព្រះធម៌វិន័យ

ឲ្យជាដើម ទើបលោកបបួលការកសង្ឃចំនួន ៥០០ អង្គ សុទ្ធតែជាព្រះអរហន្ត បានចតុប្បដិសម្ភិទាញាណ ។ ព្រះមហាកស្សបត្ថេរជាអ្នកសួរ ព្រះឧបាលិត្ថេរជាអ្នកឆ្លើយព្រះវិនយបិដក, ព្រះអានន្ទត្ថេរជាអ្នកឆ្លើយព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក, ធ្វើសង្គាយនាក្នុងសត្តបណ្ណគុហាក្បែរភ្នំវេភារៈ ក្រុងរាជគ្រឹះ, ព្រះបាទអជាតសត្រូវជាសាសនូបត្ថម្ភក៍, ធ្វើ ៧ ខែទើបចប់ស្រេច ។ ធ្វើបឋមសង្គាយនានេះ ក្នុងកាលព្រះសាស្តាបរិនិព្វានកន្លងទៅហើយបាន ៣ ខែ ។

២) ទុតិយសង្គាយនា= ធ្វើខាងក្រោយព្រះសាស្តានិព្វានកន្លងទៅហើយបាន ១០០ ឆ្នាំ, ព្រះយសកាកណ្ឌបុត្រ ជាប្រធាន ព្រមដោយការកសង្ឃ ៧០០ អង្គ សុទ្ធតែជាព្រះអរហន្តបានចតុប្បដិសម្ភិទាញាណ ប្រារព្ធពួកភិក្ខុវជ្ជីបុត្រអ្នកប្រព្រឹត្តខុសធម៌វិន័យ បញ្ញត្តប្រកាន់វត្ថុ ១០ ប្រការថាត្រឹមត្រូវឲ្យជាដើមហេតុ ព្រះរេវតត្ថេរជាអ្នកចោទសួរវត្ថុ ១០ ប្រការ, ព្រះសព្វកាមិត្ថេរជាអ្នកឆ្លើយ, ធ្វើក្នុងវាលុការាម នគរវេសាលី, ព្រះបាទកាលាសោករាជជាសាសនូបត្ថម្ភក៍, ធ្វើ ៨ ខែទើបហើយស្រេច ។ ទុតិយសង្គាយនានេះ ធ្វើតាមរបៀបបឋមសង្គាយនាដែរ ប្លែកតែត្រង់រម្ងាប់វត្ថុ ១០ ប្រការប៉ុណ្ណោះ ។

វត្ថុ ១០ ប្រការដែលពួកភិក្ខុវជ្ជីបុត្រប្រព្រឹត្តនោះគឺ:

១) **កប្បតិ សិង្គិលោណកប្បោ** វិនយប្បញ្ញត្តិ ក្នុងសន្និធិការកសិក្ខាបទ ក្នុងសុត្តវិភង្គថា របស់ជាយាវកាលិក បើភិក្ខុបានទទួលប្រគេនហើយទុកឲ្យកន្លងរាត្រីយកមកឆាន់ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា អំបិលដែលគេដាក់ក្នុងភ្លាក់ស្នែង បើទុកឲ្យកន្លងរាត្រីទៅហើយយកមកឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន មិនត្រូវអាបត្តិឡើយ ។

២) **កប្បតិ ទ្វង្គុលកប្បោ** វិនយប្បញ្ញត្តិក្នុងវិកាលភោជនសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុឆាន់របស់ជាយាវកាលិកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា បើព្រះអាទិត្យជ្រេទៅហើយប្រមាណពីរធ្នាប់ ក៏គួរនឹងឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិឡើយ ។

៣) **កប្បតិ គាមន្តរកប្បោ** វិនយប្បញ្ញត្តិ ក្នុងបឋមបវារណាសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុហាមភោជនហើយក្រោកចាកទីអង្គុយនោះហើយ ទៅឆាន់អនតិរិត្តភោជន ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា បើភិក្ខុមានសេចក្តីគិតថាអញនឹងចូលទៅកាន់ស្រុកដូច្នេះ ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិឡើយ ។

៤) **កប្បតិ អាវាសកប្បោ** វិនយប្បញ្ញត្តិ ក្នុងឧបោសថក្ខន្ធកៈ

ទី ២ ក្នុងខន្ធកវិន័យថា ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង មានឧបោសថកម្មជាដើម ផ្សេងគ្នាមិនគួរ បើធ្វើផ្សេងគ្នា ត្រូវអាបត្តិទុក្កដ. កម្មដែលធ្វើនោះសោតក៏មិនមែនជាសង្ឃកម្មនោះឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថាត្រូវធ្វើបាន ឥតមានទាស់ខុសអ្វីឡើយ ។

៥) កប្បតិ អនុមតិកប្បោ វិនយប្បញ្ញត្តិ ក្នុងចម្មេយ្យ-ក្ខន្ធកៈទី ៩ ក្នុងខន្ធកវិន័យថា ភិក្ខុនឹងធ្វើសង្ឃកម្មទាំងពួង ត្រូវប្រជុំភិក្ខុដែលមាននៅក្នុងសីមាជាមួយគ្នាឲ្យមកប្រជុំព្រមជាប់ហត្ថបាសគ្នា ឬបាននាំឆន្ទបារិសុទ្ធិនៃភិក្ខុដែលមានកិច្ចធុរៈមិនបានមកកាន់ហត្ថបាសនោះ ទើបធ្វើបាន បើមិនធ្វើដូច្នេះ ហៅថាធ្វើកម្មជាពួក ត្រូវអាបត្តិទុក្កដ កម្មដែលធ្វើនោះសោត ក៏មិនមែនជាសង្ឃកម្មឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា មិនចាំបាច់មកជួបជុំគ្នាដូច្នេះទេ បើមកដល់មុននឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតមានទាស់ខុសអ្វីឡើយ ។

៦) កប្បតិ អាចិណ្ណកប្បោ ព្រះធម៌វិន័យ ពុទ្ធសាសនានេះ មានរបៀបរៀបរៀងគ្នាជាខ្នាតជាបន្ទាត់កំណត់ទុកជាខុសជាត្រូវ មកជាស្រេចហើយ សេចក្តីប្រតិបត្តិជាចរិតរបស់ព្រះឧបជ្ឈាយ៍អាចារ្យ ៗ គ្នាមក បើត្រូវសមតាមរបៀបធម៌វិន័យនោះ ទើបឲ្យសិស្សានុសិស្សទាំង

ពួងប្រតិបត្តិតាម បើមិនត្រូវមិនសមតាមរបៀបធម៌វិន័យទេ នោះសិស្សានុសិស្សទាំងពួងមិនត្រូវប្រតិបត្តិតាមឡើយ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា សេចក្តីប្រតិបត្តិជាចរិតទំនៀមទម្លាប់របស់ព្រះឧបជ្ឈាយ៍អាចារ្យទោះបីខុសក្តីត្រូវក្តី សិស្សានុសិស្សទាំងពួងត្រូវតែប្រតិបត្តិតាម ឥតមានទាស់ខុសអ្វីឡើយ ។

៧) កប្បតិ អមថិតកប្បោ ទឹកដោះស្រស់ដែលប្រែចាកភាពដើមហើយ តែមិនទាន់ក្លាយទៅជាទធិនៅឡើយ មានវិនយប្បញ្ញត្តិថា ភិក្ខុបានភោជនហើយក្រោកចាកទីអង្គុយនោះហើយ ឆាន់ទឹកដោះជាអនតិរិត្តនោះ ត្រូវអាបត្តិបាចិត្តិយៈ តាមន័យក្នុងបឋមប្បវារណា-សិក្ខាបទ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា ភិក្ខុឆាន់បាន មិនត្រូវអាបត្តិអ្វីឡើយ ។

៨) កប្បតិ ជលោគិ បាតុំ តរុណសុរា គឺសុរាដែលគេដាក់គ្រឿងស្រវឹងផ្សំគ្រាំជាមួយគ្នាហើយ តែនៅខ្សោយមិនទាន់ពេញជាទឹកស្រវឹងនៅឡើយ បើភិក្ខុផឹក ត្រូវអាបត្តិបាចិត្តិយៈ តាមន័យក្នុងសុរាបានសិក្ខាបទ ក្នុងសុត្តវិភង្គ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា តរុណសុរានេះ ភិក្ខុត្រូវផឹកបាន មិនត្រូវអាបត្តិអ្វីឡើយ ។

៩) កប្បតិ អទសកំ និសីទនំ វិនយប្បញ្ញត្តិក្នុងនិសីទន

សិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុនឹងធ្វើសំពត់និសីទនៈ ត្រូវធ្វើឲ្យមានជាយ បើមិនធ្វើដូច្នោះទេ ត្រូវអាបត្តិបាចិត្តិយៈ ។ ពួកភិក្ខុវជ្ជីបុត្រសំដែងឡើងថា សំពត់និសីទនៈ មិនបាច់ធ្វើឲ្យមានជាយក៏ប្រើប្រាស់បាន មិនត្រូវអាបត្តិឡើយ ។

១០) កប្បតិ ជាតរូបរជតំ វិនយប្បញ្ញត្តិក្នុងរូបិយសិក្ខាបទ ក្នុងសុត្តវិភង្គថា ភិក្ខុមិនត្រូវទទួលមិនត្រូវត្រេកអរ ចំពោះមាសប្រាក់ទេ បើទទួលឬត្រេកអរ ត្រូវអាបត្តិ និស្សគ្គិយៈបាចិត្តិយៈ ។ តែក្នុងមេណ្ឌកប្បញ្ញត្តិ ក្នុងភេសជ្ជក្ខន្ធកៈទី ៦ ក្នុងខន្ធកវិន័យមានព្រះពុទ្ធានុញ្ញាតឲ្យភិក្ខុត្រេកអរចំពោះចតុប្បច្ច័យ ដែលកើតអំពីរូបិយៈ គឺមាសប្រាក់នោះបាន តែបញ្ញត្តិហាមមិនឲ្យទទួលមិនឲ្យត្រេកអរចំពោះត្រង់មាសឬប្រាក់ឡើយ ។ ពួកភិក្ខុវជ្ជីបុត្រថា ភិក្ខុគួរទទួលនឹងត្រេកអរចំពោះត្រង់មាសប្រាក់នោះបាន មិនត្រូវអាបត្តិអ្វីឡើយ ។

ព្រះអរហន្តទាំងឡាយ បានសម្រេចសេចក្តីថា វត្ថុទាំង ១០ ប្រការនោះ ជាផ្លូវប្រតិបត្តិខុសអំពីរបៀបព្រះពុទ្ធសាសនាក្នុងគ្រាដែលលោកធ្វើបឋមសង្គាយនានោះឯង ។

គ- តតិយសង្គាយនា= កាលព្រះសាស្តាបរិនិព្វានកន្លងទៅបាន ២១៨ ឆ្នាំ, ព្រះបាទធម្មាសោករាជបានសោយរាជសម្បត្តិក្នុងសកល

ជម្ពូទ្វីប ក្រុងបាដលិបុត្រ ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ញ៉ាំងលាភសក្ការៈធំឲ្យប្រព្រឹត្តទៅ ដូច្នោះហើយពួកនិគ្រន្ថអន្យតិរ្ថិយ ដែលមានសេចក្តីក្រីក្រលំបាកប្រាថ្នាលាភសក្ការៈ លបចូលបួសបួមបន្លំក្នុងពុទ្ធសាសនមណ្ឌល ហើយយកលទ្ធិរបស់ខ្លួនមកសំដែងអាងថាជាពុទ្ធសាសនា កាលបើយ៉ាងនេះ ព្រះពុទ្ធសាសនាឈ្មោះថាមានមន្ទិលធំកើតឡើង ។ គ្រានោះព្រះសង្ឃបែកគ្នាខានធ្វើឧបោសថកម្ម អស់ ៧ ឆ្នាំ ។ ព្រះបាទធម្មាសោករាជទ្រង់ប្រារព្ធនឹងជម្រះមន្ទិលព្រះពុទ្ធសាសនា ទើបត្រាស់ប្រើយោធាបាក្យឲ្យអង្កេតចាប់ពួកនិគ្រន្ថ ផ្សឹកអស់រលីង ទុកតែព្រះសង្ឃដែលបរិសុទ្ធ ។ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរជាប្រធានជ្រើសរើសរកព្រះអរហន្តដែលបានចតុប្បដិសម្ភិទាញាណចំនួន១.០០០អង្គនាំគ្នាធ្វើសង្គាយនាលើកព្រះពុទ្ធសាសនាជាគ្រាទី ៣ ក្នុងអសោការាមក្រុងបាដលិបុត្រមហានគរ ធ្វើតាមរបៀបបឋមសង្គាយនានិងទុតិយសង្គាយនានោះដែរ, មានព្រះបាទធម្មាសោករាជជាសាសនូបត្ថម្ភក៍, ធ្វើអស់កាល ៩ ខែទើបហើយស្រេច ។ សង្គាយនាទី ១ ទី ២ នឹងទី៣ នេះធ្វើក្នុងជម្ពូទ្វីបទាំងអស់ ។

ឃ ចតុត្ថសង្គាយនា= ព្រះមោគ្គលីបុត្តតិស្សត្ថេរ បានធ្វើតតិយសង្គាយនារួចហើយលោករំពឹងមើលទៅក្នុងអនាគតកាលបានឃើញ

ជា ព្រះពុទ្ធសាសនានឹងទៅប្រតិស្ឋានក្នុងបច្ចន្តប្រទេស លោកទើបចាត់ព្រះអរហន្តទីណាស្រេពឲ្យនាំព្រះពុទ្ធសាសនាទៅប្រតិស្ឋាន ទុកនៅប្រទេសផ្សេងៗ ។ ចំណែកព្រះមហិន្ទត្ថេរ បានទទួលថេរបញ្ញាឲ្យទៅប្រកាសព្រះពុទ្ធសាសនានៅនាលង្កាទ្វីប ញ៉ាំងព្រះបាទទេវានម្បិយតិស្សៈ និងអ្នកលង្កាឲ្យមានសទ្ធាជ្រះថ្លា ។

គ្រានោះព្រះនាងអនុឡាដែលជាជាយារបស់ព្រះមហានាគឧបរាជជាព្រះរាជអនុជា មានប្រាថ្នាបង់បព្វជ្ជា ជាភិក្ខុនី ។ ព្រះបាទក្រុងលង្កាទ្រង់បញ្ជូនរាជទូតទៅក្រុងបាដលិបុត្រជម្ពូទ្វីប ដើម្បីក្រាបទូលព្រះបាទធម្មាសោករាជសូមអារាធនាព្រះសង្ឃមិត្តាថេរីព្រះរាជធីតា មកសម្រេចកិច្ចឧបសម្បទាដល់ស្ត្រីជាតិសីហឡៈ និងសូមអញ្ជើញមែកព្រះមហាពោធិព្រឹក្សមកផង ។ ព្រះបាទធម្មាសោករាជក៏ទ្រង់ព្រះរាជានុញ្ញាតតាម ។

កាលព្រះពុទ្ធសាសនារុងរឿងឡើងក្នុងលង្កាទ្វីបហើយ ព្រះបាទទេវានម្បិយតិស្សៈក្រាស់សួរព្រះមហិន្ទត្ថេរថា ព្រះពុទ្ធសាសនាបានឈ្មោះថា ប្រតិស្ឋានក្នុងលង្កាទ្វីបហើយឬនៅឡើយទេ? ព្រះថេរៈថ្វាយព្រះពរថា ព្រះពុទ្ធសាសនាដែលនឹងបានយាងចុះសឹបស្ងួននោះ លុះតែបានលើកតម្កើងព្រះធម៌វិន័យ គឺជាធ្វើសង្គាយនា ។ ព្រះបាទទេវានម្បិយតិស្សៈក៏ប្រារព្ធដើម្បីនឹងសង្គាយនា ទើបទ្រង់អារាធនាព្រះមហិន្ទត្ថេរឲ្យជា

អ្នកបុច្ឆា, ព្រះអរិដ្ឋមហាថេរ ជាអ្នកវិសជ្ជនា, ធ្វើតាមរបៀបនៃសង្គាយនាទាំង៣គ្រាខាងដើមនោះដែរ ។ ព្រះសង្ឃស្រុកលង្កាបានសូត្ររៀនចេះចាំព្រះពុទ្ធវចនៈ បែកធ្លុះធ្លាយ ឥតមានសល់ជំពាក់ទាក់ទើស អាចធ្វើជាគណៈបាមោក្ខាចារ្យប្រៀនប្រដៅកុលបុត្រក្នុងទីនោះបាន ល្មមឲ្យសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាមានឫសតាំងចុះសឹបក្នុងលង្កាទ្វីបថែន ។

ចតុត្ថសង្គាយនានេះ បានធ្វើក្នុងថូបារាម ក្នុងអនុរាធបុរីមានការកសង្ឃ៦៨.០០០អង្គ មានព្រះបាទទេវានម្បិយតិស្សៈ ក្សត្រក្រុងលង្កាជាសាសនូបត្ថម្ភក៍ ធ្វើអស់កាល ១០ ខែទើបហើយស្រេច ក្នុងរវាងព្រះពុទ្ធសករាជ ២៣៦ ឆ្នាំ ។

ង-បញ្ចមសង្គាយនា= ព្រះបាទទេវានម្បិយតិស្សៈ ក្សត្រក្រុងលង្កាទ្វីប ទ្រង់មានបុញ្ញានុភាពប្រកបដោយបញ្ញាច្រើន បានបំពេញព្រះរាជកុសលផ្សេងៗ ជាអនេកហើយទីវង្គតទៅ ។ បន្ទាប់អំពីនោះមក ព្រះបាទឧត្តិយៈ ព្រះមហាសិវៈ និងព្រះបាទសុរតិស្សៈ បានសោយរាជ្យជាលំដាប់គ្នា ហើយទំនុកបំរុងព្រះពុទ្ធសាសនាតរៀងមក ។ ចំណោរចីរកាលមកខាងក្រោយ វង្សក្សត្រលង្កាទ្វីបបេះកែខ្ជិល ត្រោះថ្នាក់អំពីបច្ចាមិត្តរឿយៗ រហូតដល់ផ្លាស់ព្រះរាជវង្សថ្មី ច្ពោះ-

ហើយព្រះពុទ្ធសាសនាបែះតែលិចអណ្ដែត ៗ ទៅតាមវង្សក្សត្រដែលជ្រះថ្លានឹងមិនជ្រះថ្លា ។

ដល់មកសម័យព្រះបាទវដ្ដគាមិនីអភ័យ បានកំចាត់បច្ចាមិត្រ អស់ហើយទ្រង់បានសោយរាជ្យ សិប់សួនជាក្សត្រឯករាជ្យ ទ្រង់បានសាងវត្តអភយគិរីប្រគេនព្រះតិស្សត្ថេរព្រមទាំងទំនុកបំរុង ដោយចតុប្បច្ច័យដ៏បរិបូណ៌ ជាហេតុនាំឲ្យព្រះសង្ឃមហាវិហារកើតសេចក្ដីប្រណែនលើកទោសព្រះតិស្សត្ថេរថា ប្រឡូកប្រឡំដោយគ្រហស្ថ ។ គ្រានោះព្រះសង្ឃបែកគ្នាជាពីរពួក គឺពួកមហាវិហារ ១; ពួកខាងអភយគិរីវិហារ ១ ។

ក្នុងសម័យនោះ ពួកព្រះសង្ឃដែលមានបញ្ញាច្រើនបានឃើញហេតុដែលនាំឲ្យសាបសូន្យព្រះពុទ្ធសាសនាដូច្នោះហើយ ទើបនាំគ្នាលើកសង្គាយនាជាគ្រាទី ៥ បានចារឹកព្រះត្រៃបិដកជាតួអក្សរដាក់ក្នុងស្លឹករឹតរាប់ថាជាគ្រាដំបូងដែលប្រើអក្សរជាគ្រឿងកត់ត្រាព្រះពុទ្ធវចនៈ ។

បញ្ចសង្គាយនានេះធ្វើក្នុងមហាវិហារនាលង្កាទ្វីប មានការកសង្ឃ ១.០០០អង្គ មានព្រះពុទ្ធទត្តត្ថេរជាប្រធានជាអ្នកបុច្ឆា, ព្រះតិស្សត្ថេរជាអ្នកវិសជ្ជនា ព្រោះពួកសង្ឃបែកគ្នាជា ២ ពួកឲ្យជាដើមហេតុ, ព្រះបាទវដ្ដគាមិនីអភ័យ ក្សត្រក្រុងលង្កាទ្វីបជាសាសនូបត្ថម្ភក៏, ធ្វើអស់កាល ១២ ខែទើបស្រេច ។

ចំណេរចរកាលតៗមក លោកអ្នកប្រាជ្ញទាំងឡាយ បានតែងគម្ពីរអដ្ឋកថា ដីកា អនុដីកាព្រមទាំងសទ្ទសាស្ត្រឲ្យជាឧបការៈដល់ពុទ្ធសាសនិកជនកាន់តែច្រើនឡើង ទាល់តែប្រជាជនក្នុងនានាប្រទេសដែលរាប់អានព្រះពុទ្ធសាសនា បានមកប្រតិស្ឋានទុកជាចេតិយជាទីគោរពនឹងបានតែងឡើងថែមទៀតឲ្យបានផ្សាយច្រើនខ្លួទៅក្នុងពុទ្ធសាសនមណ្ឌល ។ ព្រះសង្ឃសាវកទាំងឡាយបាននាំព្រះពុទ្ធសាសនាតៗគ្នាមកដោយអាការដូចពោលមកនេះឯង ។

ប្រស្នារាយរង់ក្នុងពុទ្ធប្រវត្តិ

២៤៣ ស. ព្រះសាស្ដាទ្រង់ប្រកាសសាសនាឲ្យផ្សាយខ្លួទៅដោយវិធីដូចម្ដេច ?

ឆ. ដោយវិធីដូច្នេះគឺ៖ ក្នុងជាន់ដំបូង កាលព្រះអង្គបានត្រាស់ដឹងហើយ បានយាងទៅទូន្មានដោយព្រះអង្គឯងខ្លះ, លុះមានអ្នកជឿជ្រះថ្លាថ្វាយខ្លួនជាសាវកចូលបួសក្នុងធម៌វិន័យហើយ ទ្រង់ឃើញថាសាវកមានគុណធម៌ដ៏បរិបូណ៌ហើយ ក៏ទ្រង់បញ្ជូនសាវកដែលជាអ្នកអង់អាចឲ្យទៅប្រកាសសាសនា តាមស្រុកនិគមរាជធានីតូចធំ ដើម្បីឲ្យកើតសទ្ធាជ្រះថ្លាដល់បរិស័ទនោះៗ ខ្លះ ។

២៤៤ – ស. ព្រះសាវកបានជាកំឡាំងរបស់ព្រះសាស្ដាដូចម្ដេច ?

ឆ. បានជាកំឡាំងរបស់ព្រះសាស្តាក្នុងកាលដែលព្រះអង្គគង់ព្រះជន្មនៅ ដោយបានជួយគ្រាច់ទៅប្រកាសព្រះសាសនាក្នុងស្រុកតូចធំ ។ លុះព្រះសាស្តានិព្វានទៅហើយ បាននាំគ្នារក្សាព្រះសាសនានឹងធ្វើសង្គាយនា រៀបរៀងព្រះធម៌វិន័យឲ្យមានរបៀបរៀបដែនរហូតមកដល់សព្វថ្ងៃនេះ ។

២៤៥-ស. មនុស្សអ្នកកាន់ពុទ្ធសាសនាក្នុងបាលីចាត់ជាប៉ុន្មានពួក ? ណាឈ្មោះអ្វី ?

ឆ. ចាត់ជា ៤ ពួក ហៅថា បរិស័ទ ៤ គឺភិក្ខុបរិស័ទ ១ ភិក្ខុនីបរិស័ទ ១ ឧបាសកបរិស័ទ១ ឧបាសិកាបរិស័ទ១ ។

២៤៦.ស. បរិស័ទទាំង ៤ នោះ អ្នកណាជាដើមរបស់បរិស័ទណា?

ឆ. អញ្ញាកោណ្ឌញ្ញៈជាដើមរបស់ភិក្ខុបរិស័ទ ព្រះនាងបជាបតិគោតមីជាដើមរបស់ភិក្ខុនីបរិស័ទ, បិតាព្រះយសត្ថេរជាដើមរបស់ឧបាសកបរិស័ទ, មាតាព្រះយសត្ថេរជាដើមរបស់ឧបាសិកាបរិស័ទ; បើជាទ្វេវាចិកឧបាសក គឺតបុស្សៈនឹងភល្លិកៈជាដើមគេ ។

២៤៧-ស. អនុបុព្វីកថា មានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ មាន ៥ យ៉ាងគឺ ទាន១ សីល១ ស្ថានសួគ៌១ ទោសរបស់កាម១ នេក្ខម្មៈ គឺការបួសចេញចាកកាម១ ។

២៤៨-ស. អ្នកដែលនឹងទទួលព្រះធម៌ទេសនាអនុបុព្វីកថា បាននោះត្រូវប្រកបដោយអង្គប៉ុន្មាន ?

ឆ. ត្រូវប្រកបដោយអង្គ ៣, គឺកើតជាមនុស្ស១ ជាគ្រហស្ថ ១ ហើយជាអ្នកមានឧបនិស្ស័យចាស់ក្លាគួរសំរេចលោកុត្តរគុណក្នុងទីនោះ ១ លុះតែព្រមដោយអង្គ ៣ នេះ ទើបព្រះសាស្តាទ្រង់សំដែងអនុបុព្វីកថាប្រោស ។

២៤៩_ស. អភិញ្ញាទេសិតធម៌ គឺអ្វីខ្លះ ? ព្រោះហេតុអ្វីបានជាហៅដូច្នោះ ?

ឆ. អភិញ្ញាទេសិតធម៌នោះគឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គ ៨ ។ បានជាហៅថាអភិញ្ញាទេសិតធម៌ព្រោះហេតុថាធម៌ទាំងនេះព្រះអង្គទ្រង់សំដែង ដើម្បីឲ្យសត្វដឹងច្បាស់ឲ្យឃើញពិត ក្នុងធម៌ដែលគួរដឹងគួរឃើញ ។

២៥០ ស. ធម៌ទាំងនោះ បើមិនហៅថា អភិញ្ញាទេសិតធម៌ទេនឹងហៅថាអ្វីបានទៀត ? ព្រោះហេតុអ្វី ?

ឆ. ហៅថាពោធិបក្ខិយធម៌ក៏បាន ព្រោះហេតុថាធម៌ ៣៧ ប្រការនោះ ជាចំណែកនៃសេចក្តីត្រាស់ដឹង ។

២៥១ ស. ក្នុងគ្រាមុនពុទ្ធកាលមនុស្សទាំងឡាយក៏ទំយកចិត្តទុកដាក់

វិះគេធម៌ជាច្រើនមកហើយ មែនឬទេ ? ប៉ុន្តែហេតុអ្វី បានជាមិនឮល្បីឲ្យប្រាកដថា ឈ្មោះអ្នកណាខ្លះ ដែលបានឆ្លងផុតទុក្ខទៅហើយ ? កាលព្រះសាស្តាបានត្រាស់ដឹងឡើង ទ្រង់ទេសនាប្រាប់ឧបាយឲ្យផុតចាកទុក្ខយ៉ាងណា ? ចូរលើកគោលឲ្យសមមកមើល !

ច. មែន ។ ប៉ុន្តែអ្នកទាំងនោះមិនបានឆ្លងផុតទុក្ខទេ ព្រោះមិនទាន់ដឹងទីកន្លែងដែលសូន្យទុក្ខ ដែលជាទីគួរឲ្យចង់បាន, លុះតែព្រះសាស្តាបានត្រាស់ដឹងឡើងទ្រង់ចង្អុលប្រាប់ឧបាយថា ទុក្ខនឹងកើតឡើងបានក៏ព្រោះតែតណ្ហា ។ នឹងរលត់ទៅបានក៏ព្រោះតែប្រតិបត្តិតាមផ្លូវមជ្ឈិមាបដិបទាមានអង្គ ៨ ដូចមានសេចក្តីប្រាកដក្នុងព្រះធម្មចក្កប្បវត្តនសូត្រជាបឋម-ទេសនាស្រាប់ហើយ ។

២៥២- ស. ចូរចង្អុលគួយ៉ាងឲ្យឃើញថា ព្រះសាស្តាទ្រង់កែប្រ-សាសនាព្រាហ្មណ៍មកមើល! ហើយអធិប្បាយឲ្យឃើញថាល្អវិសេសជាងសាសនាចាស់យ៉ាងណា ?

ច- ព្រះសាស្តាទ្រង់សំដែងព្រះធម[illegible]នាដើម្បីកែប្រែសាសនាព្រាហ្មណ៍នោះមានច្រើនយ៉ាង ប៉ុន្តែក្នុងទីនេះ នឹងចង្អុលដោយឯកទេស ។ សាសនាចាស់ប្រកាន់ថា មនុស្សដែលនឹងបានឈ្មោះថាជាព្រាហ្មណ៍អ្នកខ្ពង់ខ្ពស់ ព្រោះជាប់សែស្រឡាយមកអំពីព្រហ្ម, ព្រមទាំង

ប្រកាន់ការងូតទឹកលាងបាបក្នុងស្ទឹងដ៏ស័ក្តិសិទ្ធិតាមសម័យ ជាហេតុឲ្យបរិ-សុទ្ធជាដើមដែលជាបច្ច័យនៃការប្រកាន់គោត្រជាហេតុឲ្យរង្កៀសគ្នាដោយជាតិ ប្រកាន់សេចក្តីបរិសុទ្ធិដោយហេតុខាងក្រៅដែលជាការបែកជាន់ថែកថ្នាក់មនុស្សមិនឲ្យរួមសាមគ្គីគ្នា កាត់ផ្លូវចំរើននៃវណ្ណៈដទៃ ធ្វើឲ្យជនចូលចិត្តខុសពេញចិត្តធ្វើតែអំពើរកក្រក់គ្មានមេត្តាដល់គ្នានឹងគ្នា ។ សម្តេចព្រះបរមសាស្តាទ្រង់កែថា មនុស្សដែលនឹងបានឈ្មោះថាជាព្រាហ្មណ៍ (អ្នកវិសេសមែនពិត) ក៏ព្រោះតែគុណសម្បត្តិ,អ្នកដែលបរិសុទ្ធក៏ព្រោះតែសន្តានចិត្តប្រាសចាកកិលេសជាគ្រឿងសៅហ្មងជាដើម ដែលជាការកាត់សេចក្តីរង្កៀសគ្នាក្នុងរបស់មិនត្រឹមត្រូវចងសាមគ្គីគ្នា បើកផ្លូវសេចក្តីចំរើនដល់មនុស្សគ្រប់ជាន់ឲ្យឃើញសេចក្តីពិតមែនដោយការស្តាប់ និងរៀនសូត្រហើយប្រតិបត្តិតាម ។ សេចក្តីនេះមានព្រះធម៌ទេសនាដែលព្រះសាស្តាទ្រង់ប្រទានដល់ព្រាហ្មណ៍ហុហុកជាតិជាគ្រឿងរុញ ។

២៥៣- ស. កាលដែលព្រះសាស្តាប្រាថ្នាយកជដិលទាំង ៣ ឲ្យជួយជាកម្លាំងប្រតិស្ឋានព្រះសាសនាក្នុងដែនមគធៈនោះ មិនគឺចង្អុលឲ្យឃើញថា ព្រះអង្គទាល់បញ្ហារស់សេចក្តីអង់រេចទៅហើយឬ ។ ថាដូចម្តេចទៅវិញ ?

ច. កាលបើគិតស៊ើបក៏ឃើញថា ព្រះអង្គទាល់បញ្ហារស់សេចក្តីអង់រេចមែន ប៉ុន្តែបើពិនិត្យពិចារណាឲ្យល្អិតទៅទៀត ត្រូវរ៉

ជាចង្អុលឲ្យឃើញថា ព្រះសាស្ដាមានព្រះបញ្ញាជ្រាលជ្រៅ, មានដំណើរឧបាយវិធីយ៉ាងឯក ជាអ្នកដឹងកាលៈទេសៈ, ធ្វើការត្រូវដល់ហេតុបានទទួលសេចក្ដីស្រួលជាផល ចេះប្រើមនុស្សដែលអង់អាចឲ្យជាកម្លាំង, សូម្បីធ្វើការតែបន្តិចបន្តួច ក៏អាចញុំាងការធំឲ្យសម្រេចបាន, គួរជាទិដ្ឋានុគតិរបស់អនុជនបានយ៉ាងល្អ; ប៉ុណ្ណោះក៏ចង្អុលឲ្យឃើញថា ព្រះអង្គមានព្រះបញ្ញាឈ្លាសវៃត្រឹមណា មិនមែនព្រះអង្គទាល់គំនិតបញ្ញាទេ ៕

២៥៤- ស. មនុស្សក្រៅព្រះពុទ្ធសាសនាគេនិយាយគ្នាថា ព្រះពុទ្ធសាសនាបានជាផ្សាយទៅបានឆាប់រហ័សនោះ ព្រោះផ្សាយទៅក្នុងពួកជនជាន់ខ្ពស់ជាមុន ហើយបានពឹងស្រ័យកម្លាំងរបស់ជនទាំងនោះ ជួយទំនុកបំរុង ទើបផ្សាយទៅបានរហ័ស មិនវិសេសនឹងអស្ចារ្យដូចជាសាសនារបស់គេដែលផ្សាយទៅក្នុងជនជាន់ទាបជាមុនទេ រឿងនេះ មានសេចក្ដីពិតត្រឹមណា សូមឆ្លើយតាមយល់ ?

ឫ. ការផ្សាយទៅរហ័សឬយឺតក្នុងមនុស្សជាន់ខ្ពស់ឬជាន់ទាបជាមុននោះ មិនសូវជាសំខាន់ប៉ុន្មានទេ ឯការសំខាន់នៅត្រង់សាសនានោះ ជារបស់ពិតល្អឬមិនពិតប៉ុណ្ណោះ, បើល្អពិតហើយនឹងផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់ ឬ ជាន់ទាបមុនក៏បាន; តែថាសម្រាប់អ្នកមានគំនិតល្អិតជ្រាលជ្រៅ ត្រូវតែផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់មុន ព្រោះថាមនុស្ស

ជាន់ខ្ពស់ជាអ្នកមានគំនិតបញ្ញាដ៏ខ្ពង់ខ្ពស់ កាលបើមនុស្សជាន់ខ្ពស់នោះទទួលរាប់រងហើយ មិនបាច់ព្រួយថ្វីដល់មនុស្សជាន់ទាប ដែលជាមនុស្សស្ដាប់ងាយជឿងាយ ដោយមិនចេះប្រើវិចារណញ្ញាណ ឬក៏គ្មានវិចារណញ្ញាណនឹងប្រើ កាលបើឃើញមនុស្សជាន់ខ្ពស់ទទួលរាប់រងហើយ ក៏បណ្ដោយទទួលសាធុងាយៗ ៗ ការផ្សាយទៅក្នុងមនុស្សជាន់ខ្ពស់មុន មានសេចក្ដីល្អជាង ច្រើនប្រការ គឺៈ ១- នឹងធ្វើឲ្យអស់សង្ស័យក្នុងរឿងជារបស់ល្អថ្លៃថ្នូរ. ២- នឹងផុតពាក្យតិះដៀលថាល្អតែខាងផ្លូវបញ្ឆោតមនុស្សងងឹតងងល់, ៣- នឹងធ្វើឲ្យផុតការមើលងាយ ថាជារបស់ថោកទាបមិនសមគួរដល់អ្នកល្អជាដើម ៕ ប៉ុន្តែបើបានទទួលការរាប់រងរបស់ជនជាន់ទាបនោះផងទៀតហើយ ក៏នឹងបានផលល្អដល់អ្នកផ្សាយមួយជាន់ទៀត ដូចជាគេហុចរបស់ឲ្យអ្នកដឹងដំឡៃពិនិត្យមើល មិនវង្វេងទៅហុចកែវឲ្យសត្វពានរ កាត់ថ្លៃដូច្នោះទេ តាមដែលបានឆ្លើយមកនេះ សេចក្ដីពិតនឹងមានយ៉ាងណា ក៏សូមឲ្យសន្និដ្ឋានទៅចុះ ៕

២៥៥- ស. ព្រះសាស្ដាជាអ្នកត្រាស់ដឹងព្រះធម៌ព្រះអង្គឯង, ព្រះធម៌ជាពាក្យប្រដៅរបស់ព្រះអង្គមែនឬទេ ? ពាក្យដែលថាព្រះអង្គទ្រង់គោរពព្រះធម៌នោះតើទ្រង់ធ្វើដូចម្ដេច ? ចូរអធិប្បាយនិងលើករឿងមកអាងឲ្យឃើញពិតផង !

ប. ព្រះធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះអង្គមែនហើយ, ប៉ុន្តែព្រះអង្គគោរពក្នុងព្រះធម៌នោះ គឺទ្រង់ធ្វើយ៉ាងនេះ ៖

ក) មិនទ្រង់លះបង់ព្រះពុទ្ធកិច្ច = សូមលើករឿងក្រង់ផ្តើមធម្មទេសនាជំហាន កាលគង់ក្រោមដើមអជបាលនិគ្រោធ ។ មុនដំបូងទ្រង់ពិចារណាធម៌ដែលបានត្រាស់ដឹង ជាគុណជ្រាលជ្រៅ ក្រៃមនុស្សអ្នកត្រេកអរក្នុងកាមគុណនឹងដឹងតាមបាន ព្រះហឫទ័យក៏បង្អោនទៅដើម្បីព្រងើយកន្តើយ មិនគិតសំដែងធម៌ទូន្មានប្រដៅជន ប៉ុន្តែព្រះករុណាមកដាស់តឿនព្រះហឫទ័យឲ្យទ្រង់ប្រារព្ធដល់ពុទ្ធវេនេយ្យ ដ៏មានផ្សេងៗ គ្នា ដែលគួរនឹងបានទទួលប្រយោជន៍អប់រំទៅតាមលំដាប់ ទើបទ្រង់តាំងព្រះទ័យនឹងសំដែងធម៌, រឿងនេះ ចង្អុលឲ្យឃើញថា ព្រះអង្គទ្រង់គោរពក្នុងធម៌គឺពុទ្ធកិច្ច មិនសោយវិមុត្តិសុខតែមួយព្រះអង្គឯង ។ ន័យមួយទៀតថា ព្រះអង្គបានទតឃើញឧបនិស្ស័យរបស់អ្នកណានៅជិតឬឆ្ងាយ សូម្បីជាមនុស្សកាចអាក្រក់រឹងរូសក៏ដោយក៏ទ្រង់យាងទៅទូន្មានដែរ ។

ខ) ទ្រង់ប្រព្រឹត្តធម៌គឺគុណសេចក្តីល្អជាគោល= គប្បីឃើញក្នុងវេលាជិតនឹងបរិនិព្វានត្រាស់ទូន្មានភិក្ខុសង្ឃថា ធម្មទីបា ភិក្ខវេ វិហរថ ធម្មប្បដិសរណា អនញ្ញសរណា ប្រែថា "ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរនៅមានធម៌ជាទីពំនាក់មានធម៌ជាទីពឹង កុំយកវត្ថុដទៃជាសរណៈ

ទីពឹងឡើយ ។ ក្នុងទីដទៃមានរឿងដំណាលថា ទ្រង់ព្រះពុទ្ធតម្រិះថា មនុស្សមិនមានទីគោរពរមែងនៅលំបាក ប៉ុន្តែព្រះអង្គសំឡឹងមើលអ្នកដទៃមិនឃើញថា គួរជាទីគោរពរបស់ព្រះអង្គ ។ ទើបទ្រង់តាំងព្រះទ័យកាន់យកព្រះធម៌ជាទីគោរពរបស់ព្រះអង្គ ។

គ) មិនទ្រង់បំពារបំពានអំណាចនៃហេតុ= គប្បីឃើញក្នុងកាលប្រទានព្រះពុទ្ធានុញ្ញាតឲ្យមាតុគ្រាមឧបសម្បទជាភិក្ខុនីដើមដំបូង ព្រះអង្គមិនព្រមប្រទាន ខាងក្រោយព្រះអានន្ទក្រាបទូលសួរថា ស្ត្រីជាអភព្វបុគ្គល ដើម្បីនឹងសម្រេចធម៌វិសេសដូចបុរសបានដែរឬទេ ? ព្រះអង្គត្រាស់ថាបាន ។ ព្រះអានន្ទក្រាបទូលសូមឲ្យប្រទានព្រះពុទ្ធានុញ្ញាតម សូម្បីមិនពេញព្រះហឫទ័យ ក៏នៅតែទ្រង់ព្រះអនុញ្ញាតដែរ ។ ធ្វើយមកប៉ុណ្ណោះ ល្មមជាសំអាងបានហើយ ។

២៥៦-សួ. បុថុជ្ជនមានការរឹករវប្រេបូកប្រេបល់ណាស់ ។ ព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច នៅជាមួយនឹងបុថុជ្ជន មានរឿងគួរឲ្យខានព្រះហឫទ័យជាយ៉ាងខ្លាំងៗ ដូចជាចាប់ក្តាមដាក់ចង្អេរ ហេតុអ្វីក៏ទ្រង់អត់ធន់នៅបាន ? បើទុកជាព្រះអង្គបរិសុទ្ធយ៉ាងក្រៃលែង មិនមានកិលេសដែលជាហេតុឲ្យធុញទ្រាន់ព្រះទ័យក៏មែន ប៉ុន្តែបើទ្រង់គង់នៅតែស្ងៀមៗទៅ ក៏មិនខូចសេចក្តីបរិសុទ្ធិនោះដែរ ?

ប. ហេតុតែព្រះមហាករុណាមកចង់ភ្ជាប់ឲ្យទ្រង់គង់នៅបាន ព្រោះបានពិចារណាឃើញរួចហើយ ក្នុងកាលធ្វើធម្មទេសនាធិដ្ឋាន ថាប្រៀបដូចផ្កាឈូកមានបែបផ្សេងៗគ្នា តាំងពីលូតឡើងផុតទឹករហូតដល់លិចទៅក្នុងទឹក គួរនឹងបានទទួលអប់រំក្នុងធម៌ជាន់ខ្ពស់ឡើងទៅដោយលំដាប់ ទ្រង់សំដែងធម៌តាំងពីទប្រតិបត្តិក្នុងផ្លូវឃរាវាសរៀងរហូតឡើងទៅដល់ត្រៃសិក្ខា ក៏តាមព្រះពុទ្ធប្រណិធាននេះ ។ កុំថាដល់ព្រះពុទ្ធជាម្ចាស់ឡើយ សូម្បីតែស្ត្រីជាម្ដាយរបស់កូនក្មេង ក៏គង់តែអត់ធន់សេចក្ដីទាននឹងការពើសរបស់កូនក្មេងបានដែរ មិនបណ្ដែតបណ្ដោយឲ្យកូនទៅតាមយថាកម្មតាមចិត្តវាទេ ។

២៥៧-ស. ការបូជាព្រះអង្គយ៉ាងណា ដែលព្រះអង្គត្រាស់ថាជាការបូជាយ៉ាងត្រៃលែង ? ហេតុអ្វីបានជាត្រាស់យ៉ាងនោះ ?

ប. ការប្រតិបត្តិតាមពាក្យប្រដៅរបស់ព្រះអង្គដែលហៅថាព្រះសាសនា បានឈ្មោះថា បដិបត្តិបូជា ៗ នេះព្រះអង្គត្រាស់ថាជាការបូជាយ៉ាងត្រៃលែង ។ ព្រោះការបូជាម្យ៉ាងទៀតដែលហៅថាអាមិសបូជាគឺការបូជាដោយអាមិសមានផ្កាភ្ញីធូបទៀនជាដើម ជាការបូជាខាងក្រៅ សូម្បីមានផលក៏មិនស្មើនឹងការប្រតិបត្តិតាម ។ បើបុគ្គលឃើញតែត្រឹមការបូជាដោយអាមិសទៅទាំងអស់គ្នា មិនមានអ្នកណាសូត្ររៀនព្រះបរិយត្តិធម៌

នឹងប្រតិបត្តិតាម, ព្រះសាសនាក៏នឹងសាបសូន្យអន់ថយចុះលុះដល់អន្តរធានទៅឆាប់ ព្រោះមិនមានគោល ។ បើមានបុគ្គលសូត្ររៀនហើយប្រតិបត្តិតាមដរាបណា ព្រះសាសនាក៏ឈ្មោះថា តាំងនៅបានដរាបនោះ ព្រោះមានគោល ។ គោលដោយខ្លី ព្រះសាសនាគឺពាក្យប្រៀនប្រដៅនឹងតាំងនៅបាន ក៏ព្រោះមានមនុស្សរៀនសូត្រហើយប្រតិបត្តិតាម, នឹងវិនាសអស់ទៅក៏ព្រោះមិនមានមនុស្សសូត្ររៀនមិនប្រតិបត្តិតាម ។ ព្រោះហេតុនោះ សម្ដេចព្រះមានព្រះភាគ ទើបទ្រង់សំដែងថា ការប្រតិបត្តិតាម ជាការបូជាដ៏ត្រៃលែង ។

២៥៨-ស. ព្រះឱវាទដែលទ្រង់ប្រទានដល់បរិស័ទទាំង៤នោះ មានដូចម្ដេចខ្លះ? ចូរសំដែងល្មមឲ្យឃើញជាតួយ៉ាងមកមើល !

ប. បរិស័ទទាំង ៤ នោះរួមចូលជា ២ ពួកគឺ បព្វជិតបរិស័ទ ១ ពួក គ្រហស្ថបរិស័ទ ១ ពួក ។ ព្រះឱវាទដែលទ្រង់ប្រទានដល់បព្វជិតបរិស័ទរួមចូលក្នុងសិក្ខា ៣ គឺ សីល, សមាធិ, បញ្ញា ។ ព្រះឱវាទដែលទ្រង់ប្រទានដល់គ្រហស្ថបរិស័ទ រួមចូលក្នុងប្រយោជន៍បច្ចុប្បន្ន នឹងប្រយោជន៍ខាងមុខ ។ ឯប្រយោជន៍បច្ចុប្បន្ន គឺឲ្យឧស្សាហ៍ធ្វើការងារ ចេះរក្សាទ្រព្យដែលបានមកព្រោះការងារ; ចេះចិញ្ចឹមជីវិតល្មមសមគួរតាមកំឡាំងទ្រព្យ, ចេះសេពគប់មនុស្សល្អជាមិត្រ, ចេះចាយវាយទ្រព្យ

ក្នុងផ្លូវដែលជាប្រយោជន៍, បេះប្រព្រឹត្តដល់បុគ្គលដែលខ្លួនជាប់ជំពាក់ជង់តាមសមគួរ ។ ប្រយោជន៍ខាងមុខទ្រង់ប្រដៅឲ្យសន្សំគុណសម្បត្តិគឺ សទ្ធា សីល ចាគៈ បញ្ញា ឬបំពេញ ហិរិ ឱត្តប្បៈនិងសុតៈឲ្យគ្រប់ជា អរិយទ្រព្យ ៧ ជាដើម ។

២៥៩-ស. ចូរពណ៌នាអំពីរឿងដែលព្រះសាស្តាទ្រង់គ្រប់គ្រងភិក្ខុបរិស័ទ តាំងពីដំបូងមកមើល ?

ឆ. ព្រះសាស្តាទ្រង់គ្រប់គ្រងភិក្ខុបរិស័ទដោយអាការៈយ៉ាងនេះ គឺកាលមុនដំបូងដែលទើបនឹងបានត្រាស់ថ្មី ព្រះអង្គទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា ដល់កុលបុត្រដែលមានសទ្ធាក្នុងផ្នួស គឺឧបសម្បទចំពោះព្រះភក្ត្រដោយអាការត្រាស់ថា "អ្នកចូរជាភិក្ខុមកចុះ" ដូច្នេះជាដើម ហើយអ្នកនោះក៏សម្រេចជាឯហិភិក្ខុ ។ លុះកាលតមក ព្រះសាសនាផ្សាយខ្ចរទៅក្នុងទិសផ្សេងៗ មានជនទាំងឡាយកើតសទ្ធាជ្រះថ្លាក្នុងព្រះសាសនាច្រើនឡើង មកសូមឧបសម្បទ ព្រះអង្គក៏ប្រទានតិសរណាគមនូបសម្បទា គឺឧបសម្បទដោយអាការដែលទទួលត្រៃសរណគមន៍ចំពោះមុខសង្ឃ ។ លុះកាលកន្លងយូរមក ប្រជុំជនមានសទ្ធាជ្រះថ្លាកាន់តែច្រើនឡើងតាមលំដាប់ មកសូមបព្វជ្ជាឧបសម្បទ, ព្រះអង្គទើបទ្រង់ប្រទានញត្តិចតុត្ថកម្មវាចាឧបសម្បទា គឺការឧបសម្បទ

ដោយអាការប្រកាសឲ្យសង្ឃដឹងថា "សង្ឃឲ្យឧបសម្បទដល់កុលបុត្រឈ្មោះនោះហើយ" ប្រកាសឲ្យសង្ឃដឹងថា "សង្ឃបានឲ្យឧបសម្បទដល់កុលបុត្រឈ្មោះនោះ ៣ ដងទៀត" កុលបុត្រនោះក៏សម្រេចជាភិក្ខុបាន ។ មួយទៀត ការឧបសម្បទ ដោយញត្តិចតុត្ថកម្មវាចានោះត្រូវសមប្រកបដោយឧបសម្បទ ៥ គឺវត្ថុសម្បទា (បរិបូណ៌ដោយវត្ថុ) ១, បរិសសម្បទា (បរិបូណ៌ដោយបរិស័ទ) ១, សីមាសម្បទា (បរិបូណ៌ដោយសីមា) ១, កម្មវាចាសម្បទា (បរិបូណ៌ដោយកម្មវាចា) ១, បុព្វកិច្ចដ្ឋានំ (ញ៉ាំងកិច្ចខាងដើមឲ្យសម្រេច) ១, ហើយព្រះអង្គទ្រង់បញ្ញត្តកែងតាំងព្រះធម៌វិន័យ ដើម្បីឲ្យពួកពុទ្ធបរិស័ទប្រព្រឹត្តតាម ។

២៦០-ស. ព្រះអង្គប្រាថ្នាយ៉ាងណាបានជាទ្រង់ឲ្យលើកលែងតិសរណាគមនូបសម្បទាចេញ ហើយទ្រង់អនុញ្ញាតឲ្យឧបសម្បទដោយញត្តិចតុត្ថកម្មវាចាវិញ ដែលត្រូវបន្ថែមសេចក្ដីលំបាកនិងខាតវេលាជាច្រើនមកទៀត ?

ឆ. ព្រះអង្គប្រាថ្នានឹងឲ្យឧបសម្បទនោះសម្រេចដោយសង្ឃសាមគ្គី គឺប្រឹក្សាយល់ព្រមព្រៀងគ្នា ទើបទ្រង់ឲ្យលើកលែងតិសរណាគមនូបសម្បទា ដែលជាការសម្រេចដោយបុគ្គលចេញ ។

២៦១-ស: បើសង្កេតមើលក្នុងពុទ្ធប្រវត្តិ ក្នុងច្បាប់ដទៃក្តី នឹងឃើញបានឬទេ ថាព្រះសាស្តាគង់នៅក្នុងនគរណាច្រើនជាងគេ? នឹងរកអ្វីជាបន្ទាល់?

ប. ព្រះអង្គគង់ក្នុងក្រុងសាវត្ថី ច្រើនជាងនគរដទៃ ។ រកឃើញមានវចនៈខាងដើមនៃព្រះសូត្រដោយច្រើនថា ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ដូច្នេះជាបន្ទាល់ ។

២៦២-ស. ព្រះឱវាទទាំងអស់ដែលព្រះសាស្តាបានប្រទានហើយក្នុងរវាង ៤៥ ឆ្នាំនោះ បើរួមចូលឲ្យនៅតែមួយយ៉ាងតើបានដល់អ្វី? ហេតុដូចម្តេច បានជាឆ្លើយយ៉ាងនោះ?

ប. មានឧទាហរណ៍ដែលគប្បីឆ្លើយក្នុងប្រស្នានេះថា ដូចកាលព្រះអង្គទ្រង់សំដែងអរិយសច្ច ៤ គឺទ្រង់សំដែងថា សេចក្តីកើតនឹងសេចក្តីរលត់រមែងប្រព្រឹត្តទៅតាមហេតុ, សេចក្តីកើតនឹងមានក៏ព្រោះហេតុកើត សេចក្តីរលត់នឹងមានក៏ព្រោះហេតុរលត់ ។ សេចក្តីកើតស្លាប់នឹងសុខទុក្ខ សុទ្ធតែនៅក្នុងអំណាចនៃហេតុ ហើយទ្រង់សំដែងមគ្គជាផ្លូវកណ្តាល មិនឲ្យធ្លាក់ទៅខាងផ្លូវធូរថយនឹងថោកទាប មិនឲ្យតឹងរឹងហួសទាល់តែលំបាកឥតប្រយោជន៍ ដើម្បីឲ្យពុទ្ធបរិស័ទ ប្រកាន់យកជាបដិបត្តិនៃខ្លួន ឬមួយដូចកាលដែលទ្រង់សំដែងថា ឥដ្ឋ-

ផល មិនមែនជារបស់ដែលបុគ្គលនឹងគប្បីបានដោយសេចក្តីប្រាថ្នានឹងអង្វរទេ រមែងបានដោយបដិបត្តិ ដែលជាហេតុនៃផលនោះ ៗ ឯង ហើយទ្រង់ដឹកនាំបរិស័ទឲ្យតាំងនៅក្នុងសេចក្តីមិនប្រមាទ ។

២៦៣-ស. មាឃបូជានឹងវិសាខបូជា ដែលពួកពុទ្ធបរិស័ទ ចាត់ធ្វើជាបុណ្យប្រចាំឆ្នាំ ក្នុងថ្ងៃពេញបូណ៌មីខែមាឃនឹងថ្ងៃពេញបូណ៌មីខែវិសាខ ជារាល់ឆ្នាំ តើព្រោះប្រារព្ធហេតុអ្វី?

ប. មាឃបូជាដែលធ្វើក្នុងថ្ងៃពេញបូណ៌មីខែមាឃ ព្រោះប្រារព្ធហេតុនៃថ្ងៃនោះ ត្រូវនឹងថ្ងៃចតុរង្គសន្និបាត ដែលព្រះសាស្តាទ្រង់សំដែងឱវាទបាតិមោក្ខដល់ព្រះអរហន្ត ១.២៥០ អង្គ ទាំងទ្រង់ដាក់ព្រះជន្មាយុសង្ខារ ។ វិសាខបូជាដែលធ្វើក្នុងថ្ងៃពេញបូណ៌មីខែវិសាខ-នោះព្រោះប្រារព្ធហេតុនៃថ្ងៃនោះ ត្រូវនឹងថ្ងៃព្រះសាស្តាប្រសូត, ត្រាស់-ដឹងនិងបរិនិព្វាន ។

ចតុរង្គសន្និបាត

២៦៤-ស. ការសន្និបាតដូចម្តេចដែលហៅថា ចតុរង្គសន្និបាត?

ប. ដែលហៅថា ចតុរង្គសន្និបាត ព្រោះថាការប្រជុំនោះប្រកបដោយអង្គ ៤ មានបាលីក្នុងគម្ពីរ បបញ្ចសូទនី អដ្ឋកថានៃមជ្ឈិម-និកាយប្រាប់ថា:

១) មាឃនក្ខត្តេន យុត្តោ បុណ្ណមីឧបោសថទិវសោ ៖ ថ្ងៃឧបោសថព្រះចន្ទពេញវង់ (១៥ កើត) ប្រកបដោយផ្កាយនក្ខត្តឫក្ស ប្រចាំខែមាឃ ។

២) កេនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ភិក្ខុសតានិ ភិក្ខុ ១.២៥០ អង្គ ឥតអ្នកណានិមន្ត មកប្រជុំគ្នាខ្លួនឯងតែម្ដង តាមធម្មតារបស់ខ្លួន ។

៣) តេសុ ឯកោ បុថុជ្ជនោ វា សោតាបន្នសកទាគាមិអនាគាមិសុក្ខវិបស្សកអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆឡភិញ្ញា វ ភិក្ខុទាំងនោះ ជាបុថុជ្ជន ឬជាសោតាបន្ន ឬសកទាគាមី ឬអនាគាមី ឬព្រះអរហន្តសុក្ខវិបស្សកៈ សូម្បី ១រូបមិនមានឡើយ មានសុទ្ធតែជាព្រះអរហន្តបានអភិញ្ញា ៦ គ្រប់រូប ។

៤) ឯកោបិ បេត្ត សត្តកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុយេវ សូម្បីតែភិក្ខុ ១ រូបដែលកោរសក់ដោយកាំបិតកោរហើយបួសក៏គ្មាន សុទ្ធតែជាឯហិភិក្ខុទាំងអស់ ។

២៦៥-ស. ចតុរង្គសន្និបាតនេះ ព្រះសាស្ដាទ្រង់ធ្វើក្នុងទីណា? មានហេតុដូចម្ដេចបានជាទ្រង់ធ្វើ ?

ប. ទ្រង់ធ្វើក្នុងវត្តវេឡុវ័ន ។ មានហេតុដើម្បីទ្រង់សំដែងឱវាទបាតិមោក្ខ ។

២៦៦-ស. បាតិមោក្ខមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ប. មាន២យ៉ាងគឺ:

១)ឱវាទបាតិមោក្ខ ទ្រង់សំដែងជាពាក្យខ្លួន ៣ យ៉ាងថា សព្វបាបស្ស អករណំ=កុំធ្វើបាបទាំងពួងដោយកាយវាចាចិត្ត១, កុសលស្សូបសម្បទា= ញុំាងកុសលឲ្យដល់ព្រមដោយកាយវាចាចិត្ត ១, សចិត្តបរិយោទបនំ= ជំរះចិត្តរបស់ខ្លួនឲ្យបរិសុទ្ធផូរផង់ចាកគ្រឿងសៅហ្មងមាន លោភៈ ទោសៈ មោហៈ ជាដើម ១ ។

២) អាណាបាតិមោក្ខ ទ្រង់បញ្ញត្តជាដាច់ខាត ដូចក្នុងសិក្ខាបទ ២២៧ ដែលទ្រង់បង្គាប់ឲ្យភិក្ខុសំដែងរាល់កន្លះខែ មានបាលីថា សុណាតុ មេ ភន្តេ សង្ឃោ ជាដើម ។

២៦៧-ស. ចុះព្រះពុទ្ធគ្រប់អង្គ វេលាធ្វើឧបោសថជាមួយនឹងភិក្ខុសង្ឃ ទ្រង់សំដែងបាតិមោក្ខអ្វី ? មានកំណត់វេលាដូចគ្នាគ្រប់អង្គឬផ្សេងគ្នា ?

ប. ទ្រង់សំដែងតែឱវាទបាតិមោក្ខ ដោយព្រះអង្គឯង ? មិនសំដែងអាណាបាតិមោក្ខទេ ។ មិនកំណត់វេលាដូចគ្នាទេ គឺព្រះពុទ្ធ

វិបស្សី ៧ ឆ្នាំសំដែងម្តង, ព្រះពុទ្ធជាម្ចាស់របស់យើងកន្លះខែសំដែងម្តង, ព្រះពុទ្ធមានព្រះជន្មវែង ទ្រង់សំដែងដរាបដល់ផុតសាសនា, បើព្រះជន្មខ្លី ទ្រង់សំដែងតែក្នុងបឋមពោធិកាល ៗ

២៦៨-សួ. ព្រះសាស្តានៃយើងទ្រង់សំដែងឱវាទបាដិមោក្ខបាន ចំនួនប៉ុន្មានវស្សា ? វេលាទ្រង់ឈប់សំដែង ទ្រង់គង់ក្នុងទីណា ? បានត្រាស់ប្រាប់ភិក្ខុសង្ឃថាដូចម្តេចខ្លះ ?

ឆ. បានចំនួន២០វស្សា ក្នុងបឋមពោធិកាល ៗ វេលាទ្រង់ឈប់សំដែង ទ្រង់គង់ក្នុងបុព្វារាម លើប្រាសាទនាងវិសាខា បានត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ តពីនេះទៅមុខទៀត តថាគតឈប់ធ្វើឧបោសថសំដែងឱវាទបាដិមោក្ខហើយ, អ្នកទាំងឡាយគប្បីធ្វើឧបោសថសំដែងអាណាបាដិមោក្ខចុះ ព្រោះតថាគតធ្វើឧបោសថសំដែងបាដិមោក្ខជាមួយនឹងបរិស័ទដែលមិនបរិសុទ្ធនោះ មិនបានជាការទេ ៗ តាំងពីកាលនោះមក ភិក្ខុទាំងឡាយក៏សំដែងតែអាណាបាដិមោក្ខ ដរាបដល់សព្វថ្ងៃនេះ ៗ

២៦៩-សួ. ព្រះបាទពិម្ពិសារ បានក្រាបទូលប្រកាសសេចក្តីប្រាថ្នាប៉ុន្មានប្រការ ដែលព្រះអង្គតាំងទុកតាំងពីនៅជាព្រះរាជកុមារ ចំពោះព្រះសាស្តា ? ព្រះប្រណិធានទាំងនោះបានសម្រេចឬទេ ?

ឆ. មាន ៥ ប្រការគឺ:

១) សូមឲ្យជនទាំងឡាយដែលចាត់ចែងរាជសម្បត្តិ គប្បីអភិសេកយើងក្នុងរាជសម្បត្តិ ជាព្រះរាជានៃមគធរដ្ឋ ៗ

២) សូមឲ្យអង្គព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ស្តេចមកប្រតិស្ឋានព្រះសាសនា ក្នុងដែននៃយើងដែលបានអភិសេកហើយ ៗ

៣) សូមឲ្យបានខ្លួនយើងបានចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគជាម្ចាស់នោះ ៗ

៤) សូមឲ្យព្រះដ៏មានព្រះភាគជាម្ចាស់នោះ ទ្រង់សំដែងធម៌ដល់យើង ៗ

៥) សូមឲ្យយើងបានត្រាស់ដឹងនូវធម៌របស់ព្រះដ៏មានព្រះភាគជាម្ចាស់នោះ ៗ សេចក្តីប្រាថ្នាទាំង ៥ នេះ បានសម្រេចដល់ព្រះបាទពិម្ពិសារគ្រប់ប្រការ ៗ

២៧០-សួ. ព្រះសាស្តាទ្រង់បំពេញសត្ថុកាវកិច្ច គឺទ្រង់ប្រោសប្រជាជនដោយប្រយោជន៍ប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ឆ. ដោយប្រយោជន៍ ៣ យ៉ាងគឺ:

១) ទិដ្ឋធម្មិកត្ថ = ប្រយោជន៍ដែលនឹងគប្បីបានក្នុងបច្ចុប្បន្ន ៗ

២) សម្បរាយិកត្ថ = ប្រយោជន៍ដែលនឹងគប្បីបានក្នុងអនាគត ៗ

៣) បរមត្ថ= ប្រយោជន៍យ៉ាងក្រៃលែងគឺព្រះនិព្វាន ។

២៧១-ស. ធម៌អ្វីហៅថា សាមុក្កំសិកធម៌ ? ធម៌នេះព្រះសាស្តាសំដែងចំពោះតែមនុស្សប្រកបដោយអង្គប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ប. អរិយសច្ចទាំង ៤ ប្រការ ហៅថា សាមុក្កំសិកធម៌ ។ ធម៌នេះព្រះសាស្តាទ្រង់សំដែងចំពោះតែគ្រហស្ថប្រកបដោយអង្គ ៣ គឺ:

១) ជាមនុស្ស= មិនមែនអមនុស្សដូចទេវតាយក្សប្រេតជាដើម ។

២) ជាគ្រហស្ថ= មិនមែនជាអ្នកបួស ។

៣) មានឧបនិស្ស័យចាស់ក្លា= គួរសម្រេចលោកុត្តរធម៌ក្នុងទីនោះ ។ បើមិនព្រមដោយអង្គ ៣ នេះទេ ព្រះអង្គទ្រង់ប្រដៅដោយសុតគោវាទនៃតាមការណ៍គួរ ។

២៧២-ស. ព្រះសាស្តាកាលទ្រង់ប្រដៅប្រជាជន តើទ្រង់ប្រដៅដោយអាការៈប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?

ប. ដោយអាការៈ ៤ យ៉ាងគឺ:

១) សន្ទស្សនា= ទ្រង់សំដែងកម្មដែលមានទោសគួរលះវៀរនឹងកម្មមិនមានទោសគួរប្រកប ឲ្យអ្នកស្តាប់ឃើញដោយល្អ ដូចនៅក្នុងទីចំពោះមុខ ។

២) សមាទបនា= ដឹកនាំឲ្យអ្នកស្តាប់ជឿកាន់ដោយល្អ ដែលជាកិច្ចគួរលះបង់នឹងគួរប្រព្រឹត្តជាដើម ។

៣) សមុត្តេជនា= ឲ្យអ្នកស្តាប់ក្លាហានឡើងដោយល្អ ក្នុងកាលដែលនឹងលះបង់ឬនឹងចំរើនជាដើម ។

៤) សម្បហំសនា= ពណ៌នាគុណនៃសេចក្តីលះបង់ នឹងសេចក្តីចំរើននោះ ៗ ឲ្យអ្នកស្តាប់រីករាយសប្បាយចិត្ត ។

២៧៣-ស. ព្រះសាស្តាទ្រង់សំដែងធម៌ប្រដៅប្រជាជន ដើម្បីប្រយោជន៍ប៉ុន្មានប្រការ គឺអ្វីខ្លះ ?

ប. ដើម្បីប្រយោជន៍ ១០ ប្រការគឺ:

១) វិសំយោគាយ= ដើម្បីនឹងឲ្យអស់សំយោគកិលេស ជាគ្រឿងប្រកបសត្វ ៈមិនបានសំដែងដើម្បីនឹងឲ្យព័ន្ធព័ទ្ធរួបរឹតទុកដោយកិលេសជាគ្រឿងប្រកប ។

២) អនុបាទានាយ= ដើម្បីនឹងឲ្យឃ្លាតចេញនូវឧបាទានទាំង ៤ គឺ កាមុបាទាន, ទិដ្ឋុបាទាន, សីលព្វតុបាទាន, អត្តវាទុបាទាន ។

៣) មទនិម្មទនាយ= ដើម្បីឲ្យបាត់សេចក្តីស្រវឹង ។

៤) បិបាសវិនយាយ= ដើម្បីនឹងឲ្យនាំបង់នូវតណ្ហា ដូចជាការស្រេកទឹក ។

៥) អាលយសមុគ្ឃាតាយ= ដើម្បីនឹងឲ្យដកចោលនូវអាល័យជន្មស្នេហាសេចក្តីស្រឡាញ់ ។

៦) វដ្ដុបច្ឆេទាយ= ដើម្បីនឹងឲ្យចូលទៅកាត់ចោលនូវវដ្ដៈ ។

៧) តណ្ហាក្ខយាយ= ដើម្បីនឹងឲ្យអស់ទៅនៃតណ្ហា ជាគ្រឿងក្តៅក្រហាយ ។

៨) វិរាគាយ= ដើម្បីនឹងឲ្យវិនាសប្រាសចាកកិលេសដ៏ជ្រលក់ចិត្ត ។

៩) និរោធាយ= ដើម្បីនឹងឲ្យរលត់ស្និទ្ធរលត់មិនសល់នៃកិលេសនឹងកងទុក្ខ ។

១០) និព្វានាយ= ដើម្បីព្រះនិព្វាន សេចក្តីរលត់មិនសល់នៃភ្លើងកិលេសមានរាគៈ ជាដើមឲ្យសូន្យអស់ជានិរវសេស ។

សម្តេចព្រះដ៏មានព្រះភាគរមែងទ្រង់សំដែងធម៌ប្រដៅវេនេយ្យសត្វទេវតាមនុស្សដោយអាការវិធីដើម្បីប្រយោជន៍គុណ គឺ វិមុត្តិ អនុត្តរផល ឲ្យសត្វផុតចាកសង្សារទុក្ខទាំងពួងដោយប្រការដូច្នេះ ។

២៧៤-ស. ពុទ្ធបរិស័ទចំណែកភិក្ខុ នឹង ភិក្ខុនី ដែលចូលមកឧបសម្បទក្នុងព្រះធម្មវិន័យដោយវិធីផ្សេងៗ គ្នា ប៉ុន្តែបើរួមជាប្រភេទមានប៉ុន្មានយ៉ាង គឺអ្វីខ្លះ? ឧបសម្បទាណាសម្រេចដោយអ្វី ?

ឆ. មាន ៤ យ៉ាងគឺ:

១) ឯហិភិក្ខុឧបសម្បទា= ឧបសម្បទដោយឯហិភិក្ខុ ។

២) តិសរណគមនូបសម្បទា= ឧបសម្បទដោយការដល់សរណគមន៍ ៣ ។

៣) ញត្តិចតុត្ថកម្មឧបសម្បទា= ឧបសម្បទដោយញត្តិចតុត្ថកម្មវាចា ។

៤) អដ្ឋវាចិកូបសម្បទា= ឧបសម្បទដោយញត្តិចតុត្ថកម្មវាចាក្នុងសង្ឃទាំង ២ ពួក រួមជា ៨ កម្មវាចានេះចំពោះតែនាងភិក្ខុនី ។ ឧបសម្បទា ២ ខាងដើម សម្រេចដោយបុគ្គល ។ ឧបសម្បទា២ខាងចុង សម្រេចដោយសង្ឃ ។

២៧៥-ស. ភិក្ខុសាមណេរក្នុងសម័យបច្ចុប្បន្ននេះ ទទួលឧបសម្បទនឹងបព្វជ្ជាដោយវិធីដូចម្តេច?

ឆ. កាលជាខាងក្រោយមកទ្រង់អនុញ្ញាតឲ្យបំបួសភិក្ខុដោយញត្តិ

ពក្កខុបសម្បទា ហើយទ្រង់បញ្ឈប់ឧបសម្បទា ២ ខាងដើមចេញ ប៉ុន្តែទ្រង់ផ្លាស់តិសរណគមនូបសម្បទាឲ្យជាវិធីបព្វជ្ជារបស់សាមណេរវិញ ។

២៧៧-ស. បណ្ដាបុរសនិងស្ត្រីអ្នកឧបសម្បទនិងបព្វជ្ជាក្នុងធម៌វិន័យ ហៅថាអ្វី ? ប្រែថាម៉េច ? មានប៉ុន្មានពួក ? គឺអ្វីខ្លះ ?

ច. ហៅថា សហធម្មិកៈ ប្រែថា "អ្នកប្រព្រឹត្តធម៌រួមគ្នា" មាន ៥ ពួកគឺ ភិក្ខុ១ ភិក្ខុនី១ សិក្ខមានា១ សាមណេរ១ សាមណេរី១ ។

២៧៨-ស. ច្បាប់ទម្លាប់ដែលព្រះសាស្ដាទ្រង់បញ្ញត្តសម្រាប់ពួកភិក្ខុហៅថាអ្វី? ទ្រង់ឃើញអំណាចប្រយោជន៍ប៉ុន្មានប្រការ បានជាទ្រង់បញ្ញត្ត ?

ច. ហៅថា វិន័យ ។ ទ្រង់ឃើញអំណាចប្រយោជន៍ ១០ ប្រការគឺ:

១) សង្ឃសុដ្ឋុតាយ= ដើម្បីកិរិយាទទួលថាល្អហើយនៃសង្ឃ

២) សង្ឃផាសុតាយ=ដើម្បីការនៅសប្បាយនៃសង្ឃ ។

៣) ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ = ដើម្បីនឹងសង្កត់សង្កិននូវបុគ្គលអ្នកមិនមានសីល ។

៤) បេសលានំ ភិក្ខូនំ ផាសុវិហារាយ= ដើម្បីការនៅសប្បាយនៃភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ។

៥) ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ= ដើម្បីនឹងបិទនូវអាសវៈទាំងឡាយដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាលឃើញប្រាកដ ។

៦) សម្បរាយិកានំ អាសវានំ បដិឃាតាយ= ដើម្បីនឹងកំចាត់បង់នូវអាសវៈទាំងឡាយដែលនឹងកើតមានក្នុងកាលខាងមុខ ។

៧) អប្បសន្នានំ វា បសាទាយ= ដើម្បីសេចក្ដីជ្រះថ្លានៃជនទាំងឡាយដែលមិនជ្រះថ្លា គឺដើម្បីញុំាងជនទាំងឡាយអ្នកមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ។

៨) បសន្នានំ វា ភិយ្យោភាវាយ= ដើម្បីសេចក្ដីកើតក្រៃលែងនៃជនទាំងឡាយអ្នកជ្រះថ្លាហើយ គឺឲ្យជនអ្នកជ្រះថ្លារួចហើយរឹងរឹតតែជ្រះថ្លាខ្លាំងៗឡើង ។

៩) សទ្ធម្មដ្ឋិតិយា= ដើម្បីការតាំងនៅនៃព្រះសទ្ធម្ម ។

១០) វិនយានុគ្គហាយ– ដើម្បីនឹងអនុគ្រោះនូវវិន័យ ។

២៧៩-ស. ព្រះពុទ្ធោវាទដែលទ្រង់ទេសនាប្រដៅពុទ្ធបរិស័ទក្នុងរវាង ៤៥ ឆ្នាំ បើរួមឲ្យខ្លីមកមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ហៅថាអ្វី?

ច. មាន២យ៉ាងគឺ ព្រះធម៌១, វិន័យ១ ។ ហៅថាបាវចនៈ គឺពាក្យដែលជាប្រធាន ។

២៨០- ស. ចុះព្រះធម៌នឹងព្រះវិន័យទាំង ២ នោះ លោកសំដៅយកអ្វីជាផលទីបំផុតតែម្យ៉ាង ?

ច. លោកសំដៅយកវិមុត្តិរសតែម្យ៉ាង ជាផលទីបំផុតរបស់ព្រះធម៌នឹងព្រះវិន័យ ប្រៀបដូចមហាសមុទ្របើទុកជាធំជ្រៅប៉ុណ្ណាក៏ទឹកមានរសប្រៃដូចគ្នាតែមួយ នេះជាសេចក្ដីអស្ចារ្យនៃមហាសមុទ្រដូចម្ដេចមិញ សូម្បីតែព្រះធម៌វិន័យដែលជានយសាគរនេះដ៏វិចិត្រដោយធម្មប្បភេទនឹងបញ្ញត្តិវិសេសយ៉ាងណា ក៏មានវិមុត្តិសេចក្ដីផុតវិសេសចាកសព្វកិលេសបាបធម៌ជារស ជាផលទីបំផុតដូច្នោះដែរ ។

២៨១- ស. ព្រះធម៌វិន័យ ពាក្យប្រដៅរបស់សម្ដេចព្រះបរមសាស្ដានោះ ចែកដោយអង្គមានប៉ុន្មានយ៉ាងគឺអ្វីខ្លះ ? ហៅថាអ្វី ?

ច. មានអង្គ ៩ យ៉ាង ហៅថានវង្គសត្ថុសាសនៈ គឺ:

១) សុត្តៈ បានដល់ពាក្យសំដែងសេចក្ដីមានរឿងប្រកបផង ។

២) គេយ្យៈ បានដល់របៀបពាក្យដែលជាចុណ្ណិយបទ នឹងគាថា ។

៣) វេយ្យាករណៈ បានដល់របៀបពាក្យចុណ្ណិយបទសុទ្ធ ។

៤) គាថា បានដល់របៀបពាក្យជាគាថាសុទ្ធ ។

៥) ឧទាន: បានដល់របៀបពាក្យដែលព្រះដ៏មានព្រះភាគទ្រង់បន្លឺឡើងអាស្រ័យដោយព្រះសោមនស្សញ្ញាណ ។

៦) ឥតិវុត្តកៈ បានដល់របៀបពាក្យដែលមានឧទ្ទេស,និទ្ទេសនឹងនិគម ។

៧) ជាតក បានដល់របៀបពាក្យដែលសំដែងបុព្វចរិត ។

៨) អព្ភូតធម្មៈ បានដល់របៀបពាក្យសំដែងអច្ឆរិយធម៌ ។

៩) វេទល្លៈ បានដល់របៀបពាក្យដែលអ្នកសួរបានសេចក្ដីដឹងជាក់ច្បាស់ នឹងសេចក្ដីត្រេកអរហើយសួរត ៗ ជាលំដាប់ទៅ ។

២៨២- ស. ហេតុប៉ុន្មានប្រការដែលធ្វើឲ្យផែនដីកម្រើកញាប់ញ័របាន ?

ច. ព្រះសាស្ដាទ្រង់ត្រាស់ប្រាប់អានន្ទថា ហេតុដែលធ្វើឲ្យផែនដីញាប់ញ័រមាន ៨ ប្រការគឺ :

១) ខ្យល់កំរើក

២) អ្នកមានឫទ្ធិបណ្ដាល

៣) ព្រះពោធិសត្វចុះចាកតុសិតសួគ៌មកកាន់ព្រះគភ៌

៤) ព្រះពោធិសត្វប្រសូត

៥) ព្រះតថាគតត្រាស់ដឹង

៦) ព្រះតថាគតទ្រង់ដាក់ព្រះជន្មាយុសង្ខារ

៧) ព្រះតថាគតទ្រង់សំដែងបឋមទេសនា

៨) ព្រះតថាគតនិព្វាន ។

២៨៣-ស. កាលព្រះសាស្តាគង់ក្នុងកណ្ឌគ្រាមបានប្រទានឱវាទដល់ភិក្ខុសង្ឃសំដែងអំពីអរិយធម៌ប៉ុន្មានប្រការ គឺអ្វីខ្លះ? មានសេចក្ដីអធិប្បាយដូចម្ដេច?

ច. ទ្រង់សំដែងអំពីអរិយធម៌ ៤ ប្រការថា ព្រោះហេតុដែលមិនបានចាក់ធ្លុះចំពោះអរិយធម៌ ៤ ប្រការ គឺសីល ១ សមាធិ ១ បញ្ញា ១ វិមុត្តិ ១; ទើបជាហេតុឲ្យសព្វសត្វត្រាច់រង្គាត់នៅក្នុងវដ្ដសង្សារ ហេតុនោះសូមភិក្ខុសង្ឃបំពេញអរិយធម៌ឲ្យបរិបូណ៌ ដើម្បីជាប្រយោជន៍ដល់ខ្លួននិងប្រជាជនតទៅទៀត ហើយទ្រង់ប្រទានឱវាទដទៃទៀតរួមចូលក្នុងសីល សមាធិ បញ្ញា ព្រោះសិក្ខាទាំង ៣ នេះជាផ្លូវនៃវិមុត្តិដែលជាខ្លឹមសាររបស់ព្រះធម៌វិន័យ ។

២៨៤-ស. កាលព្រះសាស្តាគង់ក្នុងភោគនគរក្បែរអានន្ទចេតិយ ទ្រង់សំដែងមហាបទេស ៤ ផ្នែកខាងព្រះសូត្រ ដល់ភិក្ខុសង្ឃដើម្បីជាគ្រឿងវិនិច្ឆ័យធម៌វិន័យ មានសេចក្ដីថាដូចម្ដេចខ្លះ?

ច. មានសេចក្ដីថា "បើអ្នកណានឹងមកអាងព្រះបរមសាស្តា

សង្ឃ គណៈ ឬ បុគ្គល ហើយសំដែងថានេះជាធម៌ជាវិន័យ ក៏កុំគប្បីជឿជាមុន គប្បីប្រៀបធៀបជាមួយសូត្រនិងវិន័យមុនសិន បើឃើញថាត្រូវគ្នាទើបគួរជឿបាន បើឃើញថាខ្វែកគ្នាខុសគ្នា ក៏មិនគួរជឿ" ។

២៨៥-ស. បុគ្គលដូចម្ដេចឈ្មោះថាថូបារហបុគ្គល? មានប៉ុន្មាន? គឺលោកណាខ្លះ?

ច. អច្ឆរិយបុរសដែលគួរបញ្ចុះក្នុងព្រះស្តូបឈ្មោះថា ថូបារហបុគ្គល មាន ៤ គឺៈ សម្ដេចព្រះសម្មាសម្ពុទ្ធ ១, ព្រះបច្ចេកសម្ពុទ្ធ ១, ព្រះតថាគតសាវ័ក ១, ព្រះបាទចក្រពត្តិរាជ ១ ។

២៨៦-ស. ព្រះពុទ្ធចរិយាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? មានសេចក្ដីអធិប្បាយខ្វែកគ្នាដូចម្ដេច?

ច. មាន ៣ យ៉ាងគឺលោកត្ថចរិយា=ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដល់លោក ១, ញាតត្ថចរិយា= ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដល់ព្រះញាតិបុរដោយឋានៈជាព្រះញាតិ ១, ពុទ្ធត្ថចរិយា= ទ្រង់ប្រព្រឹត្តជាប្រយោជន៍ដោយឋានៈជាព្រះពុទ្ធ ១ ។

មានសេចក្ដីអធិប្បាយខ្វែកគ្នាដូច្នេះ

ក) លោកត្ថចរិយា= បានដល់កិរិយាដែលទ្រង់ប្រព្រឹត្តជាប្រ

យោជន៍ដល់មហាជន ដែលរាប់ថាសត្វលោកទូទៅ ដូចទ្រង់ផ្សាយព្រះញាណទតមើលនិស្ស័យសត្វលោករាល់ថ្ងៃ អ្នកណាមកប្រាកដក្នុងសំណាញ់ញាណរបស់ព្រះអង្គ ៗក៏យាងទៅប្រោសអ្នកនោះៗ មួយទៀតទ្រង់សង្គ្រោះមនុស្សទាំងឡាយដោយឋានៈជាមនុស្សផងគ្នា ក៏រាប់បញ្ចូលក្នុងលោកត្ថចរិយានេះដែរ ។

ខ) ញាតត្ថចរិយា= បានដល់កិរិយាដែលទ្រង់សង្គ្រោះពួកព្រះញាតិដោយឋានៈជាព្រះញាតិ ដូចយ៉ាងទ្រង់អនុញ្ញាតឲ្យពួកសាក្យរាជជាព្រះញាតិដែលចូលជាពួកតិរ្ថិយហើយ និងត្រឡប់ចូលមកឧបសម្បទក្នុងព្រះពុទ្ធសាសនាមិនបាច់នៅតិត្ថិយបរិវាស ៤ ខែមុន ដូចពួកតិរ្ថិយដទៃទេ នេះជាញាតត្ថចរិយាដោយចំពោះ ។ បើនឹងពិនិត្យមើលព្រះពុទ្ធចរិយាដែលប្រព្រឹត្ត ដើម្បីសង្គ្រោះព្រះញាតិនោះឃើញថា ការដែលទ្រង់យាងទៅទេសនាប្រោសព្រះញាតិនៅនគរកបិលពស្តុ ការដែលទ្រង់យាងទៅហាមឃាត់ព្រះញាតិពួកសាក្យៈនឹងកោលិយៈដែលវិវាទគ្នាដោយហេតុដណ្តើមទឹកគ្នាបញ្ចូលស្រែក្តី ក៏ចាត់ចូលក្នុងញាតត្ថចរិយានេះដែរ ។

គ) ពុទ្ធត្ថចរិយា= នោះបានដល់ពុទ្ធកិច្ចដែលទ្រង់បំពេញឲ្យជាប្រយោជន៍ដល់មហាជន ដោយឋានៈជាព្រះពុទ្ធ ដូចទ្រង់បញ្ញត្តសិក្ខា-

បទដ៏ជាអាទិព្រហ្មចរិយៈខ្លះ ដ៏ជាអភិសមាចារៈខ្លះ ដើម្បីសង្កត់សង្កិនពួកភិក្ខុអ្នកឥតអៀនខ្មាសហៅថាទុម្មង្កុអ្នកអៀនខ្មាសដោយក្រ គឺមិនសូវចេះអៀនខ្មាស់ខ្លះ ហៅថា អលជ្ជី អ្នកឥតខ្មាស់ខ្លះ ដើម្បីដាក់របៀបដឹកនាំសេចក្តីប្រព្រឹត្តនៃពួកភិក្ខុអ្នកប្រាថ្នាល្អ ដែលហៅថាបេសលៈខ្លះ អ្នកមានសេចក្តីអៀនខ្មាស ដែលហៅថាលជ្ជីខ្លះ ហើយទ្រង់ប្រកាសសាសនាឲ្យពុទ្ធបរិស័ទ ទាំងគ្រហស្ថទាំងបព្វជិតបានដឹងជ្រួតជ្រាបព្រះសទ្ធម្មទូទៅ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាឲ្យស្ថិតស្ថេរចិរកាលផ្សាយមកដល់សព្វថ្ងៃនេះ បើពោលដោយខ្លីរាប់បញ្ចូលក្នុងពុទ្ធត្ថចរិយាទាំងអស់ ។

២៨៧- ស. ព្រះគុណនៃព្រះសាស្តាមានច្រើនប្រការណាស់ ប៉ុន្តែលោកបំប្រួញចូលក្នុងសម្បទាប៉ុន្មានយ៉ាងគឺអ្វីខ្លះ? សម្បទាណាចែកចេញជាប៉ុន្មានយ៉ាងទៅទៀត ?

ឆ. លោកបំប្រួញចូលក្នុងសម្បទា ៣ គឺ:

១) ហេតុសម្បទា= បានដល់ព្រះមហាករុណាសមាយោគៈ គឺការដែលព្រះអង្គទ្រង់ប្រកបដោយព្រះករុណាធំក្នុងសត្វទាំងអស់ និងពោធិសម្ភារៈ បានដល់ការដែលទ្រង់ឧស្សាហ៍កសាងព្រះបារមីពុទ្ធការកធម៌មិនរួញរាព្រះទ័យ ដែលជាហេតុបញ្ចូនឲ្យដល់ផល ។

២) ផលសម្បទា= បានដល់ការដល់ព្រមដោយគុណសម្បត្តិ

ន៍ជាផល ដែលជាប់មកអំពីហេតុសម្បទា ចែកចេញដោយប្រភេទជា ៤ ប្រការគឺៈ

ក) ញាណសម្បទា = បានដល់ការដល់ព្រមដោយព្រះបញ្ញាញាណដ៏ភ្លឺច្បាស់ក្នុងមគ្គផល ។

ខ) បហានសម្បទា = បានដល់ការដល់ព្រមដោយកិរិយាលះកិលេសព្រមទាំងវាសនាបានដាច់ស្រឡះ ។

គ) អានុភាវសម្បទា = បានដល់ការដល់ព្រមដោយអានុភាព គឺទ្រង់សំដែងឫទ្ធិផ្សេងៗបាន ។

ឃ) រូបកាយសម្បទា = បានដល់ការដល់ព្រមដោយទ្វត្តឹស មហាបុរិសលក្ខណៈ និងអសីត្យានុព្យញ្ជនៈ ជានយនាភិសេករបស់សកលលោក ។

៣) សត្តូបការសម្បទា = បានដល់ការដែលទ្រង់នូវឧបការៈដល់សត្វមិនមានប្រមាណ ចែកបានជា ២ ប្រការគឺៈ

ក) អាសយសម្បទា = បានដល់ការដែលព្រះអង្គមានព្រះហឫទ័យត្រជាក់ត្រជុំដោយព្រះករុណាជានិច្ច សូម្បីក្នុងសត្វដែលធ្វើខុស មានទេវទត្តជាដើម ។

ខ) បយោគសម្បទា = បានដល់ការដែលព្រះអង្គទ្រង់សំដែងធម៌ដោយមិនឃើញដល់អាមិសឡើយ ទ្រង់ប្រាថ្នាតែប្រយោជន៍ដល់អ្នកស្តាប់ពិតៗ ។

ព្រះគុណនៃសម្តេចព្រះមានព្រះភាគ រាប់តាំងអំពីប្រសូតរហូតដល់បរិនិព្វាន បំប្រួញចូលក្នុងសម្បទាទាំង ៣ ដោយប្រការដូច្នេះ ។

២៨៨-ស. ធម្មសមោធាន គឺធម៌ដែលឲ្យសម្រេចព្រះពុទ្ធភូមិ មានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

ច មាន ៨ យ៉ាងគឺៈ

១) មនុស្សសម្បត្តិ = ជាមនុស្ស កាលចាប់ផ្តើមតាំងសេចក្តីប្រាថ្នាពោធិញ្ញាណ ។

២) លិង្គសម្បត្តិ = ដល់ព្រមដោយភេទ គឺបុរស, ស្ត្រីប្រាថ្នាមិនបាន; បើជាស្ត្រី ត្រូវប្រាថ្នាឲ្យកើតជាបុរសមុនសិន ។

៣) ហេតុសម្បត្តិ = ដល់ព្រមដោយឧបនិស្ស័យជាហេតុកសាងកុសលច្រើន (រាប់បាន ១ សែនមហាកប្ប ហើយតាំងនៅក្នុងភូមិសាវកបារមីអាចសម្រេចព្រះអរហត្តក្នុងជាតិនោះ) ។

៤) សត្ថុទស្សនសម្បត្តិ = បានជួបឃើញព្រះពុទ្ធជាម្ចាស់ (គឺតាំងសេចក្តីប្រាថ្នាចំពោះព្រះភក្ត្រព្រះពុទ្ធ ហើយបានទទួលពុទ្ធព្យាករណ៍)

៥) បព្វជ្ជាសម្បត្តិ= បានបព្វជ្ជា (ទ្រង់ភេទបព្វជិតជាភិក្ខុ សាមណេរឬឫសី, មុនី ឬតាបសអ្នកជាកម្មវាទី) ។

៦) គុណសម្បត្តិ= ប្រកបដោយគុណវិសេស មានឈានសមាបត្តិជាដើម ។

៧) អធិការសម្បត្តិ= បំពេញបុញ្ញាភិសម្ភារយ៉ាងលើសលប់ ដូចមហាបរិច្ចាគ ៥ ។

៨) ឆន្ទតាសម្បត្តិ= មានឆន្ទៈដ៏ខ្លាំងក្លាក្នុងពោធិញ្ញាណ ។ ធម៌ទាំង ៨ ប្រការនេះ ជាអភិនីហារឲ្យសម្រេចសព្វញ្ញុតញ្ញាណរបស់ព្រះពោធិសត្វ ៕

២៨៩- ស. ចូរប្រាប់ថ្ងៃខែឆ្នាំនឹងពេលព្រះជន្មក្នុងគោលធំ ៧ មាន កាលព្រះសាស្តាចុះចាប់បដិសន្ធិជាដើមឲ្យសព្វគ្រប់មកមើល !

ច. ព្រះសាស្តាចុះចាប់បដិសន្ធិក្នុងថ្ងៃ ៥ ១៥ ៨ ឆ្នាំរកា វេលារាត្រីជិតភ្លឺ មុន ព. ស. ៨១ ឆ្នាំ (ចូរមើលប្រស្នាលេខ ៤០) ។

កាលប្រសូតក្នុងថ្ងៃ ៦ ១៥ ៦ ឆ្នាំច វេលាថ្ងៃជិតត្រង់ មុន ព. ស. ៨០ ឆ្នាំ (ចូរមើលប្រស្នាលេខ ៤៦) ។

កាលសោយរាជសម្បត្តិក្នុងថ្ងៃ ៧ ១៥ ៨ ឆ្នាំឆ្លូវ មុន ព. ស ៦៤ ឆ្នាំ ព្រះជន្មាយុបាន ១៦ ឆ្នាំ (ចូរមើលប្រស្នាលេខ ៧៩) ។

កាលចេញបព្វជ្ជាក្នុងថ្ងៃ ៥ ១៥ ៨ ឆ្នាំថោះ វេលាអធ្រាត្រ មុន ព. ស. ៥១ ឆ្នាំ ព្រះជន្មាយុបាន ២៩ ឆ្នាំ ។ (ចូរមើលប្រស្នាលេខ ៨៥) ។

កាលត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងថ្ងៃ ៤ ១៥ ៦ ឆ្នាំរកា វេលាបែកបច្ចូស មុន ព.ស ៤៥ ឆ្នាំ ព្រះជន្មាយុបាន ៣៥ ឆ្នាំ ។

កាលសំដែងបឋមទេសនាក្នុងថ្ងៃ ១ ១៥ ៨ ឆ្នាំរកា មុន ព. ស. ៤៥ ឆ្នាំ ។

កាលដាក់ព្រះជន្មាយុសង្ខារក្នុងថ្ងៃ ១ ១៥ ៣ ឆ្នាំរោង មុន ព. ស. ២ ឆ្នាំ ។

កាលបរិនិព្វានក្នុងថ្ងៃ ៣ ១៥ ៦ ឆ្នាំម្សាញ់ វេលាបែកបច្ចូស មុន ព.ស. ១ ឆ្នាំ ព្រះជន្មាយុបាន ៨០ ឆ្នាំ ។ (ចូរមើលប្រស្នាលេខ ២២៨) ។

កាលកំណត់ពុទ្ធសករាជ គឺចាប់ផ្តើមតាំងអំពីថ្ងៃ ១ ១៥ ៦ ឆ្នាំមមី ។

កាលគ្រប់ប្រាំពាន់នៃព្រះសាសនា ក្នុងឆ្នាំជូត ។

២៩០ -ស. ចុះកាលដែលមិនទាន់មានពុទ្ធសករាជនោះតើ អ្នកស្រុកកណ្តៀបូរាណប្រើសករាជអ្វី? ប្រើមកបានប៉ុន្មានឆ្នាំ?

ច. គេប្រើមហាព្រហ្មន្តសករាជ ប្រើមកបានប្រមាណ ២០០០ ឆ្នាំសេស ទើបកើតមានពុទ្ធសករាជឡើង ។

ប្រស្នាពុទ្ធប្រវត្តិចប់តែប៉ុណ្ណោះ

ពុទ្ធប្បវត្តិគាថាសង្គហោ

"ការរួបរួមគាថាក្នុងពុទ្ធប្រវត្តិ"

១– គាថាប្រាប់ឈ្មោះជនបទទាំងដប់ប្រាំមួយ

អង្គញ្ច មគធំ កាសី វជ្ជីមល្លញ្ច កោសលំ
ចេតី វំសំ កុរុញ្ចាបិ សុរសេនញ្ច អស្សកំ
បញ្ចាលម្ហិ ច មច្ឆញ្ច គន្ធារញ្ចាបិ កម្ពោជំ
អវន្តិមេ ច សោឡស ជម្ពូទីបេបិ បាកដា ។

ជនបទទាំងឡាយ ១៦នេះគឺអង្គៈ១, មគធៈ១, កាសី១, វជ្ជី១, មល្លៈ១ កោសល១, ចេតី១, វំសៈ១, កុរុ១, សុរសេនៈ១, អស្សកៈ១, បញ្ចាលៈ១, មច្ឆៈ១, គន្ធារៈ១, កម្ពោជៈ១, អវន្តិ១ បានមានប្រាកដហើយក្នុងជម្ពូទ្វីប ។

២– គាថាប្រាប់ឈ្មោះឆ្នាំដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

កុក្កុដេ គព្ភវាសោ ច សោណោ ចុទនិក្ខមិ
ឧសភោ រាជសម្បត្តិ សសេ បព្វជិតោ ជិនោ ។
កុក្កុដេ សព្វញ្ញូ ពុទ្ធោ គត្វ ចក្កំ បវត្តយិ
និព្វានគមនំ សប្បេ សហស្សំ បញ្ច មូសិកេ ។

៣– គាថាប្រាប់ឈ្មោះថ្ងៃដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

ឱក្កន្តោ ច គុរុវារស្មិំ សុក្រវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មិំ អង្គារេ បរិនិព្វុតោ ។

៤– គាថាប្រាប់ឈ្មោះខែដែលព្រះសាស្តាចាប់បដិសន្ធិជាដើម

អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ
វិសាខបុណ្ណមីសម្ពុទ្ធោ វិសាខេ បរិនិព្វុតោ

ទាំង ៣ គាថានេះសេចក្តីប្រែមានក្នុងប្រស្នាលេខ ២៨៩ ហើយ ។

៥ – គាថាដែលពួកទេវតាទូលអារាធនាព្រះមហាបុរសឲ្យចុះមកត្រាស់ជាព្រះពុទ្ធថា៖

កាលោយន្តេ មហាវីរ ឧប្បជ្ជ មាតុកុច្ឆិយំ
សទេវកំ តារយន្តោ ពុជ្ឈស្សុ អមតំ បទំ ។

"បពិត្រព្រះអង្គអ្នកមានព្យាយាមដ៏ច្រើន កាលនេះសមគួរដល់ព្រះអង្គ ហើយសូមព្រះអង្គឲ្យកចុះទៅកើតក្នុងមាតុគភ៌ ហើយសូមចម្លងសត្វនិករក្នុងមនុស្សលោកព្រមទាំងទេវលោក ឲ្យផុតចាកភយៈ សង្សារវដ្ត ឲ្យបានត្រាស់ដឹងនូវផ្លូវប្រតិបត្តិដែលនឹងចូលកាន់ព្រះអមតមហានិព្វាន" ។

៦– គាថាដែលព្រះមហាបុរសរមិលមើលនូវមហាវិលោកនៈ ទាំង៥ថា៖

កាលំ ទេសញ្ច ទីបញ្ច កុលំ មាតរមេវ ច

"ទ្រង់មើលនូវកាល១, ប្រទេស១, ទ្វីប១, ត្រកូល១, មាតា១" ។

៧ គាថាចតុរង្គមហាបធាន

កាមំ តចោ នហារុ ច អដ្ឋិ ច អវសិស្សតុ
អវសុស្សតុ មេ សរីរេ សព្វន្តំ មំសលោហិតំ ។
យន្តំ បុរិសត្ថាមេន បុរិសវិរិយេន បុរិសបរក្កមេន បត្តព្វំ
ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតិ ។

"ស្បែក, សរសៃ, ឆ្អឹងចូរសល់នៅចុះ, សាច់នឹងឈាមក្នុងសរីរៈកាយរបស់យើងទាំងអស់ចង់រីងស្ងួតទៅក៏ដោយ គុណវិសេសដ៏លើសឯណា ដែលជាវិស័យបុគ្គលនឹងគប្បីបានដោយកំឡាំង នឹងសេចក្តីព្យាយាមប្រឹងប្រែងនៃបុរស កាលបើមិនសម្រេចគុណវិសេសនោះទេ យើងនឹងមិនលះបង់សេចក្តីព្យាយាមចោលចេញឡើយ" ។

៨. គាថាដែលមាណពធិកាជពោលសរសើរព្រះសាស្ដា

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មិំ លោកស្មិំ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆិន្នោ តិណ្ណោ តារេសិមំ បជំ ។

"បពិត្រព្រះអង្គជាបុរិសាជានេយ្យ ជាតិជាឧត្តមបុរសរាជក្នុងលោក

នេះខ្ញុំព្រះអង្គសូមថ្វាយវន្ទនាការផ្ដិតព្រមដោយទ្វារទាំង ៣ គឺកាយ វចី មនោប្រណាមក្រោមបង្គំជយុគលបាទ បុគ្គលក្នុងមនុស្សលោកព្រមទាំងទេវលោក នឹងប្រៀបផ្ទឹមឲ្យគ្រឹមស្មើនឹងព្រះអង្គជាអ្នកប្រសើរមិនមានឡើយ ព្រះអង្គបានត្រាស់ជាព្រះស្រីសពេជ្ញស្រេចហើយជ្រាបច្បាស់នូវចតុរារិយសច្ច ជាសាស្ដាចារ្យ មានព្រះតេជៈគ្របសង្កត់ឈ្នះពួកមារ ជាកំពូលអ្នកប្រាជ្ញឈ្លាសវៃក្នុងអនុស្ស័យនៃសត្វលោកទាំងអស់ នឹងចម្លងវេនេយ្យនិករឲ្យផុតចាកចតុរោឃកន្តារ ដាក់ដល់ត្រើយអមតមហានិព្វានដ៏ក្សេមក្សាន្តប្រាសចាកសង្សារទុក្ខក្នុងគ្រានេះ ។

៩– បឋមឧទានគាថាដែលព្រះពុទ្ធទាំងពួងមិនលះបង់ តែងទ្រង់បន្លឺក្នុងវេលាបានត្រាស់ដឹងថ្មីៗ ដើម្បីចំអកឲ្យតណ្ហាថា៖

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ
គហការក ទិដ្ឋោសិ បុន គេហំ នកាហសិ
សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

"កាលតថាគតមិនទាន់បានជួបប្រទះ (នូវពោធិញ្ញាណ) វិល

ស្វែងរកនូវជាងផ្ទះគឺតណ្ហា អ្នកធ្វើនូវផ្ទះគឺអត្តភាព ហើយអន្ទោលទៅរស់ សង្សារមានជាតិមិនតែមួយ, ជាតិគឺកិរិយាកើតរឿយ ៗ រមែងនាំមកនូវ សេចក្ដីទុក្ខ; ម្នាលជាងផ្ទះគឺតណ្ហា (ឥឡូវនេះ) តថាគតបានឃើញអ្នក ច្បាស់ហើយ; អ្នកនឹងធ្វើនូវផ្ទះគឺអត្តភាព (នេះ) ឲ្យតថាគតទៀតពុំបាន ឡើយ, ឆ្អឹងជំនីរគឺកិលេសទាំងអស់របស់អ្នក តថាគតបានបំបាក់ ហោលហើយ, ទាំងកំពូលនៃផ្ទះគឺអវិជ្ជារបស់អ្នក តថាគតក៏បានកំចាត់បង់ ហើយ; ចិត្តរបស់តថាគតបានដល់ហើយនូវព្រះនិព្វាន ដែលបានសង្ខារ ទៅប្រាសហើយ, តថាគតបានដល់ហើយនូវព្រះអរហត្តគឺការអស់ទៅនៃ តណ្ហាទាំងឡាយ" ។

១០- គាថាសម្រាប់នមស្សការសត្តមហាឋានថា:

បឋមំ ពោធិបល្លង្កំ ទុតិយំ អនិមិស្សកំ
តតិយំ ចង្កមំ សេដ្ឋំ ចតុត្ថំ រតនាឃរំ(១)
បញ្ចមំ អជបាលញ្ច មុចលិន្ទេន ឆដ្ឋមំ
សត្តមំ រាជាយតនំ សព្វពុទ្ធេហិ សេវិតំ
ឯតេ សត្ត មហាឋានា ជម្ពុទីប បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ទូរតោ

"មហាឋាន (ទីដ៏ប្រសើរ) មាន ៧ កន្លែង ដែលព្រះពុទ្ធជាម្ចាស់

១- រតនឃរា ដើម្បីនឹងរក្សាឆន្ទ ។

គ្រប់ព្រះអង្គធ្លាប់សេពហើយ គឺទី ១ ពោធិបល្ល័ង្ក, ទី ២ អនិមិស្សកចេតិយ ទី ៣ ទីចង្ក្រមដ៏ប្រសើរ, ទី ៤ ផ្ទះកែវ, ទី ៥ ដើមអជបាលនិគ្រោធ, ទី ៦ ស្រះមុចលិន្ទ, ទី ៧ ដើមកែះ ។ មហាឋានទាំង៧នេះ តាំងនៅក្នុងជម្ពូទ្វីបដែលមនុស្សនឹងទេវតាទាំងឡាយ តែងធ្វើសក្ការៈបូជា ខ្ញុំព្រះអង្គសូមថ្វាយបង្គំទីទាំង ៧ នោះអំពីចម្ងាយ" ។

១១ គាថាសម្រាប់នមស្សការសិក្ខត្តរចេតិយ

កកុសន្ធោ ធមការកំ កោនាគមនោ កាយពន្ធនំ
សាដិកំ កស្សបោ ពុទ្ធោ គោតមោ អដ្ឋិ កេសធាតុយោ ។

"ព្រះពុទ្ធកកុសន្ធៈ បញ្ចុះធមក្រក, ព្រះពុទ្ធកោនាគមនៈ បញ្ចុះវត្ថពន្ធ ព្រះពុទ្ធកស្សបៈបញ្ចុះសាដក ព្រះពុទ្ធគោតមបញ្ចុះកេសធាតុ៨សរសៃ" ។

១២- គាថាដែលព្រះសាស្តាទ្រង់ទទួលអារាធនាសហម្បតិព្រហ្ម នឹងសំដែងធម៌ប្រោសសត្វថា:

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

"ម្នាលសហម្បតិព្រហ្ម ! សត្វទាំងឡាយឯណា មានសោតប្បសាទ ក្រង់រង់ចាំស្តាប់ ហើយបញ្ចេញនូវសទ្ធាគឺសេចក្តីជឿ, ទ្វារទាំងឡាយនៃនគរឈ្មោះអមតៈ តថាគតបើករង់ចាំនូវសត្វទាំងឡាយនោះស្រេចហើយ; សត្វទាំងឡាយឯណា មានសញ្ញាគឺសេចក្តីសំគាល់ថា ស្តាប់ធម៌ជាការលំបាកគ្មានប្រយោជន៍ តថាគតក៏មិនសំដែងនូវធម៌ដ៏ល្អិតឧត្តមដល់សត្វទាំងឡាយនោះឡើយ" ។

១៣- គាថាព្រះពុទ្ធកិច្ច ៥ ប្រការ

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ ភិក្ខុឱវាទំ អឌ្ឍរត្តេ ទេវបញ្ហនំ
បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ
ឯតេ បញ្ចវិធេ កិច្ចេ វិសោធេតិ មុនិបុង្គវោ ។

"ព្រះសម្មាសម្ពុទ្ធជាចំបងជាងអស់អ្នកប្រាជ្ញ ទ្រង់ជំរះនូវពុទ្ធកិច្ចទាំងឡាយ ៥ ប្រការនេះគឺ ក្នុងពេលព្រឹកទ្រង់ស្តេចយាងបិណ្ឌបាត ១, ក្នុងពេលល្ងាចទ្រង់សំដែងធម៌ទេសនា ១, ក្នុងពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១, ក្នុងពេលអធ្រាត្រទ្រង់ដោះប្រស្នានៃទេវតា ១, ក្នុងពេលជិតភ្លឺទ្រង់ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹងនិងមិនគួរត្រាស់ដឹង ១" ។

១៤- គាថាពុទ្ធការកធម៌ ឬបារមី

ទានំ សីលញ្ច នេក្ខម្មំ បញ្ញា វិរិយេន បញ្ចមំ
ខន្តិ សច្ចមធិដ្ឋានំ មេត្តុបេក្ខាតិមេ ទស ។

"ធម៌ទាំង ១០ នេះគឺទាន ១, សីល ១, នេក្ខម្មៈ ១, បញ្ញា ១, វីរិយៈ ១, ខន្តី ១, សច្ចៈ ១, អធិដ្ឋាន ១, មេត្តា ១, ឧបេក្ខា ១ (ហៅថាពុទ្ធការកធម៌ឬបារមី)" ។

១៥- គាថាធម្មសមោធាន

មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ
បព្វជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា
អដ្ឋ ធម្មសមោធានា អភិនីហារោ សមិជ្ឈតិ ។

"អភិនីហារ រមែងសម្រេចព្រោះការរួបរួមពួកធម៌ទាំង ៨ ប្រការគឺភាពជាមនុស្ស ១, ដល់ព្រមដោយភេទ ១, ហេតុ ១, ជួបនឹងព្រះសាស្តា ១, បព្វជ្ជា ១, គុណសម្បត្តិ ១ អធិការ (ការធ្វើយ៉ាងក្រៃលែង) ១, សេចក្តីចូលចិត្ត ១" ។

១៦- គាថាសម្រាប់នមស្សការព្រះពុទ្ធទាំង

វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ
តិលោកកេតុំ តិភវេកនាថំ

យោ លោកសេដ្ឋោ សកលំ កិលេសំ

ឆេត្វាន ពោធេសិ ជនំ អនន្តំ ។

"ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឲ្យត្រាស់ដឹងហើយ ។ ខ្ញុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គទ្រង់ផុតអំពីច្រាំងនៃភពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយជាទីពឹងនៃសព្វសត្វក្នុងត្រៃភព" ។

យំ នម្មទាយ នទិយា បុលិនេ ច តីរេ

យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ

យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ

តំ បាទលញ្ឆនមហំ សិរសា នមាមិ ។

"ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្លូវខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) ក្នុងយោនកបុរី ខ្ញុំសូមក្រាបថ្វាយបង្គំដោយត្បូង ចំពោះទៅព្រះបាទនិងស្នាមព្រះបាទទាំងនោះ នៃព្រះសក្យមុនី" ។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ

សុមនកូដេ យោនកបុរេ

នម្មទាយ នទិយា បញ្ចបាទវរំ ឋានំ

អហំ វន្ទាមិ ទូរតោ ។

"ខ្ញុំសូមនមស្សការអំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺឋានលើភ្នំសុវណ្ណមាលិកៈ ១, លើភ្នំសុវណ្ណបព៌ត ១, លើភ្នំសុមនកូដ ១, ក្នុងយោនកបុរី ១, ក្បែរស្ទឹងនម្មទា ១" ។

១៧- គាថាសម្រាប់នមស្សការព្រះធាតុចេតិយ

មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ

ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ ។

"ព្រះគោតមបរមសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គបរិនិព្វានហើយ ឯក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុ ក្នុងទីទាំងឡាយនោះ ៗ ដោយផ្សេង ៗ គ្នា" ។

ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា

អសម្ភិន្នា វ តា សត្ត សេសា ភិន្នា វ ធាតុយោ ។

"ព្រះសារីរិកធាតុទាំងនោះ ដែលមិនបែកចេញមានប្រាំពីរអង្គគឺ ព្រះឧណ្ហីសធាតុ១(១) ព្រះទាឋាធាតុ(២)បួន, ព្រះអក្ខកធាតុ(៣) ពីរ ព្រះសារីរិកធាតុសេសក្រៅពីនោះសុទ្ធតែបែកចេញជាបំណែកតូចៗ" ។

មហន្តា បញ្ចនាឡី ច មជ្ឈិមា ច ឆ នាឡិយោ
ខុទ្ទកា បញ្ចនាឡី ច សម្ភិន្នា តិវិធា មតា ។

"ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថាមាន ៣ យ៉ាង គឺព្រះធាតុខ្នាតធំវាល់បានចំនួន ៥ នាឡិ, ព្រះធាតុខ្នាតកណ្ដាលវាល់បានចំនួន ៦ នាឡិ, ព្រះធាតុខ្នាតតូចវាល់បានចំនួន ៥ នាឡិ(៤)" ។

មហន្តា ភិន្នមុគ្គា ច មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា ។

"ព្រះបរមធាតុទាំងឡាយមានប្រមាណយ៉ាងនេះ គឺព្រះធាតុខ្នាតធំមានទំហំប៉ុនកំណាត់គ្រាប់សណ្ដែកបាយ ព្រះធាតុខ្នាតកណ្ដាលមានទំហំប៉ុនកំណាត់គ្រាប់អង្ករ ព្រះធាតុខ្នាតតូចមានទំហំប៉ុនគ្រាប់ស្ពៃ" ។

១- ឆ្អឹងថ្ងាស ។ ២- ព្រះចង្កូម ។ ៣- ឆ្អឹងដងកាំបិត ។ ៤ ព្រះធាតុរួមទាំងអស់ ១៦ នាឡិ ។

មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា(១)
ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ ។

"ព្រះបរមធាតុទាំងឡាយមានពណ៌ផ្សេងគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំមានពណ៌ដូចមាស ព្រះធាតុខ្នាតកណ្ដាល មានពណ៌ដូចកែវផ្លេក ព្រះធាតុខ្នាតតូចមានពណ៌ដូចផ្កាពិកុល(២) ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ" ។

ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ ។

"ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងវេសាលី ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងកបិលពស្តុ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងអលកប្បកៈ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងរាមគ្រាម ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងវេដ្ឋទីបកៈ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងបាវេយ្យកៈក្នុងមល្លរដ្ឋជនបទ ព្រះស្តូបមួយប្រតិស្ឋាននៅក្នុងក្រុងកុសិនារា (រួមជា ៨ កន្លែង)" ។

១ – បាលីខ្លះថា មុត្តិកប្បភាមានពណ៌ដូចកែវមុក្តា ។ ២ – ពណ៌សស្រគាំ

ឯតេ សារីរិកា ថូបា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

" ព្រះស្តូបទាំង ៨ នោះ ជាព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុប្រតិស្ឋាននៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំ នូវព្រះបរមធាតុទាំងឡាយក្នុងព្រះស្តូបទាំង៨នោះ ដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា " ។

ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ ។

" ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងស្ថានត្រៃត្រឹង្ស ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងពិភពនាគ ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងដែនគន្ធារៈ ព្រះទាឋាធាតុអង្គមួយប្រតិស្ឋានក្នុងសីហឡទ្វីប " ។

ឥមា ចតូសុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

" ព្រះទាឋាធាតុទាំងឡាយនេះ របស់ព្រះបរមសាស្តាប្រតិស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា " ។

ឧទ្ធំ ទក្ខិណាទាឋា ច តាវតឹសេ បតិដ្ឋិតា
អធោ ទក្ខិណាទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

"ព្រះទាឋាធាតុស្តាំខាងលើ ប្រតិស្ឋាននៅក្នុងស្ថានត្រៃត្រឹង្ស ព្រះទាឋាធាតុស្តាំខាងក្រោម ប្រតិស្ឋាននៅក្នុងសីហឡទ្វីប ព្រះទាឋាធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារៈ ព្រះទាឋាធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា" ។

ព្រហ្មលោកេ ទុស្សធាតុ វាមអក្ខកធាតុយោ
សព្វេ ព្រហ្មាភិបូជេន្តិ ថូបំ ទ្វាទសយោជនំ ។

" ព្រះទុស្សធាតុ(១) នឹងព្រះអក្ខកធាតុខាងឆ្វេងប្រតិស្ឋាននៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នាតែងបូជានូវព្រះស្តូបកំពស់ ១២ យោជន៍ (ដែលបញ្ចុះនៅព្រះធាតុទាំងនោះ)" ។

---

(១) ព្រះទុស្សធាតុ គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញហើយ ទ្រង់សំពត់កាសាវៈនៃឃដិការមហាព្រហ្មយកមកថ្វាយ ទ្រង់ប្រទានព្រះពស្ត្រនោះទៅឃដិការមហាព្រហ្ម បាន ទទួលយកទៅប្រតិស្ឋានឯព្រហ្មលោក ។

តាវត្តឹសម្ហិ ទេវានំ ចុឡាមណិម្ហិ កេសកំ
សព្វេ ទេវាភិបូជេន្តិ បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

"ទេវតាទាំងឡាយ ទាំងពួងដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនាតែងបូ-ជា នូវព្រះកេសធាតុដែលប្រតិស្ឋាននៅក្នុងចុឡាមណិចេតិយរបស់ទេវតាទាំងឡាយក្នុងស្ថានត្រៃត្រឹង្ស ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា "។

ចត្តាឡីស សមាទន្តា កេសា លោមា នខាបិ ច
ទេវា ហរន្តិ ឯកេកំ ចក្កវាឡបរម្បរា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

" ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផងព្រះលោមធាតុទាំងឡាយផង ព្រះនខធាតុទាំងឡាយផងទេវតាទាំង-ឡាយនាំទៅនូវព្រះធាតុមួយអង្គ ៗ កាន់ចក្រវាឡដទៃនឹងដទៃ គឺព្រះធាតុមួយអង្គ ៗក្នុងចក្រវាឡមួយៗ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតានឹងមនុស្សទាំងឡាយតែងបូជា" ។

អដ្ឋារសេ ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្សា ចេតិយា ច ការាបិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

"នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រមួយព្រះអង្គព្រះនាមធម្មាសោក ក្នុងកាលនោះព្រះអង្គបានកសាងព្រះចេតិយចំនួន ៨៤.០០០ ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយក្នុងព្រះចេតិយទាំងនោះ ដែលទេវតានឹងមនុស្សទាំងឡាយតែងធ្វើសក្ការបូជា " ។

ចប់ការរួបរួមគាថាក្នុងពុទ្ធប្រវត្តិ

តែប៉ុណ្ណេះ ៕

មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារទំព្រតេន៍"

136E_0 វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ 012 706 581

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។